សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការលែងលះ

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **កញ្ញា អ៊ុំ ចាន់រ៉ុង**

**កញ្ញា យី ឈីវអ៊ី**

ណែនាំដោយ

លោកស្រី **ឃឹម ម៉ាំណែត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences économiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការលែងលះ

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **កញ្ញា អ៊ុំ ចាន់រ៉ុង**

**កញ្ញា យី ឈីវអ៊ី**

ណែនាំដោយ

លោកស្រី **ឃឹម ម៉ាណែត**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ជាបឋម នាងខ្ញុំឈ្មោះ **អ៊ុំ ចាន់រ៉ុង** និងនាងខ្ញុំឈ្មោះ **យី ឈីងអ៊ី** ដែលជានិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ឆមាសទី២ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៤ ក្នុងឆ្នាំសិក្សា២០២០-២០២៤។

**សូមធ្វើការលំឱនកាយ ក្រាបថ្វាយបង្គំដោយកិច្ចប្រណិប័តន៍ សម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ៖**

| | |
|---|---|
| លោកឪពុកឈ្មោះ **អ៊ុំ ណារិទ្ធ** | អ្នកម្តាយឈ្មោះ **អ៊ុយ សុធា** |
| លោកឪពុកឈ្មោះ **យី គន្ធី** | អ្នកម្តាយឈ្មោះ **ទ្រី ស៊ីថា** |

ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ប្រៀនប្រដៅ ណែនាំ និងឧបត្ថម្ភទំនុកបម្រុងគ្រប់បែបយ៉ាងទាំងធនធានថវិកា និងសម្ភារៈសិក្សារៀនសូត្រព្រមទាំងបណ្តុះនូវស្មារតី តស៊ូ អំណត់អត់ធន់ព្យាយាមក្នុងការសិក្សារៀនសូត្រ រហូតដល់កូនមានឱកាសបានសិក្សាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដើម្បីក្លាយជា យុវជនដែលជាទំពាំងស្នងឫស្សីដ៏ល្អសម្រាប់សង្គមជាតិ។

បន្ថែមពីនេះ នាងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណដល់ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំផ្ទេរនូវចំណេះដឹង ដោយមិនខ្លាចនឿយហត់ និងជួយសម្របសម្រួលផ្នែកឯកសារ ស្មារតីអប់រំ និងសម្ភារៈផ្សេងៗ ដែលជាការរួមចំណែកមួយយ៉ាងសំខាន់ដល់នាងខ្ញុំទាំងពីរនាក់ក្នុងការស្រាវជ្រាវ ដើម្បីបញ្ចប់សរសេរសារណានេះ នាងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណចំពោះ៖

- **ឯកឧត្តមបណ្ឌិត លុយ ចន្ធា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង គណៈគ្រប់គ្រងទាំងអស់គ្រប់ជាន់ថ្នាក់ដែលបានសម្របសម្រួលនូវរាល់តម្រូវការនៃការសិក្សារបស់និស្សិតគ្រប់ជំនាន់។
- **អ្នកគ្រូ ឃឹម ម៉ាណែត** ជាគ្រូណែនាំ ក្នុងដំណើរការនៃការសរសេរសារណាដើម្បីបញ្ចប់ការសិក្សា ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការបង្ហាត់បង្ហាញ អប់រំណែនាំ ផ្តល់ឯកសារ និងត្រួតពិនិត្យនូវចំណុចខ្វះខាតព្រមទាំងកែតម្រូវដោយយកចិត្តទុកដាក់។

ជាចុងក្រោយនាងខ្ញុំទាំងពីរនាក់ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងពួង ដែលមាននូវលើលោកសូមជួយឱ្យតាមជួយថែរក្សាដល់អស់លោកអ្នកមានគុណ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បងប្អូន រាមច្បង និងមិត្តនិស្សិតទាំងឡាយជួបតែសេចក្តីសុខ និងពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

## **អារម្ភកថា**

ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នាងខ្ញុំឈ្មោះ **អ៊ុំ ចាន់រ៉ុង** និងនាងខ្ញុំឈ្មោះ **ឃី ឈីវអ៊ី** មានឱកាសបានសិក្សាស្វែងយល់នូវ ចំណេះដឹងយ៉ាងច្រើន ទាំងគោលការណ៍ ច្បាប់ព្រមទាំងការស្រាវជ្រាវពីស្ថានភាពជាក់ស្តែងនៃសង្គមផងដែរ។ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាគ្រឹះស្ថានកម្រិតឧត្តមសិក្សាមួយ ដែលប្រកបដោយគុណភាព និងប្រសិទ្ធិភាព តាមរយៈការបង្ហាត់បង្រៀនពី សាស្ត្រាចារ្យ ដែលលោកបានចែករំលែកនូវចំណេះដឹង បទពិសោធន៍ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែងក្នុងវិស័យតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលទទួលបានឱកាសរៀបចំនូវ សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទ ស្តីពី "**នីតិវិធីនៃការលែងលះ**" ទទួលបានការណែនាំ គាំទ្រ និងលើកទឹកចិត្តពី អ្នកគ្រូ **ឃឹម ម៉ារំណែត** ដែលជាសាស្ត្រាចារ្យផ្នែកនីតិរដ្ឋបវេណី នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លើការបង្ហាត់បង្ហាញ អប់រំទូន្មាន ដុះខាត់នូវភាពខ្វះខាតរបស់នាងខ្ញុំទាំងពីរនាក់ ដើម្បីជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវកម្មសិក្សានេះឱ្យរលូនទៅបាននឹងជាការសម្រេចចិត្តរបស់នាងខ្ញុំទាំងពីរនាក់ក្នុងការជ្រើសរើសប្រធានបទនេះ ដើម្បីយកមកសិក្សាស្រាវជ្រាវឱ្យបានល្អិតល្អន់ពីព្រោះនាងខ្ញុំទាំងពីរនាក់ យល់ឃើញថាតថភាពនៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ននេះ តែងតែមានការកើតឡើងនូវ អំពើហិង្សា និងភាពមិនចុះសម្រុងគ្នារវាងប្តី-ប្រពន្ធ ដែលបណ្តាលឱ្យមានបញ្ហានៅក្នុងគ្រួសារបណ្តាលឱ្យគ្រួសារ ដែលមានកូនៗនៅក្នុងគ្រួសារខ្វះភាពកក់ក្តៅ និងពុំទទួលបានការអប់រំ ដូចក្មេងដទៃទៀត ដែលមានគ្រួសារមានលក្ខណៈពេញបរិបូរណ៍។

នាងខ្ញុំទាំងពីរនាក់ដែលជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចំណេះដឹងនៅមានកម្រិតនៅឡើយក្នុងការស្រាវជ្រាវ និងចងក្រងឯកសារនេះឡើង ប្រាកដជាមាននូវចំណុច ខ្វះខាតផ្នែកខ្លឹមសារ និងកំហុសឆ្គងអក្ខរាវិរុទ្ធជាក់ជាមិនខាន។ នាងខ្ញុំសង្ឃឹមថារាល់កំហុសឆ្គងទាំងឡាយណាដែលកើតមានឡើងក្នុងសារណានេះនឹងទទួលបានការអធ្យាស្រ័យពីលោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋានទាំងអស់ជាក់ជាមិនខាន។ នាងខ្ញុំទាំងពីរនាក់រងចាំនូវការរិះគន់ និងកែតម្រូវក្នុងន័យស្ថាបនាពីសំណាក់អស់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់គ្រប់ពេលវេលា។

ជាទីបញ្ចប់នេះ នាងខ្ញុំទាំងពីរនាក់សូមជូនពរដល់ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់រូបឱ្យជួបប្រទះតែពុទ្ធពរបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រទី**

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃការលែងលះ

**១.១. ប្រភេទនៃការលែងលះ** ........ ៤

**១.២. មូលហេតុនៃការលែងលះ** ........ ៦

**១.២.១. អំពើផិតទៅលើសហព័ទ្ធ** ........ ៦

**១.២.២. ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ** ........ ៧

**១.២.៣. មិនដឹងច្បាស់ថាស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំ** ........ ៨

**១.២.៤. រស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ឆ្នាំ** ........ ៩

**១.២.៥. ករណីមិនអាចបដិសានឡើងវិញបាន** ........ ៩

## ជំពូកទី២

## នីតិវិធីនៃការលែងលះ

**២.១. ការលែងលះតាមការដាក់ពាក្យសុំលែងលះ** ........ ១១

**២.១.១. កិច្ចព្រមព្រៀងលែងលះ** ........ ១១

**២.១.២. ពាក្យព្រមព្រៀងសុំលែងលះ** ........ ១១

២.១.២.១. ពាក្យសុំជាលាយលក្ខណ៍អក្សរ ........ ១២

២.១.២.២. ពាក្យសុំដោយផ្ទាល់មាត់ ........ ១២

**២.១.៣. អាជ្ញាធរមានសមត្ថកិច្ច** ........ ១៣

២.១.៣.១. ក្រុមប្រឹក្សាឃុំ-សង្កាត់ ........ ១៣

២.១.៣.២. សាលាដំបូងរាជធានី/ខេត្ត ........ ១៣

**២.១.៤. នីតិវិធីជំនុំជម្រះ** ........ ១៤

២.១.៤.១. ការពិនិត្យពាក្យសុំព្រមព្រៀង ........ ១៤

២.១.៤.២. កោះហៅគូភាគី ........ ១៤

២.១.៤.៣. ការផ្សះផ្សានៅតុលាការ ........................................................................................ ១៥
២.១.៤.៤. ការទាញហេតុផលដោយផ្ទាល់មាត់ និងការសាកសួរដោយឆន្ទានុសិទ្ធិ ................. ១៥
**២.១.៥. ដីកាសម្រេច** ........................................................................................................ ១៦
**២.២. ការលែងលះតាមការដាក់ពាក្យបណ្តឹងលែងលះ** ............................................ ១៧
**២.២.១. ពាក្យបណ្តឹងលែងលះ** ........................................................................................ ១៧
២.២.១.១. ចំណុចដែលត្រូវសរសេរ ........................................................................................ ១៨
២.២.១.២. របៀបដាក់ពាក្យបណ្តឹង ......................................................................................... ១៨
**២.២.២. អាជ្ញាធរមានសមត្ថកិច្ច** ........................................................................................ ១៩
២.២.២.១. ក្រុមប្រឹក្សាឃុំ-សង្កាត់ ........................................................................................... ១៩
២.២.២.២. សាលាដំបូងរាជធានី /ខេត្ត ..................................................................................... ១៩
**២.២.៣. នីតិវិធីនៃការជំនុំជម្រះ** ......................................................................................... ១៩
២.២.៣.១. ការពិនិត្យពាក្យបណ្តឹង ............................................................................................ ២០
២.២.៣.២. កោះហៅគូភាគី ....................................................................................................... ២១
២.២.៣.៣. ការផ្សះផ្សាគូភាគី ................................................................................................... ២២
២.២.៣.៤. ការចាត់ចែងរក្សាការពារបណ្តោះអាសន្ន ..................................................................២៣
២.២.៣.៥. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល .................................................................. ២៤
២.២.៣.៦. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ..................................................................... ២៥
**២.២.៤. ការសម្រេចសេចក្តី** ................................................................................................ ២៧
២.២.៤.១. ការចេញសាលក្រមលែងលះ .................................................................................... ២៨
២.២.៤.២. ការសម្រេចមិនឱ្យលែងលះ...................................................................................២៩
២.២.៤.៣. បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់................................................................... ២៩

## ជំពូកទី៣

## អានុភាពនៃការលែងលះ

**៣.១. អានុភាពចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ** ........................................... ៣២

**៣.១.១. ចំពោះសហព័ទ្ធ** ........ ៣២

**៣.១.២. ចំពោះញាតិ និងនាមត្រកូល** ........ ៣២

**៣.១.៣. ចំពោះអត្តាធីនភាព** ........ ៣៣

**៣.២. អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ** ........ ៣៣

**៣.២.១. ទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា** ........ ៣៤

**៣.២.២. ទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់ដែលបានកំណត់** ........ ៣៤

៣.២.២.១. ទ្រព្យសម្បត្តិរួម ........ ៣៤

៣.២.២.២. ទ្រព្យសម្បត្តិដោយឡែក ........ ៣៥

**៣.៣. អានុភាពនៃការលែងលះចំពោះកូន** ........ ៣៥

**៣.៣.១. ការកំណត់អំណាចមេបា** ........ ៣៦

**៣.៣.២. អាហារកាតព្វកិច្ចចំពោះកូន** ........ ៣៦

**សេចក្តីសន្និដ្ឋាន** ........ ៣៧

**អនុសាសន៍** ........ ៣៨

**ឯកសារយោង**

**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

ជាទូទៅការរៀបអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្តរវាង បុរស និងនារី ដែលមានវ័យនីតិភាព ដើម្បីកសាងបាននូវគ្រួសារមួយដែលប្រកបដោយមានសុភមង្គល និងទទួលបាននូវភាពចុះសម្រុងគ្នារវាងដៃគូរដែលត្រូវជាប្តីប្រពន្ធ។ ការដែលទទួលបាននៅគ្រួសារមួយដែលមានសុភមង្គល លុះត្រាតែគូភាគីទាំងសងខាងត្រូវមានភាពស្មោះត្រង់ ចេះអត់ឱន យោគយល់ មិនផិតក្បត់គ្នា និងចេះអធ្យាស្រ័យ ឱ្យគ្នាទៅវិញទៅមក ជាពិសេសជាងនេះទៀតនោះ ភាគីទាំងសងខាងត្រូវចេះគោរពស្រលាញ់នូវឪពុកម្តាយ បងប្អូន សាច់ញាតិ ទាំងសងខាងផងដែរ។

ក្រោយពេលដែលបានរៀបអាពាហ៍ពិពាហ៍គ្រួសារខ្លះក៏បានសមប្រកបដែលមានភាពចុះសម្រុងគ្នា និងបានរួមរស់ជាមួយគ្នា និងចេះគោរពស្រលាញ់គ្នា រហូតបានជាកូនចៅ និងបានបង្កើតឱ្យគ្រួសារមួយនេះមានភាពកក់ក្តៅ។ ចំណែកឯគ្រួសារខ្លះទៀតពុំបានសមបំណងទេ ដែលប្តី ប្រពន្ធ មិនបានរួមរស់ជាមួយគ្នាដោយ ពុំទទួលបានភាពចុះសម្រុង និងការគោរពស្រលាញ់ឱ្យតម្លៃគ្នាទេ ផ្ទុយទៅវិញគ្រួសារនោះតែងតែមានភាពកាំរកូស ការប្រើអំពើហិង្សា និងមិនចេះគោរពស្រលាញ់គ្នា ដែលជាហេតុបណ្តាលឱ្យភាគីទាំងសងខាង មិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន។ ចំពោះបញ្ហានេះដែរ ទើបសហព័ទ្ធម្ខាង ឬគូភាគីទាំងសងខាង តែងតែដាក់ពាក្យសុំរំលាយចំណងអាពាហ៍ពិពាហ៍ពីគ្នា ក្នុងករណីដែលទំនាក់ទំនងគ្រួសារនេះបែកបាក់ដោយមានមូលហេតុណាមួយ ឬចំណងអាពាហ៍ពិពាហ៍នេះមិនអាចបដិទានដូចដើមវិញបាន។

នៅក្នុងសង្គមការកសាងគ្រួសារដែលបង្កើតឡើងដោយការរៀបអាពាហ៍ពិពាហ៍កើតមានជាហូរហែរ ហើយការលែងលះដោយការរស់នៅមិនចុះសម្រុងគ្នា និងការលែងលះដោយមានមូលហេតុផ្សេងៗទៀតក៏មានជាបន្តបន្ទាប់ផងដែរ។ ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីមិនមានអានុភាពតាមផ្លូវច្បាប់ទេ ប្តីប្រពន្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ ទើបពួកគេជាប្តីប្រពន្ធស្របច្បាប់។ ប្រការនេះដែរ បើចង់រំលាយចំណងអាពាហ៍ពិពាហ៍ ប្តីប្រពន្ធក៏ត្រូវឆ្លងកាត់នីតិវិធីតាមផ្លូវច្បាប់វិញផងដែរ ពោលគឺតាមរយៈការលែងលះ។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

ដោយហេតុថាបច្ចុប្បន្ននេះតែងតែប្រទះឃើញនៅភាពមិនចុះសម្រុងគ្នារវាងសហព័ទ្ធនឹងឈានដល់ការលែងលះគ្នា ដែលការលែងលះគ្នានេះតែងតែជួបនៅបញ្ហាពាក់ព័ន្ធជាច្រើនជាមួយនឹងការបែងចែកនូវទ្រព្យសម្បត្តិ អ្នកមានអំណាចមេបា ការបង់នៅអាហារកាតព្វកិច្ច និងបញ្ហាផ្សេងៗជាច្រើនទៀត ដែលបង្កើតបានជាចម្ងល់ មិនថាមិត្តនិស្សិតអ្នកសិក្សា សហព័ទ្ធដែលមានបំណងចង់លែងលះគ្នា ប្រជាពលរដ្ឋ រួមទាំងនាងខ្ញុំទាំងពីរនាក់ផងដែរ។ ចម្ងល់ដែលពាក់ព័ន្ធជាមួយការលែងលះមានដូចជា៖

- តើមូលហេតុអ្វីដែលអាចបណ្តាលឱ្យមានការលែងលះ?
- តើការលែងលះ ត្រូវបានអនុលោមតាមបទដ្ឋានគតិយុត្តអ្វីខ្លះ?
- តើការលែងលះនៅប្រទេសកម្ពុជាត្រូវបានធ្វើឡើងជាប៉ុន្មានប្រភេទ?
- តើការលែងលះតាមការដាក់ពាក្យសុំ ត្រូវបានប្រព្រឹត្តបែបណាខ្លះ តាមរយៈការដោះស្រាយនៅតុលាការ?
- តើការលែងលះតាមការដាក់ពាក្យបណ្តឹង ត្រូវបានប្រព្រឹត្តបែបណាខ្លះ តាមរយៈការដោះស្រាយនៅតុលាការ?
- តើក្រោយពេលដែលត្រូវបានលែងលះ ទ្រព្យសម្បត្តិ កូន អាហារកាតព្វកិច្ច សិទ្ធិ និងករណីយកិច្ចផ្សេងទៀត តុលាការនឹងត្រូវធ្វើការសម្រេចបែបណា ឬបែងចែកបែបណា?

ដូច្នេះហើយទើបបានជាបង្កើតឱ្យមាននៅការស្រាវជ្រាវនៅប្រធានបទ "នីតិវិធីនៃការលែងលះ" ដើម្បីធ្វើការបកស្រាយនូវចម្ងល់ដែលកើតមានដូចខាងលើ។

## ៣. គោលបំណង និងអត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវអំពីប្រធានបទមួយនេះ នាងខ្ញុំទាំងពីរនាក់មានគោលបំណងសិក្សាអំពីនីតិវិធីនៃការលែងលះ ដែលការលែងលះត្រូវបានធ្វើឡើងជាពីរ គឺការលែងលះតាមការដាក់ពាក្យសុំលែងលះ និងការលែងលះតាមការដាក់ពាក្យបណ្តឹងលែងលះ ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីមិនតែប៉ុណ្ណោះគោលដៅសំខាន់នៃការលែងលះ គឺការបញ្ចប់កិច្ចព្រមព្រៀង ឬចំណងអាពាហ៍ពិពាហ៍ជាប្តីប្រពន្ធ។ មិនតែប៉ុណ្ណោះអត្ថបទសារណាមួយនេះបានបង្កើននូវចំណេះដឹង និងបានសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់អំពីនីតិវិធីនៃការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ដែលបានប្រព្រឹត្តនៅប្រទេសកម្ពុជា ចាប់ពីពេលដែលកើតមាន មូលហេតុនៃការលែងលះ រហូតដល់ការដាក់ពាក្យសុំលែងលះ ឬការដាក់ពាក្យបណ្តឹងលែងលះ ទៅកាន់អាជ្ញាធរដែលមានសមត្ថកិច្ច ហើយនឹងធ្វើការដោះស្រាយទៅនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង និងនីតិវិធីរដ្ឋប្បវេណី។ ម្យ៉ាងវិញទៀតការស្រាវជ្រាវរបស់នាងខ្ញុំទាំងពីរនាក់ក៏បានធ្វើឱ្យ នាងខ្ញុំទាំងពីរនាក់ និងមិត្តអ្នកអាន បានសិក្សាស្វែងយល់អំពីមូលហេតុនៃការលែងលះ នីតិវិធីនៃការដោះស្រាយរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងការដោះស្រាយតាមប្រព័ន្ធតុលាការផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ដោយហេតុថាការលែងលះអាចកើតមានឡើងដោយសម្បូរបែប ដូចជា៖ ការលែងលះរវាងពលរដ្ឋដែលមានសញ្ជាតិខ្មែរដូចគ្នា ការលែងលះរវាងពលរដ្ឋដែលមានសញ្ជាតិខ្មែរ និងពលរដ្ឋដែលមានសញ្ជាតិបរទេស ការលែងលះរវាងពលរដ្ឋដែលមានសញ្ជាតិខ្មែរដូចគ្នាតែត្រូវបានធ្វើឡើងនៅបរទេស ការលែងលះរវាងពលរដ្ឋ

ដែលមានសញ្ជាតិបរទេសតែត្រូវបានធ្វើឡើងនៅប្រទេសកម្ពុជា និងការលែងលះជាច្រើនប្រភេទផ្សេងៗទៀត។ អាស្រ័យហេតុនេះ ដើម្បីរក្សានូវប្រសិទ្ធិភាពលើការស្រាវជ្រាវ អំពីប្រធានបទស្តីនីតិវិធីនៃការលែងលះនេះ នាងខ្ញុំទាំងពីរនាក់សិក្សាស្រាវជ្រាវត្រឹមកម្រិតនៃនីតិវិធីនៃការលែងលះដែលបានធ្វើឡើងនៅរវាងពលរដ្ឋខ្មែរជាមួយពលរដ្ឋខ្មែរ (បានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់) ដែលបានប្រព្រឹត្តនៅលើទឹកដីប្រទេសកម្ពុជាតែប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ប្រធានបទខាងលើ នាងខ្ញុំទាំងពីរនាក់បានខិតខំព្យាយាមស្រាវជ្រាវដោយបានប្រមូលនូវឯកសារ និងច្បាប់ដែលបានពាក់ព័ន្ធផ្សេងៗ ដូចជាការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណេត រួមទាំងចំណេះដឹងដែលទទួលបានពីលោកគ្រូ អ្នកគ្រូ សិស្សច្បង ព្រមទាំងអ្នកវិជ្ជាជីវៈច្បាប់ ដែលកំពុងអនុវត្តផ្ទាល់ ដែលមានចំណេះជំនាញយ៉ាងច្បាស់ដូចជា ចៅក្រម ក្រឡាបញ្ជី មេធាវី ដើម្បីចង់ក្រងសារណាមួយនេះឡើង។

## ៦. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ដើម្បីធ្វើការបកស្រាយប្រធានបទនេះឱ្យមានភាពច្បាស់លាស់ នាងខ្ញុំទាំងពីរនាក់បានធ្វើការបែងចែកសារណាស្រាវជ្រាវនេះ ជាបីជំពូកសំខាន់ៗ ដូចខាងក្រោម៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃការលែងលះ** ដែលនៅក្នុងជំពូកនេះ បានបង្ហាញ និងបកស្រាយអំពីមូលហេតុដែលមានចែងនៅបទបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ និងមូលហេតុសំខាន់ៗផ្សេងទៀត ដែលសហព័ទ្ធមិនអាចបដិទានចំណងអាពាហ៍ពិពាហ៍បាន។

**ជំពូកទី២៖ នីតិវិធីនៃការលែងលះ** ដែលសិក្សាទៅលើការចាប់ផ្តើមនៃនីតិវិធីដែលមានដូចជា៖ ការដាក់ពាក្យសុំលែងលះ, ការដាក់ពាក្យបណ្តឹងលែងលះ, ការពិនិត្យទៅលើពាក្យសុំ, ការបញ្ជូនឯកសារផ្សេងៗដែលពាក់ព័ន្ធជាមួយនឹងការអនុវត្តនីតិវិធី, ការផ្សះផ្សានៅក្រុមប្រឹក្សាឃុំ-សង្កាត់, ការធ្វើដោះស្រាយតាមប្រព័ន្ធតុលាការ និងជាពិសេសការសម្រេចសេចក្តីរបស់តុលាការ។

**ជំពូកទី៣៖ អានុភាពនៃការលែងលះ** ដែលនិយាយពីអានុភាពក្រោយពេលដែលបានធ្វើការលែងលះគ្នារួចមក ឬក្រោយពេលដែលបានរំលាយចំណងអាពាហ៍ពិពាហ៍ ជាពិសេស គឺបកស្រាយអំពីសេចក្តីសម្រេចរបស់តុលាការក្រោយពេលដែលបានធ្វើនីតិវិធីដែលមានចែងនូវក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងទៅលើការសម្រេចបែងចែកទ្រព្យសម្បត្តិ កូន សិទ្ធិ និងករណីយកិច្ចផ្សេងៗទៀតតាមការទាមទាររបស់ភាគី និងតាមឆន្ទានុសិទ្ធិរបស់ចៅក្រម។

# ជំពូកទី១
# សញ្ញាណទូទៅនៃការលែខលះ

# ជំពូកទី១
# សញ្ញាណទូទៅនៃការលែងលះ

ជាទូទៅបុរស និងស្ត្រី ដែលដល់វ័យនីតិភាពគ្រប់ការតាមបញ្ញត្តិច្បាប់ គឺមានសិទ្ធិអាចជ្រើសរើសដៃគូដើម្បីរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដើម្បីក្លាយជាប្តីប្រពន្ធ និងបង្កើតនៅគ្រួសារថ្មីមួយទៀតដែលប្រកបដោយសុភមង្គល។ ការដែលបានរៀបអាពាហ៍ពិពាហ៍ក្លាយជាប្តីប្រពន្ធ ដើម្បីរួមរស់នៅជាមួយគ្នា ដែលគូភាគីទាំងសងខាង ព្រមទាំងឪពុកម្តាយរបស់គូភាគីទាំងសងខាង គឺសុទ្ធតែមានបំណងប្រាថ្នាចង់ឱ្យសហព័ទ្ធកសាងគ្រួសារមួយដែលមានអនាគតរុងរឿងចេះសាមគ្គីគ្នា ចេះអធ្យាស្រ័យគ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក មានជីវភាពរុងរឿងនៅក្នុងគ្រួសារដែលជា កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃគ្រួសារ។

ក្រោយពេលដែលគូភាគីបានរៀបអាពាហ៍ពិពាហ៍ ចាប់ដៃគ្នាជាគូស្វាមី ភរិយា និងបានរួមរស់ជាមួយគ្នា គ្រួសារខ្លះបានរួមរស់ជាមួយគ្នាប្រកបដោយមានសុភមង្គលនៅក្នុងគ្រួសារ មានជីវភាពធូធារ ចេះស្រលាញ់គោរពគ្នាទៅវិញទៅមក និងបានបង្កើតកូនចៅ។ ប៉ុន្តែគ្រប់បុរស និងស្ត្រី ដែលបានរៀបអាពាហ៍ពិពាហ៍ និងចាប់ដៃគូគ្នាជាប្តី ប្រពន្ធមិនសុទ្ធតែទទួលបាននូវសុភមង្គលដូចគ្នាទាំងអស់នោះទេ ផ្ទុយទៅវិញគ្រួសារខ្លះ ក្រោយពេលដែលបានរៀបអាពាហ៍ពិពាហ៍ហើយ គឺមានភាពមិនចុះសម្រុងគ្នា មិនចេះស្រលាញ់គោរពគ្នា មានអំពើហិង្សានៅក្នុងគ្រួសារដោយមានការ រំលោភបំពានសិទ្ធិ និងផលប្រយោជន៍របស់ភាគីណាមួយហើយពុំអាចបដិទានឡើងវិញបាន ដែលជាហេតុបណ្តាលឱ្យគ្រួសារពុំមានសុភមង្គល ការអស់មនោសញ្ចេតនានឹងឈានទៅដល់លែងលះគ្នា ដើម្បីរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ប៉ុន្តែការរំលាយនៅចំណងអាពាហ៍ពិពាហ៍ ក៏បានធ្វើឱ្យខាតបង់នៅផលប្រយោជន៍របស់ភាគី ដល់កូន ការជះឥទ្ធិពលអាក្រក់ដល់កូន ក្នុងការចិញ្ចឹមបីបាច់ ជាពិសេសធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរ។

ផ្អែកតាមគោលការណ៍នៃនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ ឈរលើអាពាហ៍ពិពាហ៍ដោយបានស្ម័គ្រចិត្តដើម្បីរៀបអាពាហ៍ពិពាហ៍ នៅពេលដែលមានការអស់មនោសញ្ចេតនា មិនអាចរួមរស់នៅជាមួយគ្នាបានតទៅទៀត គូភាគីក៏អាចលែងលះគ្នាបានដែរ តែការលែងលះក៏ត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្តផងដែរ។ ដូច្នេះ នៅពេលដែលគូភាគីមានបំណងចង់រំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ គឺត្រូវតែមានហេតុផលសមស្របទៅតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដោយគូភាគីមិនអាចរំលាយទំទាក់ទំនងអាពាហ៍ពិពាហ៍តាមតែទំនើងចិត្តរបស់ខ្លួនបានឡើយ។

## ១.១. ប្រភេទនៃការលែងលះ

យោងតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានចែងបទបញ្ញត្តិពីការលែងលះមានពីរប្រភេទ គឺការលែងលះតាមការដាក់ពាក្យសុំ និងការលែងលះតាមការដាក់ពាក្យបណ្តឹង។

- **ការលែងលះតាមការដាក់ពាក្យសុំ៖** ការលែងលះតាមការដាក់ពាក្យសុំ គឺជាការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ដោយមានការព្រមព្រៀងគ្នាពីភាគីនៃអាពាហ៍ពិពាហ៍ ប៉ុន្តែតុលាការអាចឱ្យលែងលះគ្នាបានក្រោយពីបានយល់ឃើញថា ភាគីទាំងសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយអាពាហ៍ពិពាហ៍។[1] ចំពោះការលែងលះដោយការដាក់ពាក្យសុំ ភាគីត្រូវព្រមព្រៀងគ្នារួចជាស្រេចទាំងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ និងការព្រមព្រៀងគ្នាលើការបែងចែកលើកម្មវត្ថុនៃសិទ្ធិ និងកាតព្វកិច្ចផ្សេងៗទៀតនៅក្នុងពាក្យសុំទៅកាន់តុលាការ។ ដើម្បីឱ្យភាគីមានសិទ្ធិនៅក្នុងការធ្វើពាក្យសុំលែងលះ ភាគីត្រូវតែបង្ហាញឱ្យតុលាការបានដឹងអំពីមូលហេតុដែលនាំឱ្យមានការដាក់ពាក្យសុំលែងលះ។ មូលហេតុដែលតុលាការយល់ព្រម ទទួលយករឿងក្តីលែងលះនោះមកធ្វើការសម្រេច លុះត្រាតែមានមូលហេតុត្រឹមត្រូវដូចបានរៀបរាប់នៅចំណុចខាងលើ (មូលហេតុនៃការលែងលះ)។ ទោះបីជាមូលហេតុនៃការលែងលះមានច្រើនក៏ពិតមែនតែភាគីដែលបានស្នើសុំលែងលះដោយការដាក់ពាក្យសុំច្រើនតែលើកយកចំណុចចុងក្រោយគេមកធ្វើជាមូលហេតុដាក់ពាក្យសុំលែងលះ គឺមូលហេតុផ្សេងៗដែលនាំឱ្យមានការរស់នៅមិនចុះសម្រុងគ្នា ហើយមិនអាចបដិទានឡើងវិញបាន មកធ្វើជាមូលហេតុដើម្បីដាក់ពាក្យសុំលែងលះដើម្បីឱ្យតុលាការសម្រេចការលែងលះ។ ការលែងលះដោយការដាក់ពាក្យសុំ មិនមានភាពស្មុគស្មាញច្រើននៅពេលដែលតុលាការធ្វើនីតិវិធីទេ ព្រោះថាភាគីបានព្រមព្រៀងគ្នាលើកម្មវត្ថុផ្សេងៗ ដោយគ្រាន់តែសុំឱ្យតុលាការសម្រេចតាមការព្រមព្រៀងតែប៉ុណ្ណោះ។ ការលែងលះតាមការដាក់ពាក្យសុំ គឺត្រូវធ្វើឡើងដោយពាក្យសុំទៅតុលាការ ហើយតុលាការចេញសេចក្តីសម្រេចក្រោមរូបភាពជាដីកាសម្រេច។

- **ការលែងលះតាមការដាក់ពាក្យបណ្តឹង៖** ការលែងលះតាមការដាក់ពាក្យបណ្តឹង គឺជាការទាមទារឱ្យលែងលះរបស់ភាគីម្ខាងនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ ដោយផ្អែកលើមូលហេតុ ដែលកំណត់ដោយច្បាប់ ប្រសិនបើការលែងលះតាមការដាក់ពាក្យបណ្តឹង គ្មានមូលហេតុត្រឹមត្រូវដូចដែលបានរៀបរាប់នូវខាងលើទេនោះ តុលាការក៏មិនអាចទទួលរឿងលែងលះ និងសម្រេចឱ្យលែងលះបានដែរ។ ការកើតឡើងនៃការលែងលះដោយការដាក់ពាក្យបណ្តឹងលែងលះដោយសារតែភាគីទាំងសងខាងមានការទាមទាររៀងខ្លួនដែលនាំឱ្យមានការខ្វែងគំនិតគ្នា លើការពិភាក្សាក្នុងការបែងចែកអំពីកម្មវត្ថុ និងកាតព្វកិច្ចផ្សេងៗ ដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍ ដែលមានការទាមទារដូចគ្នាឬដណ្តើមនៅកម្មវត្ថុដែលបានទាមទារគ្នា។ ម្យ៉ាងវិញទៀត ភាគីដែលបានដាក់ពាក្យបណ្តឹងលែងលះ ត្រូវធ្វើពាក្យបណ្តឹងលែងលះដាក់ទៅតុលាការដែលមានសមត្ថកិច្ច ដោយភ្ជាប់ជាមួយនៅមូលហេតុដែលកំណត់ដោយច្បាប់ និងឯកសារជាភស្តុតាងផ្សេងៗដែលបញ្ជាក់ពីទំនាក់ទំនង ឬការទាមទារ។ ចំពោះការលែងលះដោយការដាក់ពាក្យសុំលែងលះ គឺមានភាពស្មុគស្មាញ ព្រោះថាភាគីមិនបានព្រមព្រៀងទៅលើកម្ម

[1] ក្រមរដ្ឋប្បវេណី មាត្រា៩៧៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

វត្ថុដែលបានទាមទារ ដែលការសម្រេចរបស់តុលាការត្រូវសម្រេចដោយការពិនិត្យទៅលើអង្គហេតុ ភស្តុតាង និងតាមឆន្ទានុសិទ្ធិរបស់តុលាការ។

### ១.២. មូលហេតុនៃការលែងលះ

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយរវាងគូស្រករពីរនាក់ បុរស និងស្ត្រី ដែលបានសម្រេចចិត្តបង្កើតចំណងគតិយុត្តរួមគ្នា ក្នុងនាមជាសហព័ទ្ធដើម្បីរួមរស់ ដែលទំនាក់ទំនងនេះក៏ត្រូវបានទទួលស្គាល់ដោយច្បាប់ផងដែរ បន្ទាប់ពីពេលដែលអ្នកទាំងពីរបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា។ អាពាហ៍ពិពាហ៍ គឺជាចំណងផ្លូវច្បាប់ ដែលអាពាហ៍ពិពាហ៍ជាកិច្ចសន្យាមួយបែប ដែលមិនដូចជាកិច្ចសន្យាដ៏ទៃទៀតទេ ដែលភាគីមិនអាចរំលាយ ឬបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍តាមទំនើងចិត្តបានឡើយ ព្រោះថាការរៀបអាពាហ៍ពិពាហ៍ជាការសម្រេចចិត្ត និងជាឆន្ទៈរបស់សហព័ទ្ធ។ នៅក្នុងអំឡុងពេលដែលភាគីបានរួមរស់នៅជាមួយគ្នាក្នុងនាមជាសហព័ទ្ធ ភាគីក៏បានបង្កើតនូវចំណងអាពាហ៍ពិពាហ៍ជាច្រើនដូចជា ការប្រើប្រាស់នាមត្រកូល, បុត្រដែលបានចិញ្ចឹមមករួមគ្នា, ទ្រព្យសម្បត្តិដែលបានព្យាយាមរកមករួមគ្នា, ការប្រើប្រាស់សិទ្ធិ និងករណីយកិច្ចផ្សេងៗទៀត ក្នុងគ្រួសារខ្លះបានរួមរស់ជាមួយគ្នាយ៉ាងមានសុភមង្គល តែគ្រួសារខ្លះទៀតមិនសមប្រកបគ្មានសុភមង្គល ព្រោះថានូវក្នុងចំណងអាពាហ៍ពិពាហ៍តែងតែមានជួបប្រទះនូវបញ្ហា ដោយសារការមិនចុះសម្រុងគ្នា ក៏ជាហេតុបណ្តាលឱ្យគ្រួសារបែកបាក់គ្នាដែលឈានដល់ការលែងលះគ្នា។ ដូច្នេះហើយទើបក្រមរដ្ឋប្បវេណីបានចែងយ៉ាងច្បាស់អំពីមូលហេតុនៃការលែងលះដែលមាន[2] (១.១.១) អំពើផិតទៅលើសហព័ទ្ធ (១.១.២) ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ (១.១.៣) មិនដឹងច្បាស់ថាស្លាប់ ឬរស់អស់រយៈពេលមួយឆ្នាំ (១.១.៤) រស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលមួយឆ្នាំ និង (១.១.៥) ករណីមិនអាចបដិទានបាន។

#### ១.២.១. អំពើផិតទៅលើសហព័ទ្ធ

អំពើផិត គឺជាអំពើដែលសហព័ទ្ធម្ខាងក្នុងចំណងអាពាហ៍ពិពាហ៍ ហើយមានចំណងផ្លូវភេទ (រួមសមគ្គសង្វាស) ជាមួយបុគ្គលផ្សេងទៀត ដែលមិនមែនជាសហព័ទ្ធរបស់ខ្លួន។ ក្នុងករណីដែលភាគីម្ខាងលួចលាក់រួមរ័ក្សជាមួយបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ នោះភាគីដែលត្រូវបានគេផិតអាចដាក់ពាក្យបណ្តឹងលែងលះដោយលើកយកមូលហេតុនេះបាន។

ឧទាហរណ៍៖ លោក A និងស្ត្រី B បានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ ស្រាប់តែ ៥ (ប្រាំ) ឆ្នាំក្រោយមក លោក A បានលួចលាក់មានស្រីកំណាន់នៅក្រៅ រយៈពេល ២ (ពីរ) ឆ្នាំមកហើយ។ លោកស្រី B ក៏បានស៊ើបដឹងរឿងនេះ ក៏មានការខកចិត្តទៅលើលោក A យ៉ាងខ្លាំង និងមិនអាច

[2] ក្រមរដ្ឋប្បវេណី មាត្រា៩៧៨ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

រួមរស់ជាមួយគ្នាតទៅទៀតបានទេ។ ដូច្នេះក្នុងករណីនេះ លោកស្រី B អាចសុំលែងលះជាមួយលោក A បាន ដោយមូលហេតុ លោក A បានផិតក្បត់ដោយលួចលាក់មានស្រីកំណាន់នៅក្រៅក្នុងចំណងអាពាហ៍ពិពាហ៍។

ដូចដែលបានលើកឧទាហរណ៍ខាងលើនេះ ដែលលោក A បានប្រព្រឹត្តទង្វើរផិតក្បត់ លោកស្រី B ហើយ លោកស្រី B អាចយកមូលហេតុនេះជាការអះអាងដើម្បីលែងលះ ប៉ុន្តែលោកស្រី B ត្រូវមានភស្តុតាងមកបញ្ជាក់ផងដែលថា លោក A ពិតជាបានប្រព្រឹត្តទង្វើរផិតក្បត់ពិតមែន ដែលភស្តុតាងអាចជាការថតរូប ថតវិឌីអូ ដែលបានបង្ហាញពីទំនាក់ទំនងផ្លូវភេទរបស់សហព័ទ្ធម្ខាងទៀត ឬអង្គហេតុប្រហាក់ប្រហែលដែលអាចវាយតម្លៃបានថាមានអំពើផិត ដូចជាការចាកចេញពីបន្ទប់សណ្ឋាគារជាមួយគ្នាដោយមានភាពផ្អែមល្ហែមជាដើម។ អាស្រ័យហេតុនេះហើយ ប្រសិនបើភាគី ដែលទាមទារឱ្យលែងលះមិនបានបង្ហាញថា មានអំពើផិតទេ តុលាការនឹងមិនអាចសម្រេចឱ្យលែងលះទេ។

នៅក្នុងការអនុវត្តជាក់ស្តែងនៃការលែងលះ ការប្រព្រឹត្តអំពើផិតនេះ គឺមានចំនួនច្រើនជាងមូលហេតុផ្សេងៗទៀតដែលមាននៅក្នុងក្រមរដ្ឋប្បវេណី។ ប៉ុន្តែទោះបីជាភាគីដែលបានទាមទារលែងលះ ពុំបានបង្ហាញនៅភស្តុតាងដើម្បីបញ្ជាក់អំពីការផិតរបស់ភាគីម្ខាងទៀតក៏ដោយ ក៏តុលាការអាចសម្រេចឱ្យលែងលះបានដែល បើតុលាការយល់ឃើញថា សហព័ទ្ធពុំអាចរួមរស់ជាមួយគ្នាបានតទៅទៀតទេ ឬអាចបង្ករឱ្យកើតមាននៅអំពើហិង្សានៅក្នុងគ្រួសារ កាន់តែធ្ងន់ធ្ងរថែមទៀត។

### ១.២.២. ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ

ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ ក៏ជាមូលហេតុមួយដែលមាននៅក្នុងក្រមរដ្ឋប្បវេណីបានកំណត់ជាហេតុផលនៃការលែងលះផងដែរ។[3] នៅត្រង់ចំណុចនេះ គឺវាផ្ទុយទៅនឹងបទបញ្ញត្តិដែលមាននៅក្នុងក្រមរដ្ឋប្បវេណីដែលសហព័ទ្ធ មានករណីយកិច្ចរួមរស់នឹងគ្នា សហការគ្នា និងសង្គ្រោះគ្នាទៅវិញទៅមក។[4] ដោយហេតុថា បុរស និងស្ត្រីរៀបអាពាហ៍ពិពាហ៍ ក្នុងគោលបំណងរួមសុខ រួមទុក្ខ ដើម្បីរួមរស់ជាមួយគ្នា ដូច្នេះការដែលមានភាគីម្ខាងបោះបង់នៅភាគីម្ខាងទៀតដោយគ្មានមូលហេតុត្រឹមត្រូវទេនោះ វាហាក់បីដូចជា អយុត្តិធម៌ណាស់ចំពោះភាគីដែលត្រូវបានគេបោះបង់ចោល ទើបភាគីដែលរងគ្រោះអាចលើកនៅចំណុចនេះជាមូលហេតុនៃការលែងលះបាន។

ឧទាហរណ៍៖ លោក A ជាប្តី និងលោកស្រី B ជាប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ តែក្រោយពេលដែលបានរៀបអាពាហ៍ពិពាហ៍អស់រយៈពេល ២ (ពីរ) ឆ្នាំ

---

[3] ក្រមរដ្ឋប្បវេណី មាត្រា៩៧៨ (១) ចំណុចខ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[4] ក្រមរដ្ឋប្បវេណី មាត្រា៩៦៦ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

ក្រោយមក សហព័ទ្ធក៏មានការឈ្លោះប្រកែកគ្នាបន្តិចបន្តួច ស្រាប់តែលោក A ជាប្ដី ចាកចោលផ្ទះ ដោយពុំត្រឡប់វិលមកផ្ទះដើម្បីរួមរស់ជាមួយលោកស្រី B វិញនោះទេ។ ក្នុងករណីនេះ លោកស្រី B អាចដាក់ពាក្យបណ្ដឹងលែងលះដោយលើកយកចំណុចនេះជាមូលហេតុបាន។

### ១.២.៣. មិនដឹងច្បាស់ថាស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំ

ការបាត់ដំណឹងសហព័ទ្ធដោយមិនដឹងថានៅរស់រានមានជីវិត ឬបានបាត់បង់ជីវិត ចាប់ពីរយៈពេល ១ (មួយ) ឆ្នាំ ឡើងទៅក៏ជាមូលហេតុនៃការលែងលះដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីផងដែរ។[5]

ឧទាហរណ៍៖ លោក A ជាប្ដី និងលោកស្រី B ជាប្រពន្ធ ដោយក្រោយពេលដែលបានរៀបអាពាហ៍ពិពាហ៍រួចមក គ្រួសារមានជីវភាពមិនសូវធូធារ លោក A ដែលត្រូវជាប្ដីក៏បានសម្រេចចិត្តចាកចេញពីផ្ទះ ដែលបានធ្វើចំណាកស្រុក ដើម្បីធ្វើការយកប្រាក់មកផ្គត់ផ្គង់នៅក្នុងគ្រួសារ។ ប៉ុន្តែលោក A បានចេញពីផ្ទះអស់រយៈពេល ៣ (បី) ឆ្នាំហើយ តែពុំដែលបានផ្ដល់ប្រាក់ដល់លោកស្រី A ដែលជាប្រពន្ធឡើយ និងមិនដែលវិលត្រលប់មកផ្ទះទេ ដោយមិនដឹងផងថា លោក A នៅរស់រានមានជីវិត ឬយ៉ាងណា។ ក្នុងករណីនេះ លោកស្រី A ដែលត្រូវជាប្រពន្ធរបស់ លោក A អាចទាមទារលែងលះដោយមូលហេតុនេះបាន។

នៅត្រង់ចំណុចនេះចង់សំដៅទៅលើសហព័ទ្ធដែលបានបែកគ្នាក្នុងព្រឹត្តិការណ៍គ្រោះថ្នាក់ ដូចជាការទៅធ្វើសង្គ្រាម លិចទូក ធ្លាក់យន្តហោះ ការចូលទៅក្នុងព្រៃជ្រៅបណ្ដាលឱ្យវង្វេងក្នុងព្រៃ ដោយភាគីអាចព្យាករណ៍ដឹងថាសហព័ទ្ធរបស់ពួកគេបានបាត់បង់ជីវិត ឬការដែលធ្វើដំណើរទៅរកស៊ីផ្លូវឆ្ងាយដោយពុំឃើញត្រឡប់មកផ្ទះវិញ។ ចំពោះសហព័ទ្ធដែលទាមទារលែងលះ ត្រូវធ្វើពាក្យបណ្ដឹងដើម្បីស្វែងរកសហព័ទ្ធដែលបានបាត់ខ្លួននោះ ក្នុងរយៈពេលមួយឆ្នាំសិន ដើម្បីឱ្យតុលាការចេញសាលក្រមរៀបប្រកាសស្វែងរកខ្លួនសហព័ទ្ធដែលបានបាត់ខ្លួន ដែលសាលក្រមនេះត្រូវបិទនៅលំនៅដ្ឋានរបស់សហព័ទ្ធដែលបាត់ខ្លួនធ្លាប់ស្នាក់នៅ និងនៅសាលាឃុំ-សង្កាត់ ដែលសហព័ទ្ធបានបាត់ខ្លួនរយៈពេល ១ (មួយ) ឆ្នាំសិន បើនៅតែគ្មានដំណឹងពីសហព័ទ្ធដែលបានបាត់ខ្លួននោះទេ ទើបតុលាការសម្រេចចេញសាលក្រមប្រកាសអំពីការបាត់ខ្លួនរបស់សហព័ទ្ធនោះ។ សាលក្រមដែលប្រកាសអំពីការបាត់ខ្លួននោះនឹងត្រូវបិទផ្សាយនៅលំនៅដ្ឋានរបស់សហព័ទ្ធដែលបានបាត់ខ្លួនក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីប្ដឹងតវ៉ា និងបើកផ្លូវឧទ្ធរណ៍ក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃផុតរយៈពេលដាក់បណ្ដឹងទាស់។ បើគ្មានការតវ៉ាពី ឬប្ដឹងឧទ្ធរណ៍ ពីសហព័ទ្ធដែលបានបាត់ខ្លួនទេ សហព័ទ្ធម្ខាងទៀតអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបាន ទោះបីសហព័ទ្ធដែលបានបាត់ខ្លួននោះត្រឡប់មកវិញក៏ដោយ ក៏មិនអាចប្ដឹងបដិសេធអាពាហ៍ពិពាហ៍នេះបានដែរ។

[5] ក្រមរដ្ឋប្បវេណី មាត្រា៩៧៨ (១) ចំណុចគ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

### ១.២.៤. រស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ឆ្នាំ

ការរស់នៅបែកគ្នាអស់រយៈពេលជាង ១ (មួយ) ឆ្នាំ ជាបន្តបន្ទាប់ក៏ជាមូលហេតុនៃការលែងលះផងដែរ ហើយការរស់នៅបែកគ្នាជាបន្តបន្ទាប់នេះ គឺសំដៅដល់សហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍រួចហើយតែពុំរស់នៅក្រោមដំបូលផ្ទះជាមួយគ្នា។[6] ចំពោះការរស់នៅបែកគ្នានេះដែរ អាចបណ្តាលមកពីភាពមិនចុះសម្រុងគ្នាពេលរស់នៅ ការឈ្លោះប្រកែកគ្នា ឬការអស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយគ្នាតទៅទៀតបាន។ ប៉ុន្តែការលែងលះដោយការរស់នៅបែកគ្នាអស់រយៈពេល ១ (មួយ) ឆ្នាំ តុលាការត្រូវពិចារណាទៅលើឆន្ទៈរបស់ភាគី ថាអាចរួមរស់ជាមួយគ្នាបន្តទៀតបានទេ ជាពិសេស គឺពិចារណាទៅលើមូលហេតុដែលនាំឱ្យមានការរស់នៅបែកគ្នា។ ក្នុងករណីសហព័ទ្ធត្រូវបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេល ១ (មួយ) ឆ្នាំ ដោយសារតែភាគីត្រូវបានបន្តបេសកកម្ម ការធ្វើការ ឬការបន្តការសិក្សា នៅឆ្ងាយពីផ្ទះ ដែលការរស់នៅបែកគ្នានេះមិនមែនបណ្តាលមកពីការឈ្លោះទាស់ទែងគ្នាទេ មិនអាចលើកជាមូលហេតុនៃការលែងលះបានទេ ព្រោះថាភាគីគ្មានឆន្ទៈក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ទេ។

ឧទាហរណ៍៖ លោក A ជាប្តី និងលោកស្រី B ជាប្រពន្ធ ក្រោយពេលដែលបានរៀបអាពាហ៍ពិពាហ៍រួចស្រាប់តែភាគីទាំងពីររស់នៅមិនចុះសម្រុងគ្នា និងមានការឈ្លោះទាស់ទែងគ្នា រហូតធ្វើឱ្យលោកស្រី B អស់មនោសញ្ចេតនា។ ក្រោយមក លោកស្រី B ក៏បានចាកចេញពីផ្ទះមករស់នៅជាមួយម្តាយបង្កើតអស់រយៈពេល ៤ (បួន) ឆ្នាំ និងមិនត្រឡប់ទៅរស់នៅជាមួយលោក A វិញឡើយ។ ក្នុងករណីនេះ លោក A អាចទាមទារលែងលះបានដោយលើកការរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ជាមូលហេតុនៃការលែងលះ។

### ១.២.៥. ករណីមិនអាចបដិទានឡើងវិញបាន

ក្រៅពីមូលហេតុដែលច្បាប់បានកំណត់ដូចមាននៅក្នុងចំណុចដែលបានរៀបរាប់ខាងលើ គឺនៅមានមូលហេតុជាច្រើនទៀតដែលច្បាប់ពុំបានកំណត់។ ដោយហេតុថា ច្បាប់បានផ្តល់នូវអំណាចឆន្ទានុសិទ្ធិដល់ចៅក្រមដែលទទួលកាន់បន្ទុកសំណុំរឿង ក្នុងការសម្រេចសេចក្តីទៅលើអង្គហេតុនៃការលែងលះ ដែលមានលក្ខណៈធ្ងន់ធ្ងរនាំឱ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍ភាគីម្ខាងទៀត និងមិនអាចបដិទានវិញបាន។ ម្យ៉ាងទៀត ច្បាប់ក៏បានផ្តល់នៅអាទិភាពនៃសិទ្ធិឱ្យភាគីប្តឹងលែងលះ ដោយមានមូលហេតុផ្ទាល់របស់ភាគី ដែលច្បាប់មិនមានកំណត់នៅក្នុងច្បាប់ដូចមាននៅក្នុងចំណុចខាងលើ។ ការដែលមិនអាចបដិទានវិញបានដែលជាមូលហេតុមួយនៃការលែងលះ ដែលមូលហេតុទាំងនោះអាចមានដូចជា៖

[6] ក្រមរដ្ឋប្បវេណី មាត្រា៩៧៨ (១) ចំណុចឃ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

- ការប្រើអំពើហិង្សាយ៉ាងធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬចំពោះបុព្វញាតិរបស់សហព័ទ្ធ៖ សំដៅទៅដល់ការវាយដំ ទាត់ធាក់ ទះតប់ ឬយកឧបករណ៍ផ្សេងៗទៅវាយធ្វើបាបទៅលើសហព័ទ្ធម្ខាងទៀត ឬញាតិរបស់សហព័ទ្ធ ដែលបណ្តាលឱ្យមាននៅស្នាមរបួសដល់រូបរាងកាយ ឬគ្រោះថ្នាក់បណ្តាលឱ្យបាត់បង់ជីវិត។ ម្យ៉ាងវិញទៀតការប្រើពាក្យជេរប្រមាថមើលងាយ ការនិយាយឆ្កឹះឆ្កៀល ចាក់រុក ដោយប្រើពាក្យបង្កាច់បង្ខូចខុសពីការពិតដែលធ្វើមានជម្លោះរវាងបុព្វញាតិរបស់សហព័ទ្ធខាងទៀត គ្មានការគោរពជីដូនជីតា ឬឪពុកម្តាយ របស់សហព័ទ្ធធ្វើប៉ះពាល់ដល់កិត្តិយសសេចក្តីថ្លៃថ្នូរ និងបណ្តាលឱ្យមានភាពអាម៉ាសមុខ ដែលចំណុចនៃការវាយដំ ឃោរឃៅធ្វើទុក្ខបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬចំពោះបុព្វញាតិរបស់សហព័ទ្ធនេះ អាចលើកជាមូលហេតុដើម្បីដាក់ពាក្យបណ្តឹងលែងលះបាន។

- មានចរិយាផ្ទុយពីសីលធម៌ ឬប្រព្រឹត្តអនាចារ៖ សំដៅដល់ការដើរហើរពេលាអាវ៉ាសែ លេងល្បែង ស្រាស្រី ឬការដើរចាយវាយបំផ្លាញទ្រព្យសម្បត្តិដែលមាននៅក្នុងគ្រួសារ ដើរបោកប្រាស់ទ្រព្យសម្បត្តិ លួចប្លន់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ដែលមិនគិតគូរដល់សុខទុក្ខរបស់គ្រួសារ និងពុំជួយរកទ្រព្យសម្បត្តិដើម្បីទុកផ្គត់ផ្គង់នៅក្នុងគ្រួសារ។

- ការប្រច័ណ្ឌ៖ ការប្រច័ណ្ឌជ្រុលហួសហេតុពេក ដោយមិនបានស្តាប់ហេតុផលដើម្បីពិចារណាឱ្យបានត្រឹមត្រូវ ដែលងាយនឹងប៉ះពាល់ដល់ការរស់នៅជាមួយគ្នា។ ព្រោះប្រសិនបើមួយថ្ងៃៗ គិតតែរករឿងគ្នា គិតតែពីខឹងគ្នា មានការសង្ស័យលើគ្នា នោះប្រាកដនាំឱ្យមានការទាស់ទែងគ្នារហូតឈានដល់ការលែងលះគ្នា។

- រៀបការក្មេងពេក ឬកង្វះចំណេះដឹង៖ សំដៅដល់សហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ដែលនៅវ័យក្មេងពេកដែលពុំទាន់មានការយល់ដឹង ចេះអត់ឱនឱ្យគ្នា គ្មានភាពអត់ធ្មត់ពេលនៅជាមួយគ្នា ជាពិសេសការរៀបអាពាហ៍ពិពាហ៍ដោយមានវ័យក្មេងពេកដែលពុំទាន់មានការងារធ្វើ សម្រាប់ចិញ្ចឹមគ្រួសារក៏មិនទាន់មានដែលជាហេតុនាំឱ្យមានការឈ្លោះប្រកែកនឹងឈានទៅដល់ការលែងលះគ្នា។

- អពលានុភាពនៃលិង្គ៖ ការរៀបអាពាហ៍ពិពាហ៍ ក្នុងគោលបំណងកសាងសុភមង្គលនៅក្នុងគ្រួសារ។ សុភមង្គលនៅក្នុងគ្រួសារមិនមែនមានតែការជួបជុំតែពីរនាក់ប្តីប្រពន្ធ ហើយប្រកបមុខរបរ ដើម្បីរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់នៅក្នុងគ្រួសារ គឺគ្រប់គ្រាន់ទេ ក្នុងសុភមង្គលនេះក៏ត្រូវមានបុត្រី បុត្រា ជាផ្នែកមួយដើម្បីរួមចំណែកផងដែល ដើម្បីឱ្យគ្រួសារកាន់តែមានសុភមង្គលពេញលេញ។ ដូច្នេះ ក្នុងករណីសហព័ទ្ធណាម្ខាងដែលពុំអាចបង្កកំណើតដើម្បីបង្កើតបាន សហព័ទ្ធម្ខាងទៀតអាចប្តឹងលែងលះ ដោយលើកមូលហេតុនៅក្នុងចំណុចនេះបាន។ យើងនឹងបន្តសិក្សាលម្អិតអំពីនីតិវិធី ក៏ដូចជាអានុភាពក្រោយពីការលែងលះ នៅជំពូកបន្ទាប់។

# ជំពូកទី២
# នីតិវិធីនៃការលែងលះ

# ជំពូកទី២

# នីតិវិធីនៃការលែងលះ

## ២.១. ការលែងលះតាមការដាក់ពាក្យសុំលែងលះ

ការលែងលះតាមការដាក់ពាក្យសុំលែងលះ ត្រូវបានធ្វើឡើងនៅពេលដែលគូភាគីទាំងពីរបានព្រមព្រៀងគ្នាក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ដោយគ្មានការឈ្លោះប្រកែកគ្នាទៅលើការទាមទារ ការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗ នៅក្រោយពេលដែលបានរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។ ការលែងលះដោយការដាក់ពាក្យសុំលែងលះ គឺស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង។[7] ដូចនេះហើយ នៅក្នុងចំណុចការលែងលះតាមការដាក់ពាក្យសុំលែងលះ ត្រូវបានសិក្សាទៅលើ (២.១.១) កិច្ចព្រមព្រៀងលែងលះ, (២.១.២) ពាក្យព្រមព្រៀងសុំលែងលះ, (២.១.៣) អាជ្ញាធរមានសមត្ថកិច្ច, (២.១.៤) នីតិវិធីនៃការជំនុំជម្រះ និង (២.១.៥) ដីកាសម្រេច។

### ២.១.១. កិច្ចព្រមព្រៀងលែងលះ

គូភាគីក្នុងចំណងអាពាហ៍ពិពាហ៍ ដែលមានបំណងចង់រំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្តឹងលែងលះ ទៅតុលាការបាន ក្នុងករណីដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នាអំពីការលែងលះ។ ប៉ុន្តែតុលាការអាចចេញដីកាសម្រេចលែងលះគ្នាបាន លុះត្រាតែយល់ឃើញថា ភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។[8] ការលែងលះត្រូវធ្វើឡើងដោយភាគីទាំងសងខាង មានឆន្ទៈពិតប្រាកដក្នុងការលែងលះ និងគ្មានការបង្ខិតបង្ខំពីភាគីម្ខាងណាឡើយ។

### ២.១.២. ពាក្យព្រមព្រៀងសុំលែងលះ

ពាក្យសុំលែងលះត្រូវធ្វើឡើងជាលាយល័ក្ខអក្សរដែលសរសេរនៅគ្រប់ចំណុចទាំងអស់ដែលគូភាគីបានព្រមព្រៀងគ្នាដែលត្រូវភ្ជាប់ជាមួយនៅឯកសារដែលជាភស្តុតាង ដើម្បីភ្ជាប់ជាមួយនិងពាក្យព្រមព្រៀងលែងលះ បន្ទាប់ពីបានរៀបចំនៅឯកសារនៃពាក្យសុំព្រមព្រៀងរួចហើយ ភាគីត្រូវយកឯកសារទៅដាក់នៅតុលាការដែលមានសមត្ថកិច្ច[9] ដើម្បីឱ្យតុលាការធ្វើការចាត់ចែងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង។ ពាក្យព្រមព្រៀងលែងលះអាចធ្វើឡើងដោយ (២.១.២.១) ពាក្យសុំជាលាយលក្ខណ៍អក្សរ និង (២.១.២.២) ពាក្យសុំដោយផ្ទាល់មាត់។

---

[7] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ១០១០, មាត្រា១ និងមាត្រា៣ ។

[8] ក្រមរដ្ឋប្បវេណី មាត្រា៩៧៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[9] ក្រមរដ្ឋប្បវេណី មាត្រា១០ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

**២.១.២.១. ពាក្យសុំជាលាយលក្ខណ៍អក្សរ**

យោងតាមបញ្ញត្តិកថាខណ្ឌទី១ និងកថាខណ្ឌទី២ មាត្រា២៦ នៃច្បាប់ស្ដីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹងឆ្នាំ២០១០ ពាក្យសុំធ្វើជាលាយលក្ខណ៍អក្សរ ដោយនៅក្នុងលិខិតនៃពាក្យសុំនេះត្រូវសរសេរបញ្ជាក់នូវចំណុចៈ

- នាមករណ៍ ឬ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ ឈ្មោះ ប្ដី ឬប្រពន្ធ ដែលបានយកពាក្យសុំលែងលះមកដាក់ត្រូវសរសេរនូវឈ្មោះ ភេទ អាយុ សញ្ជាតិ និងសរសេរនូវអាសយដ្ឋាននៅក្នុងពាក្យសុំ។ ប្រសិនបើនៅក្នុងពាក្យសុំនេះមានអ្នកតំណាងដោយអាណត្តិ ដែលច្បាប់បានកំណត់ ត្រូវសរសេរឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដោយអាណត្តិនោះចូលក្នុងពាក្យសុំផងដែរ។ ភាគី ជាចំណុចសំខាន់នៅក្នុងពាក្យសុំនេះ ដូច្នេះទាមទារឱ្យមានការបញ្ជាក់យ៉ាងច្បាស់លាស់ពីអត្តសញ្ញាណរបស់ភាគី ដើម្បីបញ្ចៀសនៅការភាន់ច្រឡំទៅលើបុគ្គលផ្សេងទៀតដែលគ្មានពាក់ព័ន្ធនិងការដាក់ពាក្យសុំ។ មូលហេតុដែលត្រូវតែបញ្ជាក់យ៉ាងច្បាស់លាស់ទៅលើអត្តសញ្ញាណនៃភាគី ដើម្បីងាយស្រួលកំណត់នៅភាគី "ដាក់ពាក្យសុំ" និង "ភាគីម្ខាងទៀត" នៃពាក្យសុំ សម្រាប់ធ្វើការបញ្ជូនឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំលែងលះ។

- ខ្លឹមសារនៃដីកាសម្រេច ឬសកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំៈ ជាកម្មវត្ថុនៃការសម្រេចសេចក្ដី និងជាការសម្រេចសេចក្ដីរបស់តុលាការទៅលើរឿងក្ដីរដ្ឋប្បវេណី ដែលការទាមទារដោយព្រមព្រៀងគ្នានេះមានដូចជា ការបែងចែកកូន ការបែងចែកទ្រព្យសម្បត្តិ អាហារកាតព្វកិច្ច និងការប្រាស្រ័យទាក់ទងកូន។

- អង្គហេតុដែលជាមូលហេតុនៃការទាមទារៈ គឺជាការសរសេរអំពីមូលហេតុនៃការទាមទាររបស់ភាគី។ ការលែងលះ គឺជាមូលហេតុនៃអង្គហេតុដែលអាចធ្វើឱ្យមានការទាមទារនៅពេលលែងលះបានពោល គឺអង្គហេតុនៃការកើតឡើងចំណងអាពាហ៍ពិពាហ៍ ដែលអាចបញ្ជាក់បានតាមសំបុត្រអាពាហ៍ពិពាហ៍ និងអង្គហេតុនៃការព្រមព្រៀងលែងលះដូចជាកិច្ចព្រមព្រៀង ឬការអះអាងរបស់ភាគី។[10]

**២.១.២.២. ពាក្យសុំដោយផ្ទាល់មាត់**

យោងតាមបញ្ញត្តិកថាខណ្ឌទី១ និងកថាខណ្ឌទី២ មាត្រា២៦ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹងឆ្នាំ២០១០ ពាក្យសុំផ្ទាល់មាត់អាចធ្វើបាននៅចំពោះមុខក្រឡាបញ្ជី។ ដោយសហព័ទ្ធទាំងសងខាងត្រូវធ្វើសេចក្ដីថ្លែងការណ៍នូវ ឈ្មោះរបស់សហព័ទ្ធ អាយុ អាសយដ្ឋាន និងអ្នកតំណាងដោយច្បាប់កំណត់ (ប្រសិនបើមាន)។ ជាពិសេសសហព័ទ្ធត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីការទាមទារ ដែលចង់ឱ្យតុលាការ

[10] ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ឆ្នាំ១០១០, មាត្រា២៦។

ចេញសេចក្តីសម្រេច និងអង្គហេតុដែលជាមូលហេតុនាំឱ្យមានការស្នើសុំលែងលះ។ ចំណែកឯក្រឡាបញ្ជីវិញត្រូវមានកាតព្វកិច្ចធ្វើនៅកំណត់ហេតុដែលសហព័ទ្ធបានធ្វើសេចក្តីថ្លែងការណ៍ និងឱ្យអ្នកដាក់ពាក្យសុំចុះហត្ថលេខាលើកំណត់ហេតុ ចំពោះកំណត់ហេតុនៃសេចក្តីថ្លែងការណ៍ត្រូវបានចាត់ទុកជាលិខិតនៃការដាក់ពាក្យសុំលែងលះ។

### ២.១.៣. អាជ្ញាធរមានសមត្ថកិច្ច

នៅក្នុងការលែងលះតាមការដាក់ពាក្យសុំ គូភាគីដែលមានបំណងចង់ស្នើសុំលែងលះ ត្រូវដាក់ពាក្យសុំលែងលះពីអាជ្ញាធរដែលមានសមត្ថកិច្ច លើការដោះស្រាយរឿងក្តីលែងលះ។ អាជ្ញាធរដែលមានសមត្ថកិច្ចមានចំនួនពីរ គឺ (២.១.៣.១) ក្រុមប្រឹក្សាឃុំ-សង្កាត់ និង (២.១.៣.៤) សាលាដំបូងរាជធានី/ខេត្ត។

#### ២.១.៣.១. ក្រុមប្រឹក្សាឃុំ-សង្កាត់

សហព័ទ្ធដែលមានបំណងចង់ដាក់ពាក្យសុំលែងលះ ជាជំហានដំបូងអាចដាក់ពាក្យសុំលែងលះ នៅក្រុមប្រឹក្សាឃុំ-សង្កាត់ នៃលំនៅដ្ឋានរបស់ភាគីខាងប្តីឬប្រពន្ធ តែនៅក្នុងដំណាក់កាលនេះក្រុមប្រឹក្សាឃុំ-សង្កាត់មិនមានសមត្ថកិច្ចអាចធ្វើការសម្រេចសេចក្តីឱ្យគូភាគីលែងលះ បែងចែកទ្រព្យសម្បត្តិ និងសិទ្ធិអំណាចមេបាលើកូន តាមការទាមទារដូចមានក្នុងពាក្យសុំលែងលះបានឡើយ ដោយហេតុថាក្រុមប្រឹក្សា ឃុំ-សង្កាត់ មានតួនាទីត្រឹមផ្សះផ្សាឱ្យគូភាគីបានត្រូវរ៉ូវ ហើយធ្វើការសះជា ដើម្បីបន្តការរួមរស់ជាប្តីប្រពន្ធសារជាថ្មី។ ប្រសិនបើគូភាគីត្រូវរ៉ូវគ្នាបន្ទាប់ពីក្រុមប្រឹក្សាឃុំ-សង្កាត់ បានធ្វើការផ្សះផ្សានោះ នាំឱ្យភាគីមានការសះជានឹងគ្នា ហើយក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវធ្វើកត់ត្រា ពីអ្វីដែលគូភាគីបានធ្វើការសះជានឹងគ្នា នោះទុកធ្វើជាកំណត់ហេតុ។ ក្នុងករណីដែលក្រុមប្រឹក្សាឃុំ-សង្កាត់ បានព្យាយាមអស់ពីសមត្ថភាពហើយតែគូភាគីនៅតែចង់លែងលះ ដោយនៅតែមិនព្រមសះជាក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនោះទេ។[11] ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបញ្ជូនពាក្យសុំលែងលះទៅតុលាការដែលមានសមត្ថកិច្ច[12] ដើម្បីបន្តនីតិវិធីតាមផ្លូវច្បាប់។

#### ២.១.៣.២. សាលាដំបូងរាជធានី/ខេត្ត

ក្នុងករណីដែលក្រុមប្រឹក្សាឃុំ-សង្កាត់ ពុំអាចធ្វើការផ្សះផ្សាបានសម្រេច ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបញ្ចូលពាក្យសុំនោះមកតុលាការទៅតាមលំនៅឋានរបស់ប្តី-ប្រពន្ធ ឬតុលាការដែលមានសមត្ថកិច្ច។[13] ដូច្នេះ តុលាការនឹងធ្វើចំណាត់ការបន្តលើពាក្យសុំនេះ ព្រោះថាមានតែតុលាការតែប៉ុណ្ណោះទើបអាចមានសិទ្ធិសម្រេចថាឱ្យគូភាគីលែងលះគ្នា ឬមិនអាចលែងលះគ្នាបានតាមការចេញដីកាសម្រេច។ ប៉ុន្តែមុនពេលដែលតុលាការធ្វើការ

---

[11] ក្រមរដ្ឋប្បវេណី មាត្រា៩៨៤ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[12] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[13] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ១០១០, មាត្រា៤។

សម្រេចសេចក្តី តុលាការត្រូវចាត់ចៅក្រមទៅតាមលេខរៀងដែលសាលាដំបូងបានកំណត់ ដើម្បីឱ្យមានចៅក្រមទទួលបន្ទុកកាន់នូវសំណុំរឿងនៃពាក្យសុំដើម្បីធ្វើនីតិវិធីជំនុំជម្រះ។

### ២.១.៤. នីតិវិធីជំនុំជម្រះ

នីតិវិធីនៃការលែងលះចាប់ផ្តើមនៅពេលដែលពាក្យសុំលែងលះ ត្រូវបានដាក់មកសាលាដំបូង បន្ទាប់មកពាក្យសុំត្រូវបានត្រួតពិនិត្យដោយក្រឡាបញ្ជីថាពាក្យសុំដែលបានដាក់មកនោះត្រឹមត្រូវតាមទម្រង់ច្បាប់កំណត់។ នៅពេលដែលតុលាការធ្វើនីតិវិធីជំនុំជម្រះនៃពាក្យសុំលែងលះ គឺត្រូវបានអនុលោមតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង មានដូចជា៖ (២.១.៤.១) ការពិនិត្យពាក្យសុំព្រមព្រៀង, (២.១.៤.២) កោះហៅគូភាគី (២.១.៤.៣) ការផ្សះផ្សានៅតុលាការ និង (២.១.៤.៤) ការទាញហេតុផលដោយផ្ទាល់មាត់ និងការសាកសួរដោយឆន្ទានុសិទ្ធិ។

#### ២.១.៤.១. ការពិនិត្យពាក្យសុំព្រមព្រៀង

នៅពេលដែលពាក្យសុំត្រូវបានដាក់មកតុលាការ ចៅក្រមដែលត្រូវបានប្រធានតុលាការចាត់តាំងឱ្យទទួលបន្ទុកត្រូវពិនិត្យមើលលើពាក្យសុំ ថាតើពាក្យសុំនេះមានសរសេរនូវចំណុចដែលចាំបាច់ត្រូវសរសេរ[14] និងបានបង់ពន្ធសម្រាប់ការដាក់ពាក្យសុំដែរឬទេ។ ក្នុងករណីដែលពាក្យសុំពុំមានសរសេរនូវភាពចាំបាច់ក្នុងពាក្យសុំ ឬពន្ធដាក់ពាក្យសុំមិនត្រូវបានបង់នោះទេ តុលាការត្រូវចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការកែតម្រូវនូវចំណុចដែលខ្វះនោះ ដោយកំណត់នូវអំឡុងពេលសមរម្យដើម្បីកែតម្រូវ[15] ប្រសិនបើពាក្យសុំមិនត្រូវបានធ្វើការកែតម្រូវតាមការកំណត់របស់តុលាការនោះទេ តុលាការត្រូវលើកចោលនូវពាក្យសុំដោយដីកាសម្រេច តែបើមិនសុខចិត្តនឹងដីកាសម្រេចនេះទេ គូភាគីនៃដាក់ពាក្យសុំអាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍បាន។

#### ២.១.៤.២. កោះហៅគូភាគី

ក្រោយពីចៅក្រមបានពិនិត្យពាក្យសុំឃើញថាពាក្យសុំត្រឹមត្រូវតាមទម្រង់រួចអស់ហើយនោះ ចៅក្រមដែលទទួលបន្ទុកកាន់រឿងត្រូវចាត់ក្រឡាបញ្ជី ដើម្បីធ្វើការចុះលេខសំណុំរឿង និងកំណត់កាលបរិច្ឆេទដើម្បីកោះហៅគូភាគី និងបុគ្គលដែលពាក់ព័ន្ធ ឱ្យចូលមកតុលាការតាមកាលបរិច្ឆេទដើម្បីដំណើរការនីតិវិធីនៃការលែងលះ។ ដូចនេះ គូភាគី និងបុគ្គលដែលពាក់ព័ន្ធ មានករណីយកិច្ចចូលបង្ហាញខ្លួន តាមរយៈដីកាកោះនៅក្នុងតុលាការតាមកាលបរិច្ឆេទដែលក្រឡាបញ្ជីបានកំណត់។ មូលហេតុដែលតុលាការកោះហៅគូភាគី និងបុគ្គលដែលពាក់ព័ន្ធ ឱ្យចូលបង្ហាញខ្លួនក្នុងតុលាការ គឺដើម្បីឱ្យភាគីចូលមកបំភ្លឺអំពីអង្គហេតុឱ្យកាន់តែច្បាស់លាស់ និងព័ត៌មាន

[14] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៦៥ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[15] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៨ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

ផ្សេងៗទៀត មកកាន់តុលាការតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ។ ក្នុងករណីដែលគូភាគីមានអ្នកតំណាងដោយអាណត្តិ នោះគូភាគីពុំចាំបាច់ចូលបង្ហាញខ្លួនក្នុងតុលាការក៏បានដែរ បើតុលាការយល់ថាពុំចាំបាច់ត្រូវមានភាគីមកបំភ្លឺនៅអង្គហេតុបន្ថែម ប៉ុន្តែប្រសិនបើតុលាការយល់ឃើញថាមានភាពចាំបាច់គូភាគីត្រូវចូលបង្ហាញខ្លួននោះ គូភាគីត្រូវចូលបង្ហាញខ្លួននៅក្នុងតុលាការជាដាច់ខាត អ្នកតំណាងដោយអាណត្តិនៅតែមានអាចចូលរួមជាមួយគូភាគីបានដែរ។ យោងតាមកថាខណ្ឌ២ មាត្រា២៩ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹងឆ្នាំ២០១០ ក្នុងករណីដែលជនត្រូវបានកោះហៅដោយតុលាការ ជាអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀតនៃ មិនបានចូលបង្ហាញខ្លួនក្នុងតុលាការដោយគ្មានមូលហេតុត្រឹមត្រូវនោះទេ តុលាការអាចពិន័យជាប្រាក់មិនលើសពី ១,០០០,០០០ (មួយលាន) រៀល បាន ទោះបីជាការកោះហៅចូលបង្ហាញខ្លួនជាករណីយកិច្ចក៏ដោយ។

### ២.១.៤.៣. ការផ្សះផ្សានៅតុលាការ

នៅពេលដែលភាគីទាំងពីរនៃពាក្យសុំលែងលះបានចូលមកតុលាការ ដើម្បីចូលរួមនីតិវិធីដែលត្រូវបានកោះហៅដោយចៅក្រមទទួលបន្ទុកលើសំណុំរឿង គឺចៅក្រមមានករណីយកិច្ចធ្វើការផ្សះផ្សាភាគីទាំងពីរបាន មុនពេលពេលសម្រេចសេចក្តី បើទោះបីជាក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្លាប់បានសាកល្បងធ្វើការផ្សះផ្សារួចហើយក៏ដោយ បើតុលាការយល់ឃើញថាការលែងលះរបស់ភាគីនេះអាចនឹងប៉ះពាល់ដល់ប្រយោជន៍កូនៗរបស់ពួកគេ ឬតុលាការយល់ឃើញថាគូភាគីនៅមានមនោសញ្ចេតនាជាមួយគ្នានៅឡើយ ដែលអាចរួមរស់ជាមួយគ្នាឡើងវិញបាន។ ការផ្សះផ្សាគូភាគីរបស់តុលាការក្នុងបំណងចង់ឱ្យគូភាគីសះជាជាមួយគ្នាឡើងវិញ និងដកពាក្យសុំលែងលះដើម្បីផ្សះផ្សាគូភាគីឱ្យមានចំណងអាពាហ៍ពិពាហ៍ឡើងវិញ។ ក្នុងករណីដែលគូភាគីនៅតែទទូចទាមទារសុំលែងលះដោយតុលាការយល់ថាមិនអាចធ្វើការផ្សះផ្សាវិញបាននោះទេ តុលាការនឹងបន្តនីតិវិធីនៃពាក្យសុំលែងលះតាមនីតិវិធីច្បាប់។

### ២.១.៤.៤. ការទាញហេតុផលដោយផ្ទាល់មាត់ និងការសាកសួរដោយឆន្ទានុសិទ្ធិ

បន្ទាប់ពីតុលាការធ្វើការផ្សះផ្សាគូភាគីមិនបានសម្រេចហើយ តុលាការត្រូវកោះហៅភាគីដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬចេញសេចក្តីសម្រេចដោយពុំចាំបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ បើយោងតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង។[16] ការដាក់ពាក្យសុំលែងលះ គឺជាការដាក់ពាក្យសុំលែងលះដោយគូភាគីបានព្រមព្រៀងគ្នាលែងលះដោយមានការទាមទារដូចគ្នាដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍ដែលគូភាគីមានឆន្ទៈដូចគ្នាដែលជាហេតុធ្វើឱ្យរឿងនេះមិនមានការទាមទារមានខ្វែងគំនិតគ្នាដូចជាការដាក់

[16] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ១០១០, មាត្រា២៨។

ពាក្យបណ្តឹងលែងលះ ទើបតុលាការពុំចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រម ដែលអាចសម្រេចថា គួរធ្វើនីតិវិធីក្នុងការទាញហេតុផលផ្ទាល់មាត់ ឬពុំចាំបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់។ ក្នុងករណីដែលតុលាការយល់ថាចាំបាច់ តុលាការមានសិទ្ធិសាកសួរអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត ឬបុគ្គលដែលតុលាការយល់ថាពាក់ព័ន្ធដោយឆន្ទានុសិទ្ធិ ដូច្នេះតុលាការមានសិទ្ធិអំណាចក្នុងការស្រាវជ្រាវលើអង្គហេតុ និងត្រួតពិនិត្យលើភស្តុតាងផ្សេងៗដែលបានដាក់មកតុលាការដោយឆន្ទានុសិទ្ធិ។

### ២.១.៥. ដីកាសម្រេច

ក្រោយពេលដែលតុលាការបានពិនិត្យទៅលើឯកសារ ភស្តុតាង និងបានធ្វើនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ហើយនោះ គឺតុលាការត្រូវតែចេញសេចក្តីសម្រេចលើពាក្យសុំលែងលះដោយការព្រមព្រៀងរបស់ភាគី ដែលការដាក់ពាក្យសុំលែងលះជារឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ជាគោលការណ៍សេចក្តីសម្រេចនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវហត្ថលេខាលើសេចក្តីសម្រេចនេះផងដែរ។[17] ដីកាសម្រេចនេះតុលាការត្រូវបញ្ជូនទៅឱ្យគូភាគីដែលត្រូវទទួលនូវដីកាសម្រេចនេះ ការបញ្ជូនដំណឹងអំពីការសម្រេចនេះត្រូវធ្វើឡើងតាមរយៈការបញ្ជូន និងការផ្ញើរឯកសារចម្លងយថាភូតនៃដីកាសម្រេចនេះ។[18] ចំពោះដីកាសម្រេចនេះ គឺមានអានុភាពដូចសាលក្រមលែងលះដែរ។ ដីកាសម្រេចមានអានុភាពបន្ទាប់ពីចូលជាស្ថាពរ។ ការចូលជាស្ថាពរនៃដីកាសម្រេច គឺមានរយៈពេល ២ (ពីរ) សប្តាហ៍ ដែលគិតចាប់ពីដីកាសម្រេចនោះបានបញ្ជូនទៅគូភាគី ហើយពុំមានការបណ្តឹងជំទាស់ពីភាគីណាទេនោះ។ ក្នុងករណីដែលមានភាគី ពុំសុខចិត្តនឹងដីកាសម្រេចរបស់តុលាការទេនោះ ភាគីអាចប្តឹងជំទាស់លើដីកាសម្រេចរបស់តុលាការនេះបាន ដែលមានរយៈពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលនៅការជូនដំណឹងនេះ ភាគីដែលមានបំណងប្តឹងជំទាស់តែខកខានពុំបានធ្វើការដាក់ពាក្យបណ្តឹង មិនអាចស្នើសុំឱ្យតុលាការធ្វើការពន្យារពេលបានឡើយ ប៉ុន្តែបើការខកខាននៅការដាក់ប្តឹងជំទាស់នេះមិនមែនជាកំហុសរបស់ភាគីទេ តុលាការផ្តល់ឱកាសឱ្យដាក់ពាក្យបណ្តឹងក្នុងអំឡុងរយៈពេល ១ (មួយ) សប្តាហ៍ ទើបការប្តឹងជំទាស់នោះមិនអាចស្នើសុំបាន។ ចំពោះការជំនុំជម្រះនៃប្តឹងជំទាស់ គឺតុលាការធ្វើនីតិវិធីដូចគ្នាទៅនឹងប្តឹងជំទាស់ដូចមាននៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែរ។[19] ចំពោះមូលហេតុដែលនាំឱ្យមានការប្តឹងជំទាស់ក្នុងរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹង គឺមិនដូចនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីទេ ព្រោះថាភាគីពុំបានព្រមព្រៀងគ្នាលើសេចក្តីសម្រេចរបស់តុលាការ ឬ

---

[17] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៨ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[18] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៣៦ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[19] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ១០១០, មាត្រា៤៨។

ការចេញសេចក្តីសម្រេចរបស់តុលាការពុំមានខ្លឹមសារដូចទៅនឹងពាក្យសុំព្រមព្រៀងដែលគូភាគីបានធ្វើការព្រមព្រៀង។ ដូច្នេះ ការបណ្តឹងជំទាស់របស់ភាគី គឺត្រូវបានបន្តនីតិវិធីនៅតុលាការជាន់ខ្ពស់ (សាលាឧទ្ធរណ៍)។

## ២.២. ការលែងលះតាមការដាក់ពាក្យបណ្តឹងលែងលះ

ការដាក់ពាក្យបណ្តឹងលែងលះ ត្រូវបានធ្វើឡើងដោយភាគីម្ខាងនៃចំណងអាពាហ៍ពិពាហ៍ដែលបានមានបំណងចង់រំលាយនូវចំណងអាពាហ៍ពិពាហ៍ ដោយពុំមានការព្រមព្រៀងពីភាគីម្ខាងនៃទៀត។ ការដាក់ពាក្យបណ្តឹងលែងលះ គឺស្ថិតនៅក្រោមវិសាលភាពច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។[20] ចំពោះនីតិវិធីនៃការដាក់ពាក្យបណ្តឹងលែងលះ គឺមានលក្ខណៈស្មុគស្មាញជាងការដាក់ពាក្យសុំលែងលះ ដោយហេតុថាភាគីទាំងពីរពុំមានការព្រមព្រៀងគ្នាទៅលើការទាមទារ ដូច្នេះមុននឹងតុលាការធ្វើការសម្រេចសេចក្តីក្នុងរឿងបណ្តឹងលែងលះ តុលាការត្រូវធ្វើនីតិវិធីច្រើនជាងពាក្យសុំលែងលះ។ អាស្រ័យហេតុនេះ នៅក្នុងនីតិវិធីការដាក់ពាក្យបណ្តឹងលែងលះ និងធ្វើការសិក្សាទៅលើ (២.២.១) ពាក្យបណ្តឹងលែងលះ, (២.២.២) អាជ្ញាធរមានសមត្ថកិច្ច (២.២.៣) នីតិវិធីនៃការជំនុំជម្រះ និង (២.២.៤) ការសម្រេចសេចក្តី។

### ២.២.១. ពាក្យបណ្តឹងលែងលះ

ការដាក់ពាក្យបណ្តឹងលែងលះ ត្រូវបានធ្វើឡើងដោយភាគីម្ខាងនៃចំណងអាពាហ៍ពិពាហ៍ដែលអស់មនោសញ្ចេតនា ឬពុំអាចរួមរស់ជាមួយនឹងគ្នាបន្តទៅទៀតបានទើបសម្រេចដាក់ពាក្យបណ្តឹងលែងលះដើម្បីរំលាយនូវចំណងអាពាហ៍ពិពាហ៍។ ការដាក់ពាក្យបណ្តឹងលែងលះ គឺជាបណ្តឹងដែលភាគីពុំមានការព្រមព្រៀងទៅលើការទាមទារ ការបែងចែក និងកាតព្វកិច្ចផ្សេងៗ ដូចដាក់ពាក្យសុំលែងលះ ទើបបណ្តាលឱ្យការដាក់ពាក្យបណ្តឹងលែងលះមានភាពស្មុគស្មាញ ព្រោះភាគីមានទំនាស់ទៅលើការទាមទារ ដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍។ មូលហេតុដែលនាំឱ្យមានការកើតមាននូវការដាក់ពាក្យបណ្តឹងលែងលះ គឺដោយសារតែសហព័ទ្ធពុំបានបំពេញនូវតម្រូវការឱ្យគ្នាទៅវិញទៅមកដូចជាការចូលរួមចំណែកនៅក្នុងការជួយធ្វើនូវកិច្ចការផ្ទះ ការខិតខំប្រឹងប្រែងរកប្រាក់ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ និងការមើលថែគ្នាទៅវិញទៅមកជាដើម។ មូលហេតុដែលអាចធ្វើឱ្យតុលាការយល់ព្រមទទួលយកនូវពាក្យបណ្តឹងលែងលះ មកធ្វើនីតិវិធី និងសម្រេចសេចក្តីបាន លុះត្រាតែពាក្យបណ្តឹងលែងលះនេះមានភ្ជាប់មកជាមួយនូវមូលហេតុដែលត្រឹមត្រូវ ឬមានចែងនៅក្នុងក្រមរដ្ឋប្បវេណី[21] ដូចដែលបានរៀបរាប់នៅក្នុង ជំពូកទី១ អំពីមូលហេតុនៃការលែងលះ។ ម្យ៉ាងវិញទៀតបណ្តឹងលែងលះ ត្រូវបានតុលាការធ្វើការដោះស្រាយតាមក្រមនីតិវិធីរដ្ឋប្បវេណី (ដូចពាក្យបណ្តឹងទូទៅ) ដែលខុសពីការដាក់ពាក្យសុំលែងលះ ដែលត្រូវបានតុលាការធ្វើការដោះស្រាយតាមច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ព្រោះថា

[20] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០, មាត្រា៣ កថាខណ្ឌ៣ ។

[21] ក្រមរដ្ឋប្បវេណី មាត្រា៩៧៨ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

បណ្ដឹងលែងលះភាគីមានការខ្វែងគំនិតគ្នា ទៅលើការពិភាក្សាអំពីការបែងចែកកម្មវត្ថុទាំងនោះ ដែលអាចមានភាគីម្ខាងយល់ព្រម និងភាគីម្ខាងទៀតមិនយល់ព្រម។

**២.២.១.១. ចំណុចដែលត្រូវសរសេរ**

ការលែងលះតាមការដាក់ពាក្យបណ្ដឹងលែងលះ គឺតម្រូវឱ្យដើមចោទធ្វើឡើងជាលាយលក្ខណ៍អក្សរទៅតុលាការ និងសរសេរពាក្យបណ្ដឹងដូចមានចែងនៅក្នុងមាត្រា៧៥ នៃក្រមរដ្ឋប្បវេណី។[22] នៅក្នុងពាក្យបណ្ដឹងការដាក់ពាក្យបណ្ដឹងលែងលះ ត្រូវតែបញ្ជាក់ឱ្យច្បាស់អំពីខ្លឹមសារនៃការទាមទារ ដែលដើមចោទចង់ឱ្យតុលាការចេញនូវសាលក្រមលើការទាមទារនោះ ព្រោះថានៅក្នុងរឿងក្ដីរដ្ឋប្បវេណី តុលាការនឹងធ្វើការជំនុំជម្រះទៅលើតែការទាមទាររបស់ដើមចោទដូចដែលបានសរសេរនៅក្នុងពាក្យបណ្ដឹងតែប៉ុណ្ណោះ។[23] ម្យ៉ាងទៀត ដើមចោទត្រូវតែសរសេរបញ្ជាក់ឱ្យច្បាស់នូវអង្គហេតុដែលជាមូលហេតុនាំឱ្យមានការទាមទារ ដែលជាហេតុបណ្ដាលឱ្យមានការដាក់ពាក្យបណ្ដឹងលែងលះ។ ដើម្បីបញ្ជាក់ថាអង្គហេតុដែលបានសរសេរនៅក្នុងពាក្យបណ្ដឹងឱ្យកាន់តែច្បាស់បន្ថែមទៀតនោះ ដើមចោទត្រូវមានឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធភ្ជាប់មកជាមួយផងដែរ ដើម្បីដាក់ជូនតុលាការជាភស្តុតាង។ ចំពោះការសរសេរពាក្យបណ្ដឹង ដែលដាក់ជូនសាលាដំបូងរាជធានី-ខេត្ត សហព័ទ្ធដែលជាអ្នកដាក់ពាក្យបណ្ដឹងលែងលះ ត្រូវបានតុលាការកំណត់ឱ្យហៅថា "ដើមចោទ" ចំពោះភាគីម្ខាងទៀតដែលត្រូវបានគេដាក់ពាក្យបណ្ដឹងលែងលះ ត្រូវបានតុលាការកំណត់ឱ្យហៅថា "ចុងចម្លើយ"។[24] ពាក្យបណ្ដឹងដែលត្រូវបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានកំណត់ ពាក្យបណ្ដឹងនេះនឹងមានអានុភាព និងមិនត្រូវបានលុបចោលឡើយ។

**២.២.១.២. របៀបដាក់ពាក្យបណ្ដឹង**

ជាបឋម ដើមចោទអាចដាក់ពាក្យបណ្ដឹងទៅក្រុមប្រឹក្សាឃុំ-សង្កាត់។ ក្រុមប្រឹក្សាឃុំ-សង្កាត់ អាចធ្វើការបញ្ចុះបញ្ចូលឱ្យភាគីទាំងពីរសះជាគ្នាបានក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ ប្រសិនបើពុំអាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជាបានទេ ត្រូវចាត់ទុកថាមានពាក្យបណ្ដឹងលែងលះគ្នា ហើយក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបញ្ជូនពាក្យបណ្ដឹងនោះ ទៅតុលាការជាបន្ទាន់ដើម្បីបន្តនីតិវិធីនៃការលែងលះដោយការដាក់ពាក្យបណ្ដឹង។ ម្យ៉ាងទៀត ដើមចោទអាចដាក់ពាក្យបណ្ដឹងលែងលះទៅសាលាដំបូងរាជធានី-ខេត្ត ដែលមានសមត្ថកិច្ចលើរឿងក្ដីរបស់ខ្លួនឯង ដោយមិនចាំបាច់មានការដាក់ពាក្យបណ្ដឹងលែងលះទៅក្រុមប្រឹក្សាឃុំ-សង្កាត់ឡើយ។

---

[22] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៥ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[23] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨២ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[24] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៣២ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

### ២.២.២. អាជ្ញាធរមានសមត្ថកិច្ច

នៅក្នុងនីតិវិធីនៃការលែងលះតាមការដាក់ពាក្យបណ្ដឹងលែងលះ ភាគីដែលបានដាក់ពាក្យបណ្ដឹងលែងលះច្រើនតែដាក់ពាក្យបណ្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើចំណាត់ការនៅលើពាក្យបណ្ដឹងលែងលះ។ ដែលអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើចំណាត់ការដោះស្រាយលើពាក្យបណ្ដឹងលែងលះនេះ មាន (២.២.២.១) ក្រុមប្រឹក្សាឃុំ-សង្កាត់ និង (២.២.២.១) សាលាដំបូងរាជធានី /ខេត្ត។

#### ២.២.២.១.ក្រុមប្រឹក្សាឃុំ-សង្កាត់

ភាគីដែលមានបំណងដាក់ពាក្យបណ្ដឹងលែងលះ ត្រូវដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការដែលមានសមត្ថកិច្ច ហើយភាគីក៏អាចដាក់ពាក្យបណ្ដឹងលែងលះទៅក្រុមប្រឹក្សាឃុំ-សង្កាត់បានផងដែរ។[25] ប៉ុន្តែក្រុមប្រឹក្សាឃុំ-សង្កាត់គ្មានសមត្ថកិច្ចក្នុងការសម្រេចអំពីការលែងលះទេ គឺក្រុមប្រឹក្សាឃុំ-សង្កាត់ គ្រាន់តែធ្វើការបញ្ចុះបញ្ចូលឱ្យភាគីទាំងសងខាងសះជាតែប៉ុណ្ណោះ។ នៅពេលដែលក្រុមប្រឹក្សាឃុំ-សង្កាត់ ទទួលបាននៅពាក្យបណ្ដឹងលែងលះ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវគោរពតួនាទីចម្បង នៅក្នុងការផ្សះផ្សាដើម្បីឱ្យដើមចោទ និងចុងចម្លើយសះជានឹងគ្នាវិញ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ មានរយៈពេលតែ ១៥ (ដប់ប្រាំ) ថ្ងៃ តែប៉ុណ្ណោះ ដើម្បីធ្វើការផ្សះផ្សារឱ្យត្រូវរ៉ូវគ្នាវិញ បើផុតរយៈពេលដែលបានកំណត់នេះភាគីទាំងសងខាងនូវតែមិនព្រមសះជាវិញទេ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបញ្ជូនពាក្យបណ្ដឹងលែងលះនេះទៅកាន់តុលាការ ដើម្បីចាត់នីតិវិធីក្នុងការបន្តនីតិវិធីស្របតាមច្បាប់។ ក្នុងករណីដែលក្រុមប្រឹក្សាឃុំ-សង្កាត់ បានធ្វើឱ្យភាគីអាចផ្សះផ្សាបានសម្រេច ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើកំណត់ហេតុ និងកិច្ចសន្យាសះជាដល់ភាគីទាំងពីរផងដែរ។

#### ២.២.២.២. សាលាដំបូងរាជធានី /ខេត្ត

ជាធម្មតា ដើមចោទនៃរឿងក្ដីលែងលះត្រូវដាក់ពាក្យបណ្ដឹងលែងលះ ទៅតុលាការដែលមានសមត្ថកិច្ចផ្ដាច់មុខ របស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្ដឹង ឬលំនៅឋានរបស់ចុងចម្លើយ។[26] ការកំណត់សមត្ថកិច្ចផ្ដាច់មុខលើរឿងក្ដីលែងលះនេះ ដើម្បីឱ្យការដោះស្រាយលើរឿងក្ដីនេះ ដំណើរការបានងាយស្រួល ក្នុងការស្វែងយល់នៃស្ថានភាព នៃរឿងក្ដីឱ្យបានត្រឹមត្រូវជាពិសេសចំណេញពេលវេលាដល់គូភាគីនៃរឿងក្ដីលែងលះថែមទៀតផង។

### ២.២.៣. នីតិវិធីនៃការជំនុំជម្រះ

នៅក្នុងនីតិវិធីរឿងក្ដីរដ្ឋប្បវេណី តុលាការអាចបើកការជំនុំជម្រះរឿងក្ដីនោះបាន លុះត្រាតែពាក្យបណ្ដឹងដែលដើមចោទបានដាក់មកតុលាការនោះ ត្រឹមត្រូវតាមច្បាប់បានកំណត់។ ក្រោយពេលដែលពាក្យបណ្ដឹងបាន

[25] ក្រមរដ្ឋប្បវេណី មាត្រា៩៨២ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[26] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

ដាក់មកតុលាការហើយនោះ នីតិវិធីនៃការជំនុំជម្រះនឹងចាប់ផ្តើមដំណើរការ ដោយអនុលោមតាមច្បាប់នីតិវិធីរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។[27] ដូចនេះ នីតិវិធីនៃការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណីនៃបណ្តឹងលែងលះដោយការដាក់ពាក្យបណ្តឹង មានដូចជា៖ (២.២.៣.១) ការពិនិត្យពាក្យបណ្តឹង (២.២.៣.២) ការបញ្ជូនពាក្យបណ្តឹង (២.២.៣.៣) ការផ្សះផ្សាគូរភាគី (២.២.៣.៤) នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង (២.២.៣.៥) នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។

### ២.២.៣.១. ការពិនិត្យពាក្យបណ្តឹង

នៅពេលដែលពាក្យបណ្តឹងលែងលះត្រូវបានដើមចោទដាក់មកសាលាដំបូង ក្រឡាបញ្ជីមានកាតព្វកិច្ចត្រូវត្រួតពិនិត្យមើលលើបណ្តឹងនោះភ្លាមៗ ដោយសារតែតុលាការអាចធ្វើនីតិវិធីជំនុំជម្រះលើពាក្យបណ្តឹងបានតែលើពាក្យបណ្តឹងដែលត្រឹមត្រូវតាមច្បាប់កំណត់តែប៉ុណ្ណោះ។ នីតិវិធីនៃការពិនិត្យពាក្យបណ្តឹងនេះ គឺការទទួលយកនៅពាក្យបណ្តឹងបើត្រឹមត្រូវតាមច្បាប់កំណត់  និងការជូនដំណឹងទៅចៅក្រមដែលទទួលកាន់បន្ទុកនៅសំណុំរឿង ប្រសិនបើពាក្យបណ្តឹងដែលដើមចោទបានដាក់មកតុលាការនោះមានភាពខុសឆ្គង ដើម្បីឱ្យចៅក្រមជាអ្នកសម្រេចថាកែតម្រូវ ឬលើកចោលនៅពាក្យបណ្តឹង និងបង្គាប់ឱ្យបន្ថែមទៅលើពាក្យបណ្តឹង ឬផ្លាស់ប្តូរកម្មវត្ថុនៃពាក្យបណ្តឹងនោះជាដើម។

#### ក. ការទទួលយកពាក្យបណ្តឹងតាមផ្លូវច្បាប់

នៅពេលដែលក្រឡាបញ្ជីបានទទួលនូវពាក្យបណ្តឹង ក្រឡាបញ្ជីត្រូវមានកាតព្វកិច្ចពិនិត្យទៅលើពាក្យបណ្តឹងនេះ។ ក្នុងពាក្យបណ្តឹងត្រូវតែសរសេរនូវចំណុចដែលចាំបាច់ត្រូវសរសេរ ដែលមានលក្ខណៈត្រឹមត្រូវតាមការកំណត់ដូចមានក្នុងមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ បន្ទាប់ពីក្រឡាបញ្ជីបានពិនិត្យឃើញថាពាក្យបណ្តឹងបានសរសេរត្រឹមត្រូវតាមច្បាប់កំណត់ហើយ  និងបានបង់ពន្ធសម្រាប់ការដាក់ពាក្យបណ្តឹងតាមការកំណត់រួចហើយ ក្រឡាបញ្ជីត្រូវយកបណ្តឹងនោះ ដើម្បីធ្វើការចុះលេខលើសំណុំរឿង និងបញ្ជូនឱ្យចៅក្រម ដើម្បីរៀបចំបន្តនីតិវិធី។ ពាក្យបណ្តឹងលែងលះ  គឺមានការទាមទារទៅលើការបែងចែកទ្រព្យសម្បត្តិ ការកំណត់អំណាចមេបា ក្នុងករណីនេះបើទាមទារសំណងផ្សេងៗទៀតដែលពាក់ព័ន្ធនឹងអង្គហេតុនៃការលែងលះ នាំឱ្យបណ្តឹងទាមទារទាំងនោះអាចធ្វើការបញ្ចូលគ្នានៅក្នុងបណ្តឹងទាមទារលែងលះតែមួយបាន។[28]

#### ខ. ការបន្ថែម ឬផ្លាស់ប្តូរនូវកម្មវត្ថុនៃពាក្យបណ្តឹង

ទោះបីដើមចោទបានដាក់ពាក្យបណ្តឹងលែងលះមកតុលាការរួចហើយក៏ដោយ  ដើមចោទនៅតែអាចធ្វើការកែប្រែ បន្ថែម និងផ្លាស់ប្តូរទៅលើពាក្យបណ្តឹង នៅក្នុងនីតិវិធីរហូតដល់ចប់ការទាញហេតុផលដោយផ្ទាល់មាត់

[27] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០, មាត្រា៣ (គ)។

[28] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៧ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

នៃការជំនុំជម្រះលើកទី១ ឬការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍បាន។[29] ក្នុងករណីនេះអាចធ្វើការបន្ថែម ឬការផ្លាស់ប្តូរបានលុះត្រាតែមិនធ្វើឱ្យនីតិវិធីនៃបណ្តឹងមានការយឺតយ៉ាវខ្លាំង ឬរាំងស្ទះដល់ដំណើរការនីតិវិធីរបស់តុលាការ ចំពោះការធ្វើការបន្ថែម ឬផ្លាស់ប្តូរនូវពាក្យបណ្តឹងនេះផងដែរ ដើមចោទត្រូវធ្វើជាលាយលក្ខណ៍អក្សរ។[30] តុលាការនៅតែពិនិត្យទៅលើការបន្ថែម ឬផ្លាស់ប្តូរនូវពាក្យបណ្តឹង បើតុលាការយល់ឃើញថា ការបន្ថែម ឬការផ្លាស់ប្តូរនូវកម្មវត្ថុនៃពាក្យបណ្តឹង មិនត្រឹមត្រូវទេ តុលាការត្រូវចេញដីកាសម្រេចមិនយល់ព្រមនឹងការបន្ថែម ឬការផ្លាស់ប្តូរនោះតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន។[31]

**គ. ការលើកចោលពាក្យបណ្តឹង**

ពាក្យបណ្តឹងដែលបានដាក់មកតុលាការមិនសុទ្ធតែត្រឹមត្រូវតាមទម្រង់ដែលច្បាប់បានកំណត់ទាំងអស់នោះទេ ទើបបណ្តាលឱ្យមានការពិនិត្យរាល់ពាក្យបណ្តឹងដែលដើមចោទបានដាក់មកតុលាការ។ កាលបើក្រឡាបញ្ជីបានពិនិត្យឃើញថា ពាក្យបណ្តឹងមានភាពខ្វះខាតពុំទាន់មានភាពត្រឹមត្រូវតាមទម្រង់ច្បាប់កំណត់ អង្គហេតុនៃពាក្យបណ្តឹងមិនច្បាស់លាស់ កម្មវត្ថុដែលទាមទារមិនពាក់ព័ន្ធជាមួយនឹងអង្គហេតុ ពុំមានភស្តុតាងដើម្បីបញ្ជាក់នៃការទាមទារ ឬពុំទាន់បានបង់ពន្ធតាមការកំណត់ ក្រឡាបញ្ជីត្រូវជូនដំណឹងអំពីសំណុំរឿងនេះទៅចៅក្រមដែលទទួលកាន់បន្ទុកនៅសំណុំរឿង ដើម្បីឱ្យចៅក្រមពិចារណាបង្គាប់ឱ្យដើមចោទកែតម្រូវនៅពាក្យបណ្តឹងដោយកំណត់អំឡុងពេលសមរម្យ។[32] ក្នុងករណីដែលពិនិត្យឃើញថា ពាក្យបណ្តឹងមានលក្ខណៈផ្ទុយច្បាប់ មានភាពខ្វះខាតយ៉ាងធ្ងន់ធ្ងរដែលមិនអាចកែតម្រូវបាន និងមិនបានធ្វើការកែតម្រូវតាមការបង្គាប់របស់ចៅក្រមនោះទេ ចៅក្រមមានសិទ្ធិក្នុងការលើកបណ្តឹងចោលតែម្តងតាមរយៈការចេញនៅដីកាសម្រេច។[33] ប្រសិនបើមានការមិនពេញចិត្តនឹងដីកាសម្រេចនេះទេ ដើមចោទអាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍បាន។[34]

**២.២.៣.២. កោះហៅគូភាគី**

បន្ទាប់ពីបានឆ្លងកាត់ដំណាក់កាលដាក់ពាក្យបណ្តឹង ត្រូវបានបំពេញរួចរាល់ និងត្រឹមត្រូវរួចហើយនោះ តុលាការត្រូវធ្វើចំណាត់ការលើនីតិវិធីបន្ត។ តុលាការត្រូវកំណត់កាលបរិច្ឆេទ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ លើកលែងតែក្នុង

[29] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០, មាត្រា១២។

[30] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៨៤ (១) និង(២) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[31] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៨៤ (៤) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[32] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៨ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[33] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៨ (២) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[34] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៨ (៣) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

ករណីដែលមានមូលហេតុពិសេស។[35] ដូចនេះតុលាការត្រូវធ្វើការកោះហៅគូភាគី និងបុគ្គលដែលពាក់ព័ន្ធទាំងឡាយឱ្យចូលមកបំភ្លឺនូវតុលាការ។ មូលហេតុដែលនាំឱ្យមានកោះហៅគូភាគី គឺគោរពតាមការគោលការណ៍ចំពោះមុខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានបញ្ញត្តិថា ភាគីណាក៏មិនអាចត្រូវបានជម្រះក្តី ដោយមិនបានសាកសួរ ឬកោះហៅឡើយ។[36] ការកោះហៅគូភាគី គឺដើម្បីឱ្យភាគីមានឱកាសចូលមកបំភ្លឺនូវឱ្យកាន់តែច្បាស់អំពីអង្គហេតុ កម្មវត្ថុ ការទាមទារ និងចំណុចវិវាទដែលបណ្តាលឱ្យការដាក់ពាក្យបណ្តឹងលែងលះ។ ចំពោះដីកាកោះដែលត្រូវកោះហៅគូភាគី គឺមានចំនួន ២(ពីរ) សន្លឹក ដែលមានមួយសន្លឹកហៅថា "ដីកាកោះដើម" និងមួយសន្លឹកទៀតហៅថា "ចុងដីកា"។ អ្នកដែលយកដីកាប្រគល់ជូនគូភាគី គឺត្រូវយកដីកានេះឱ្យភាគីនៃរឿងដោយផ្ទាល់ ហើយអ្នកទទួលត្រូវចុះហត្ថលេខា កាលបរិច្ឆេទទទួល និងស្នាមមេដៃនៅលើក្រដាសដីកាទាំងពីរ។ អ្នកប្រគល់ដីកាត្រូវប្រគល់ចុងដីកាឱ្យទៅអ្នកទទួលមួយសន្លឹក និងដីកាដើម ទុកជូនទៅតុលាការវិញឱ្យបានមុនថ្ងៃដែលតុលាការបានកំណត់។

### ២.២.៣.៣. ការផ្សះផ្សាគូភាគី

ការផ្សះផ្សា គឺជាការសម្របសម្រួល ដោយមានការចូលរួមអន្តរាគមន៍ពីមន្ត្រីមានសមត្ថកិច្ច ដើម្បីធ្វើយ៉ាងណាឱ្យភាគីដើមចោទ និងចុងចម្លើយនៃបណ្តឹងលែងលះ យល់ព្រមសះជានឹងគ្នាវិញ ហើយយល់ព្រមបញ្ឈប់ការប្តឹងទាមទារសាលក្រមលែងលះពីតុលាការបន្តទៀត។ ប្រសិនបើដើមចោទធ្លាប់បានដាក់ពាក្យបណ្តឹងលែងលះនេះទៅក្រុមប្រឹក្សាឃុំ-សង្កាត់ នោះប្រាកដជាធ្លាប់បានធ្វើការផ្សះផ្សាភាគីទាំងពីរ ដែលមានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃមុននឹងក្រុមប្រឹក្សាឃុំ-សង្កាត់ សម្រេចបញ្ជូនបន្តមកតុលាការដើម្បីធ្វើការដោះស្រាយ។[37] ទោះបីជាការផ្សះផ្សាធ្លាប់បានធ្វើឡើងនៅក្នុងដំណាក់កាលក្រុមប្រឹក្សាឃុំ-សង្កាត់ក៏ដោយ តុលាការនៅតែមានកាតព្វកិច្ច ក្នុងការសាកល្បងធ្វើការផ្សះផ្សាគូភាគីឱ្យអស់ពីសមត្ថភាព ដើម្បីឱ្យគូភាគីបានសះជា ជាមួយនឹងគ្នា។ មូលហេតុដែលក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណី មានចែងពីបទបញ្ញត្តិស្តីពីការសះជា ព្រោះថារវាងគូភាគីនៃបណ្តឹងលែងលះ ជាបណ្តឹងដែលពាក់ព័ន្ធជាមួយបុគ្គលផ្សេងៗដូចជា កូនៗ សាច់ញាតិ និងក្រុមគ្រួសារដោយច្បាប់មិនចង់ឱ្យពលរដ្ឋខ្មែរក្នុងសង្គមមានការបែកបាក់នូវក្នុងគ្រួសារ ដែលនាំឱ្យខូចខាតនូវផលប្រយោជន៍និងប៉ះពាល់ដល់កិត្តិយសទៀតផង។ ប្រសិនបើ តុលាការធ្វើការផ្សះផ្សាបានសម្រេច ធ្វើឱ្យគូភាគីបានសះជានឹងគ្នាវិញ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ ដែលកំណត់ត្រានេះត្រូវបានទទួលស្គាល់ថាមានអានុភាពដូចគ្នានឹង

[35] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៨០ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[36] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៣ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[37] ក្រមរដ្ឋប្បវេណី មាត្រា៩៧៨ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

សាលក្រមលែងលះដែរ។[38] តែបើក្នុងករណីដែលតុលាការបានធ្វើការផ្សះផ្សាតែគូភាគីពុំព្រមសះជាទេនោះ តុលាការនឹងបន្តនីតិវិធីនៃពាក្យបណ្តឹងលែងលះ។

### ២.២.៣.៤. ការចាត់ចែងរក្សាការពារបណ្តោះអាសន្ន

ដំណើរការនីតិវិធីនៃការលែងលះតាមការដាក់ពាក្យបណ្តឹង មានលក្ខណៈស្មុគស្មាញ និងត្រូវចំណាយពេលវេលាវែងក្នុងការធ្វើនីតិវិធី ហេតុនេះភាគីទាំងសងខាងអាចមានការព្រួយបារម្ភ ឬក៏ជួបប្រទះនឹងបញ្ហាក្នុងការរស់នៅ ឬក៏ជួបប្រទះនឹងបញ្ហាពាក់ព័ន្ធការចាត់ចែងផ្សេងៗ ដែលអាចកើតមាននៅអំឡុងពេលនីតិវិធីលែងលះ។ ហេតុនេះហើយទើបគូភាគីអាចមានសិទ្ធិស្នើសុំនូវដីកាសម្រេចរក្សាការពារជាបណ្តោះអាសន្នដែលមានចាំបាច់ដូចជា ការគ្រប់គ្រងកូន ការរស់នៅបែកគ្នារបស់សហព័ទ្ធ និងការថែរក្សាទ្រព្យសម្បត្តិ ពីតុលាការបាន ដែលពាក្យស្នើសុំដីកាសម្រេចរក្សាការពារជាបណ្តោះអាសន្ននេះ ត្រូវធ្វើឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីឈ្មោះ និងអាសយដ្ឋាន។ ការចាត់ចែងរក្សាការពារនេះ មានប្រសិទ្ធិភាពតែក្នុងរយៈពេលដំណើរការនៃរឿងក្តីតែប៉ុណ្ណោះ គឺនៅពេលដែលតុលាការចេញសាលក្រមស្ថាពររួច សាលក្រមនេះនឹងមកជំនួសឱ្យការចាត់ចែងរក្សាការពារជាបណ្តោះអាសន្នហើយការដីការសម្រេចរក្សាការពារពីមុននឹងត្រូវអស់សុពលភាព។

#### ក. ការកំណត់អំពីការរស់នៅរបស់សហព័ទ្ធ

ការលែងលះតាមការដាក់ពាក្យបណ្តឹងលែងលះ គឺបណ្តាលមកពីការរស់នៅមិនចុះសម្រុងគ្នារវាងគូភាគី។ ការមិនចុះសម្រុងនេះអាចបណ្តាលមកពីការប្រើអំពើហិង្សា ការគុំកួនគ្នា ការធ្វើទុក្ខបុកម្នេញ ដែលអាចឈានទៅដល់ការបាត់បង់អាយុជីវិតក៏អាចថាបាន។ ដូចនេះហើយបើមានករណីចាំបាច់ ដោយយោងតាមមូលហេតុដូចបានរៀបរាប់ខាងលើ តុលាការក៏អាចចេញដីកាសម្រេច ក្នុងការបំបែកលំនៅឋានរបស់គូភាគី ក្នុងគោលបំណងដើម្បីការពារសុវត្ថិភាពរបស់ជនរងគ្រោះ ជាភាគីខាងប្រពន្ធ ឬប្តី និងកូន កុំឱ្យបន្តក្លាយជាជនរងគ្រោះ ដែលងាយនឹងទទួលរងនៅអំពើហិង្សាក្នុងគ្រួសារ ក្នុងអំឡុងពេលលែងលះ។[39]

#### ខ. ការថែរក្សាកូនជាបណ្តោះអាសន្ន

ក្នុងអំឡុងពេលដែលកំពុងដំណើរការនីតិវិធីនៃការលែងលះ គូភាគីអាចស្នើសុំទាមទារអំណាចមេបាលើកូនជាបណ្តោះអាសន្នបាន ឬការចាត់ចែងតាមឆន្ទានុសិទ្ធិរបស់តុលាការ។ ដែលការចាត់ចែងអំណាចមេបាទៅលើកូនៗ ចៅក្រមនឹងពិចារណាសម្រេចដោយឈរលើមូលដ្ឋានរបស់កូន។ ក្នុងករណីដែលកូនរបស់ភាគីដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្ហាញឆន្ទៈអំពីការយល់ព្រមទៅជាមួយភាគីខាងណាមួយ នោះចៅក្រមត្រូវធ្វើការសម្រេចតាមឆន្ទៈរបស់កូន។ ប្រសិនបើ កូនមិនទាន់មានសមត្ថភាពនៅក្នុងការបង្ហាញឆន្ទៈនៅឡើយទេ

[38] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២២២ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[39] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥, មាត្រា២០។

ចៅក្រមនឹងសម្រេចការចាត់ចែងបណ្ដោះអាសន្ន លើការថែរក្សាកូន ទៅឱ្យភាគីខាងឪពុក ឬម្ដាយ ដោយពិចារណាទៅលើឧត្ដមប្រយោជន៍របស់កូនមកធ្វើជាមូលដ្ឋានក្នុងការសម្រេច។[40]

**គ. ការថែរក្សាទ្រព្យជាបណ្ដោះអាសន្ន**

ការចេញដីកាសម្រេចលើការថែរក្សាទ្រព្យជាបណ្ដោះអាសន្ន នៅក្នុងអំឡុងពេល ដែលបណ្ដឹងលែងលះកំពុងស្ថិតនៅក្នុងនីតិវិធីហើយមិនទាន់មានសាលក្រមសម្រេចលើការបែងចែកទ្រព្យសម្បត្តិនៅឡើយ។ ដែលបណ្ដាលភាគីមានការព្រួយបារម្ភទៅលើបញ្ហាទ្រព្យសម្បត្តិ ដោយភ័យខ្លាចថាភាគីម្ខាងទៀត ព្យាយាមយកទ្រព្យសម្បត្តិដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍នោះទៅបំផ្លាញ កែប្រែ លក់ ឬផ្ទេរកម្មសិទ្ធិនៅទ្រព្យសម្បត្តិទាំងអស់នោះ មុនពេលដែលតុលាការធ្វើការសម្រេចលើការបែងចែកទ្រព្យសម្បត្តិ ដូច្នេះភាគីដែលមានការព្រួយបារម្ភ អាចដាក់ពាក្យស្នើសុំទៅតុលាការដើម្បីសុំឱ្យតុលាការចេញដីកាសម្រេច លើការចាត់ចែងរក្សាការពារជាបណ្ដោះអាសន្នលើទ្រព្យសម្បត្តិទាំងនោះបាន។[41]

**២.២.៣.៥. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

នៅក្នុងនីតិវិធីនៃការលែងលះតាមការដាក់ពាក្យបណ្ដឹង ការធ្វើនីតិវិធីនៅតុលាការ គឺត្រូវឆ្លងកាត់នៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជាការកត់សម្គាល់នៅក្នុងនីតិវិធីនៃការលែងលះតាមការដាក់ពាក្យបណ្ដឹងដែលមានលក្ខណៈខុសប្លែកពីគ្នា អំពីនីតិវិធីនៃការលែងលះតាមការដាក់ពាក្យសុំ ព្រោះថានៅក្នុងនីតិវិធីនៃការលែងលះតាមការដាក់ពាក្យសុំ តុលាការពុំចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលឡើយ បើពុំមានការចាំបាច់។ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៃការលែងលះតាមការដាក់បណ្ដឹងនេះ ត្រូវបានដឹកនាំដោយចៅក្រម និងក្រឡាបញ្ជី ព្រមជាមួយនឹងវត្តមានរបស់គូភាគីជាចាំបាច់។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះត្រូវរៀបចំឡើងក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីភាគីបានដាក់បណ្ដឹងលែងលះមកតុលាការ។[42] ចំពោះការកំណត់ពីកាលបរិច្ឆេទ ដើម្បីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិ តែក៏ត្រូវកំណត់កាលបរិច្ឆេទដែលគូភាគីទាំងសងខាងអាចចូលរួមបាន។[43] គោលបំណងដែលតុលាការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺដើម្បីហៅគូភាគីមកជួបនិយាយគ្នាផ្ទាល់អំពីបញ្ហា ចំណុចវិវាទ និងការបំភ្លឺនៅអង្គហេតុផ្សេងៗទៀតដែលពាក់ព័ន្ធជាមួយនឹងការលែងលះ។ ជាពិសេស ការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺដើម្បីឱ្យតុលាការទទួលបានភាពច្បាស់ពីចំណុចវិវាទនៃរឿងក្ដីដែល

[40] អនុសញ្ញាស្ដីពីសិទ្ធិកុមារ ឆ្នាំ១៩៩០, មាត្រា៩។

[41] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៣០ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[42] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៨០ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[43] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០៥ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

ភាគីមិនយល់ស្របគ្នា និងបានរៀបចំភស្តុតាងទាំងឡាយដែលភាគីបានដាក់មកតុលាការ។[44] ប្រសិនបើតុលាការនៅមិនទាន់ច្បាស់នូវត្រង់ចំណុចណាមួយនៃរឿងក្តីទេ តុលាការអាចបង្គាប់ឱ្យគូភាគីធ្វើការបំភ្លឺបន្ថែមត្រង់ចំណុចដែលមិនច្បាស់ ឬការសាកសួរភាគី និងបង្គាប់ឱ្យដាក់ឯកសាផ្សេងៗទៀតនៃបណ្តឹង។[45] នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីទាំងពីរក៏អាចដាក់ជូននូវមធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួនមកតុលាការផងដែរ។[46] បន្ថែមពីនេះតុលាការក៏ត្រូវបង្គាប់ឱ្យដើមចោទនៃរឿងក្តីធ្វើសេចក្តីថ្លែងការណ៍អំពីបណ្តឹងទាមទាររបស់ខ្លួនដោយផ្ទាល់មាត់។ ការធ្វើនីតិវិធីនេះផងដែរ មិនចាំបាច់បើសវនាការជាសាធារណៈទេ គឺត្រូវបានធ្វើការទាញហេតុផលដោយនៅក្នុងបន្ទប់របស់ចៅក្រមដែលទទួលកាន់បន្ទុកនូវរឿងក្តី។[47]

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្រឡាបញ្ជីត្រូវកត់ត្រានៅសញ្ញាណនៃរឿងក្តី ឈ្មោះចៅក្រម និងក្រឡាបញ្ជី និងបុគ្គលផ្សេងទៀតដែលបានចូលរួមនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ពេលវេលា និងទីកន្លែង ក្រោយបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជីត្រូវចុះហត្ថលេខាលើកំណត់ហេតុនេះ។[48] បន្ថែមពីនេះ ក្រឡាបញ្ជីត្រូវកត់ត្រានូវសេចក្តីសម្រេចសង្ខេបអំពីសកម្មភាពដែលមានធ្វើឡើងនៅក្នុងនីតិវិធីនីមួយៗ និងកត់ត្រាឱ្យបានច្បាស់លាស់នូវខ្លឹមសាលដែលដើមចោទទាមទារឱ្យតុលាការចេញ អង្គហេតុដែលបានអះអាង និងការស្នើសុំឱ្យពិនិត្យភស្តុតាង ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ភាគី និងអង្គហេតុផ្សេងៗទៀតដែលបានកើតមាននៅក្នុងនីតិវិធី។[49] ក្នុងករណីដែលភាគីទាំងពីរមិនពេញចិត្តនៅចំណុចណាដែលមាននៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ភាគីទាំងពីរក៏អាចប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៃកំណត់ហេតុបានដែល។[50]

### ២.២.៣.៦. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ គឺជានីតិវិធីសំខាន់នៅក្នុងការជំនុំជម្រះនៃបណ្តឹងលែងលះ ដែលចាំបាច់ត្រូវតែធ្វើឡើងនៅក្នុងសាលសវនាការ មុននឹងឈានការសម្រេចសេចក្តីពីតុលាការទៅលើបណ្តឹងលែងលះ។[51] នៅក្រោយពេលដែលបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវកំណត់

[44] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០៣ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[45] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៩០ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[46] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៩៣ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០៥ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[48] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១០ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[49] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១១ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[50] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១២ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[51] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១៤ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅភាគីមកចូលរួម។[52] កាលកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងដោយអាស្រ័យទៅលើការសម្រេចរបស់តុលាការ តែតុលាការគប្បីណាតែដាក់កាលបរិច្ឆេទណាដែលភាគីសងខាងអាចមានវត្តមានបាន ឬធ្វើការសាកសួរភាគីទាំងសងខាងនៅថ្ងៃដែលអាចចូលរួមនីតិវិធីបាន មុននឹងសម្រេចកំណត់កាលបរិច្ឆេទកាលទាញហេតុផលដោយផ្ទាល់មាត់។[53] ចំពោះការទាញហេតុផលដោយផ្ទាល់មាត់នេះ គឺតុលាការមិនត្រូវបានធ្វើឡើងនៅក្នុងសាលសវនាការជាសាធារណៈឡើយ ប៉ុន្តែតុលាការអាចអនុញ្ញាតឱ្យបុគ្គលដែលបានពាក់ព័ន្ធក្នុងរឿងក្តីលែងលះអាចចូលរួមបានតែប៉ុណ្ណោះ។[54]

នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីបន្ថែមនូវអង្គហេតុ និងអាចភស្តុតាងផ្សេងៗបន្ថែមទៀតបាន។[55] ប៉ុន្តែបើការដាក់បន្ថែមនូវអង្គហេតុ និងការដាក់ភស្តុតាង ធ្វើឱ្យមានការយឺតយ៉ាវដល់ការធ្វើនីតិវិធី ភាគីអាចដាក់បានតាមឆន្ទានុសិទ្ធិរបស់តុលាការ។[56] ការពិនិត្យភស្តុតាងត្រូវបានធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ ឬការស្នើសុំរបស់ភាគី ដូចជា៖ តុលាការទទួលបំភ្លឺបន្ថែមនៃរឿងក្តីលែងលះ តាមរយៈការសាកសួរសាក្សី។ តុលាការនឹងពិនិត្យរាល់ភស្តុតាងទាំងឡាយដែលភាគីបានដាក់មកតុលាការ ដើម្បីលើកមកជជែកវែកញែក និងសួរដេញដោលដល់ភាគីនៅក្នុងសាលសវនាការ។ តុលាការអាចបង្គាប់ឱ្យកោះហៅសាក្សីដើម្បីចូលមកបំភ្លឺក្នុងសាលសវនាការ ដោយសួរដេញដោលទៅលើអង្គហេតុដែលសាក្សីបានដឹងដែលទាក់ទងនឹងភាគីទាំងពីរដែលកំពុងធ្វើសកម្មភាពលែងលះ ប្រសិនបើសាក្សីមិនព្រមចូលបំភ្លឺនៅក្នុងតុលាការតាមការកោះហៅទេ តុលាការអាចបង្គាប់ឱ្យនាំខ្លួនសាក្សីបានតាមរយៈដីកាសម្រេច។[57] ចំពោះការសាកសួរគូភាគីក្នុងរឿងក្តីលែងលះ គឺសំខាន់ណាស់នូវក្នុងនីតិវិធី ដែលតុលាការត្រូវធ្វើការសាកសួរទាំងដើមចោទ និងចុងចម្លើយ ដើម្បីប្រមូលយកនូវព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងរឿងលែងលះ។ ភាគីតែងឆ្លើយបំភ្លឺ ឬសារភាព ឬបដិសេធ នូវការអះអាងចំពោះគ្នាទៅវិញទៅមកនៅក្នុងនីតិវិធី។ តុលាការនឹងធ្វើការសម្រេចដោយផ្អែកទៅលើភស្តុតាងជាឯកសារផ្សេងៗដែលពាក់ព័ន្ធដោយតុលាការបានពិនិត្យវិនិច្ឆ័យតម្លៃគតិយុត្តនៃឯកសារដែលគូភាគីបានដាក់មកតុលាការ

[52] ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១១៣ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[53] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១៥ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[54] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៦ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១៦ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[56] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០៨ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[57] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១២៣ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

នោះទាំងអស់។ ដែលឯកសារដែលគូភាគីបានដាក់មកតុលាការដើម្បីពិនិត្យនោះមានដូចជាៈ សំបុត្រអាពាហ៍ពិពាហ៍របស់គូភាគី សំបុត្រកំណើតរបស់កូន និងបញ្ជីទ្រព្យសម្បត្តិជាដើម។

នៅចុងក្រោយពេលដែលតុលាការបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការឱ្យគូភាគីធ្វើការទាញហេតុផលចុងក្រោយម្តងទៀតបាន មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ នៅក្នុងដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់នេះ ក្រោយពេលបញ្ចប់នៃនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ ក្រឡាបញ្ជីមានកាតព្វកិច្ចសំខាន់ គឺកត់ត្រានៅសញ្ញាណនៃរឿងក្តី ឈ្មោះចៅក្រម និងក្រឡាបញ្ជី និងបុគ្គលផ្សេងទៀតដែលបានចូលរួមនៅក្នុងនីតិវិធីការទាញហេតុផលដោយផ្ទាល់ ពេលវេលា និងទីកន្លែង នៃការទាញហេតុផលដោយផ្ទាល់មាត់។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជី ត្រូវពិនិត្យទៅលើកំណត់ត្រានៃការទាញហេតុផលដោយផ្ទាល់មាត់ និងចុះហត្ថលេខាលើកំណត់ហេតុនេះ។[58] ចំពោះចៅក្រមវិញត្រូវកំណត់ការបរិច្ឆេទមិនឱ្យលើសពី ៣០ (សាមសិប) ថ្ងៃ ដើម្បីធ្វើការប្រកាសសាលក្រម បន្ទាប់ពីបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។[59]

**២.២.៤. ការសម្រេចសេចក្តី**

រឿងក្តីលែងលះតាមការដាក់ពាក្យបណ្តឹង ត្រូវបានឈានដល់នីតិវិធីបញ្ចប់នៃរឿងក្តីលែងលះ គឺការចេញនូវសាលក្រមសម្រេចលើបណ្តឹងទាមទារលែងលះ។ ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ត្រូវបានបញ្ញត្តិថាការសម្រេចលើបណ្តឹងលែងលះ គឺត្រូវសម្រេចដោយសាលក្រមពីតុលាការ។ ដែលសាលក្រម គឺជាការសម្រេចសេចក្តី ដែលតុលាការធ្វើលិខិតសាលក្រមដែលមាន លក្ខណៈគ្រប់គ្រាន់ ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសនៅក្នុងក្រមនេះ ឬ នៅក្នុងច្បាប់ផ្សេង ហើយកើតអានុភាព ដោយការប្រកាសដោយផ្អែកលើលិខិតសាលក្រមនោះ។[60] ការធ្វើសេចក្តីសម្រេចទៅការលែងលះតាមការដាក់ពាក្យបណ្តឹង តុលាការមានឆន្ទានុសិទ្ធិក្នុងការសម្រេចចេញសាលក្រមលែងលះ ឬតុលាការចេញសេចក្តីសម្រេចបដិសេធចោលនូវពាក្យបណ្តឹងលែងលះ។ ចំពោះនីតិវិធីដើម្បីសម្រេចចេញសាលក្រមនឹងរៀបរាប់ដូចខាងក្រម។

[58] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១១៨ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[59] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨២ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[60] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៧៩ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

### ២.២.៤.១. ការចេញសាលក្រមលែងលះ

ចៅក្រមដែលទទួលបន្ទុកក្នុងរឿងលែងលះ ត្រូវធ្វើសេចក្ដីសម្រេចដោយឆន្ទានុសិទ្ធិ តាមរយៈសាលក្រម ដោយផ្អែកលើលទ្ធផលដែលបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង។[61] តុលាការធ្វើការវិនិច្ឆ័យ និងធ្វើការសម្រេចទៅលើចំណុចដែលភាគីបានទាមទារតែប៉ុណ្ណោះនៅក្នុងសាលក្រម គឺតុលាការមិនអាចចេញសាលក្រមទៅលើចំណុចណាដែលភាគីមិនបានទាមទារឡើយ ប្រសិនបើភាគីពុំបានទាមទារ។[62] ចំពោះពាក្យបណ្ដឹងលែងលះ បើសិនតុលាការចេញសាលក្រមលែងលះ នោះតុលាការត្រូវធ្វើសេចក្ដីសម្រេចអំពីការកំណត់អំណាចមេបា ការចាត់ចែងទាក់ទងនឹងការចិញ្ចឹមបីបាច់រក្សាកូន ឬការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ ដោយឆន្ទានុសិទ្ធិ និងការស្នើសុំរបស់ភាគី។[63] នៅក្នុងរបៀបនៃការសរសេរសាលក្រម តុលាការត្រូវសរសេរអំពីចំណុចមួយយចំនួនឱ្យបានច្បាស់លាស់ដូចជា៖ ថ្ងៃដែលបានបញ្ចប់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ នាមករណ៍ ឬ ឈ្មោះ និងអាសយដ្ឋានរបស់ភាគី ហើយនឹងឈ្មោះ អាសយដ្ឋានរបស់អ្នកតំណាងដោយច្បាប់បានកំណត់ អង្គហេតុ ចំណុចវិវាទ សំអាងហេតុ និងការធ្វើនូវសេចក្ដីសម្រេចបញ្ចប់។ ចៅក្រមត្រូវមានកាតព្វកិច្ចចុះហត្ថលេខា និងត្រាលើលិខិតសាលក្រមលែងលះនោះផងដែរ។[64] សាលក្រមលែងលះត្រូវតែប្រកាសដោយតុលាការ នៅក្នុងសាលសវនាការ ដើម្បីឱ្យសាលក្រមលែងលះនោះមានអានុភាព។ ការសាលក្រមត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ១ (មួយ) ខែ បន្ទាប់ពីបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែមិនត្រូវបានយកមកអនុវត្តទេប្រសិនបើរឿងក្ដីនោះមានភាពស្មុគស្មាញខ្លាំង។[65] ហើយសាលក្រមនេះត្រូវបញ្ជូនទៅឱ្យគូភាគី ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រម ចំពោះការបញ្ជូនសាលក្រមលែងលះនេះផងដែរ ត្រូវធ្វើឡើងដោយអានុសារសាលក្រម។[66] ចំពោះសាលក្រមដែលអត្តពន្ធភាព តុលាការដែលចេញសាលក្រម មិនអាចលុប ឬកែប្រែសាលក្រមនោះទេ លើកលែងតែក្នុងករណីដែលសាលក្រមនេះមានការគណនាខុស ឬកត់ខុស ឬកំហុសជាក់ស្ដែង តុលាការអាចកែប្រែតាមឆន្ទានុសិទ្ធិ ឬការស្នើសុំរបស់ភាគី។ ការកែតម្រូវលើសាលក្រមលែងលះនេះត្រូវតែធ្វើឡើង តាមរយៈដីកាសម្រេចឱ្យកែតម្រូវ។

---

[61] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨០ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[62] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨២ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[63] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទង់នឹងឋានៈបុគ្គល ឆ្នាំ២០១០, មាត្រា២២(១)។

[64] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[65] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨៧ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[66] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៩០ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

**២.២.៤.២. ការសម្រេចមិនឱ្យលែងលះ**

គ្រប់ការដាក់ពាក្យបណ្តឹងលែងលះ តុលាការមិនសុទ្ធតែចេញសាលក្រមលែងលះឱ្យនោះទេ ដោយតុលាការត្រូវធ្វើការពិចារណាជាមុនសិន មុននឹងធ្វើសម្រេចឱ្យលែងលះ ឬអត់។ តុលាការសម្រេចសេចក្តី ដោយធានាមិនឱ្យមានការបំពានផលប្រយោជន៍ និងធានាសណ្តាប់ធ្នាប់សង្គម។ តុលាការមានឆន្ទានុសិទ្ធិច្រានចោលការប្តឹងទាមទារលែងលះ បើតុលាការយល់ឃើញថាការសម្រេចឱ្យលែងលះតាមការដាក់ពាក្យបណ្តឹងលែងលះនោះ អាចបណ្តាលឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើផលប្រយោជន៍របស់ភាគីទាំងសងខាង ឬការលែងលះនោះធ្វើឱ្យមានការប៉ះពាល់ ឬខាតបង់ផលប្រយោជន៍របស់កូន និងការទាមទារលែងលះនោះពុំមានមូលហេតុត្រឹមត្រូវតាមច្បាប់ដែលមានកំណត់ ដែលមានលក្ខណៈផ្ទុយអំពីច្បាប់។

**២.២.៤.៣. បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់**

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាបណ្តឹងឧបាស្រ័យទាមទារដោយភាគីដែលមិនសុខចិត្តនឹងសាលក្រមរបស់តុលាការថ្នាក់ក្រោម ទៅតុលាការជាន់ខ្ពស់ ដើម្បីឱ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដែលមិនទាន់បានចូលជាស្ថាពរ។[67] ភាគីដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់តុលាការដើម ភាគីអាចធ្វើការដាក់បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន (បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ) នៅក្នុងអំឡុងពេលដែលច្បាប់បានកំណត់។ បណ្តឹងឧបាស្រ័យដែលភាគីមានសិទ្ធិធ្វើនោះមាន បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ។[68] បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលក្រម ឬសាលដីកា។ ចំពោះបណ្តឹងជំទាស់ក៏ស្ថិតនៅក្នុងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលប៉ុន្តែនៅក្នុងបណ្តឹងលែងលះមិនអាចធ្វើបណ្តឹងជំទាស់បានទេ ដោយហេតុថាបណ្តឹងជំទាស់ជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះដីកាសម្រេច។

**ក. បណ្តឹងឧទ្ធរណ៍**

ភាគីលែងលះ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់តុលាការដើម អាចដាក់បណ្តឹងឧទ្ធរណ៍បាន នៅមុនពេលដែលសេចក្តីសម្រេចរបស់តុលាការដើមចូលជាស្ថាពរ។ ភាគីដែលបានធ្វើបណ្តឹងឧទ្ធរណ៍ត្រូវបានហៅថា "ដើមបណ្តឹងឧទ្ធរណ៍" ហើយភាគីម្ខាងទៀតហៅថា "ចុងបណ្តឹងឧទ្ធរណ៍"។ បណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងដោយតុលាការបានទុកអំឡុងពេល ១ (មួយ) ខែ ដោយគិតចាប់ពីថ្ងៃដែលទទួលនូវការបញ្ជូនលិខិតសាលក្រម។[69] ភាគីដែលប្តឹងឧទ្ធរណ៍ត្រូវដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការដើម ដែលសរសេរបញ្ជាក់អំពីអត្តសញ្ញាណ

[67] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[68] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[69] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៦៤ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

របស់ភាគី សញ្ញាណសាលក្រមនៃការជំនុំជម្រះលើកទី១ សេចក្ដីដែលប្ដឹងឧទ្ធរណ៍ចំពោះសាលក្រម និងបញ្ជាក់ឱ្យច្បាស់នូវមូលហេតុនៃការទាមទារឱ្យលុបចោល ឬផ្លាស់ប្ដូរសេចក្ដីសម្រេច។[70] តុលាការដើមត្រូវប្រញាប់បញ្ជូនសំណុំរឿងលែងលះនោះ ទៅសាលាឧទ្ធរណ៍ដើម្បីបន្តនីតិវិធី។ ចំពោះនីតិវិធីនៃការលែងលះនៅក្នុងសាលាឧទ្ធរណ៍វិញ គឺត្រូវបានអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការជំនុំជម្រះនៅតុលាការដើម លើកលែងតែមាននៅក្នុងករណីដែលមានបញ្ញត្តិពិសេស។[71] ក្នុងករណីដែលភាគីមិនបានប្ដឹងឧទ្ធរណ៍ទៅលើចំណុចផ្សេងនៃសាលក្រមទេ សាលាឧទ្ធរណ៍អាចប្រកាសឱ្យអនុវត្តបណ្ដោះអាសន្ន ត្រឹមតែផ្នែកដែលពុំមាននៅក្នុងពាក្យសុំប្ដឹងឧទ្ធរណ៍តែប៉ុណ្ណោះ។[72] បណ្ដឹងឧទ្ធរណ៍មិនត្រូវបានប្ដឹងទេបើសាលក្រមនៃសេចក្ដីសម្រេចនោះ ជាសាលក្រមរបៀប ឬភាគីទាំងសងខាងបានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរថា មិនធ្វើប្ដឹងឧទ្ធរណ៍ទេ។ បើតុលាការយល់ឃើញថាសាលក្រមនៅក្នុងនីតិវិធីជំនុំជម្រះលើកទី១ មានភាពត្រឹមត្រូវ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវច្រានចោលនូវពាក្យបណ្ដឹងឧទ្ធរណ៍ ក្នុងករណីដែលសំអាងហេតុនៅក្នុងការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវក៏ដោយ តុលាការនៃបណ្ដឹងឧទ្ធរណ៍ក៏អាចច្រានចោលនូវពាក្យបណ្ដឹងនោះបានដែរ បើយល់ថាសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមនោះ ត្រឹមត្រូវដោយផ្អែកលើសំអាងហេតុផ្សេងទៀត។[73] តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី១ បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវ ឬមានភាពផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ។[74]

**ខ.បណ្ដឹងសាទុក្ខ**

ភាគីលែងលះអាចដាក់ពាក្យប្ដឹងសាទុក្ខបានបើយល់ថាសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍មិនត្រឹមត្រូវ ដោយយកមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តដែលមាន។[75] ភាគីដែលបានដាក់ពាក្យប្ដឹងសាទុក្ខ ត្រូវហៅថា "ដើមបណ្ដឹងសាទុក្ខ" និងភាគីម្ខាងទៀតហៅថា "ចុងបណ្ដឹងសាទុក្ខ"។ ពាក្យបណ្ដឹងសាទុក្ខត្រូវសរសេរបញ្ជាក់ឱ្យច្បាស់នូវមូលហេតុដែលនាំឱ្យផ្ទុយនឹងច្បាប់របស់សាលដីកាសាលាឧទ្ធរណ៍ រួចយកពាក្យបណ្ដឹងនោះទៅដាក់នូវតុលាការដើម។ ប្រសិនបើភាគីមិនបានសរសេរនូវមូលហេតុនៃបណ្ដឹងសាទុក្ខក្នុងពាក្យបណ្ដឹងសាទុក្ខទេ ដើមបណ្ដឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ ជូនទៅតុលាការ

[70] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៦៥ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[71] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៧៣ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[72] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៧១ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[73] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៧៧ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[74] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៧៩ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[75] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៨៤ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

នៃបណ្ដឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ។[76] តុលាការដើមត្រូវប្រញាប់បញ្ជូននៅសំណុំរឿងលែងលះនោះទៅតុលាការកំពូល ដើម្បីបន្តនីតិវិធី។ ចំពោះនីតិវិធីនៃការលែងលះនៅក្នុងតុលាការកំពូល គឺ អនុវត្តនីតិវិធីដូចការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ដែរ ដូចដែលច្បាប់បានបញ្ញត្តិនៃជំពូកទី២ នៃគន្ថីទី៣ លើកលែងតែមានបញ្ញត្តិពិសេស។[77] តុលាការកំពូលអាចប្រកាសឱ្យអនុវត្តបណ្ដោះអាសន្នបាន ត្រង់ចំណុចទាំងឡាយណាដែលភាគីមិនបានដាក់ប្ដឹងសាទុក្ខ តាមពាក្យសុំដែលចេញដោយដីកាសម្រេច។ តុលាការកំពូល ធ្វើការសម្រេចបដិសេធចោលនូវសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ ក្នុងករណីដែលសេចក្ដីសម្រេចដែលសាលាឧទ្ធរណ៍នោះមានភាពមិនត្រឹមត្រូវតាមច្បាប់ដែលមានចែងនៅក្នុងមាត្រា ២៨៤ និងមាត្រា ២៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីតុលាការត្រូវបដិសេធចោលនូវសាលដីកា ឬសាលក្រម ហើយត្រូវបញ្ជូនរឿងក្ដីត្រឡប់ទៅតុលាការដើមវិញ ឬផ្ទេររឿងក្ដីនេះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា លើកលែងតែក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៣០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។[78]

[76] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៨៩ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[77] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៨៦ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[78] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៩៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

# ជំពូកទី ៣
# អានុភាពនៃការលែងលះ

# ជំពូកទី៣
# អានុភាពនៃការលែងលះ

អានុភាពនៃការលែងលះ គឺជាការផ្តាច់នៃចំណងអាពាហ៍ពិពាហ៍រវាងគូភាគីនៅពេលដែលតុលាការចេញសេចក្តីសម្រេចអំពីការលែងលះដែលបានចូលជាស្ថាពរ។ ក្នុងនោះផងដែរ អានុភាពនៃការលែងលះ គឺមានចំពោះសាលក្រម និងដីកាសម្រេច នាំឱ្យបង្កើតនូវអានុភាពដល់ភាគី ទាំងភាគីដែលសម្រេចការលែងលះតាមការដាក់ពាក្យសុំ និងភាគីដែលបានលែងលះតាមការដាក់ពាក្យបណ្តឹង។ អានុភាពលែងលះមានដូចជា៖ (៣.១) អានុភាពចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ, (៣.២) អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ និង (៣.៣) អានុភាពនៃការលែងលះចំពោះកូន។

## ៣.១. អានុភាពចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ

### ៣.១.១. ចំពោះសហព័ទ្ធ

បុរស នៅពេលដែលបានបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍រួចហើយ បុរសនោះ គឺអាចរៀបអាពាហ៍ពិពាហ៍ម្តងទៀតបាន ដោយមិនចាំបាច់រងចាំទេ បន្ទាប់ពីសាលក្រមនៃការលែងលះបានចូលជាស្ថាពរ។ ចំណែកឯខាងស្ត្រី ក្រោយពីបានរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍មានលក្ខណៈខុសពីបុរស ដោយច្បាប់បានកំណត់រយៈពេលនៃការរៀបអាពាហ៍ពិពាហ៍ថ្មី ពោល គឺស្ត្រីពុំអាចរៀបអាពាហ៍ពិពាហ៍ភ្លាមៗបានឡើយ ប្រសិនបើអំឡុងពេល ១២០ (មួយរយម្ភៃ) ថ្ងៃ ពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ ឬលុបចោល។[79] ក្នុងករណីដែលភាគីខាងស្ត្រីមានបំណងរៀបអាពាហ៍ពិពាហ៍ថ្មី មុនអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ ឬលុបចោល ភាគីខាងស្ត្រីត្រូវមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះ ពីវេជ្ជបណ្ឌិតសិន ដើម្បីបញ្ជាក់ នោះស្ត្រីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។

### ៣.១.២. ចំពោះញាតិ និងនាមត្រកូល

#### ក. ចំពោះញាតិ

នៅពេលដែលគូភាគីបានរៀបអាពាហ៍ពិពាហ៍ នាំឱ្យគូភាគីបង្កើតឱ្យមាននៅទំនាក់ទំនងញាតិពន្ធ ហើយទំនាក់ទំនងញាតិពន្ធនេះនឹងត្រូវបញ្ចប់ដោយការលែងលះ។[80] ដែលញាតិ សំដៅលើការដែលមានជាប់ខ្សែលោហិតក្នុង៦ថ្នាក់ សហព័ទ្ធ និងញាតិពន្ធ ក្នុង៣ថ្នាក់។ ញាតិពន្ធ កើតឡើងនៅពេលដែលមានចំណងអាពាហ៍ពិពាហ៍ដែលនាំឱ្យមានការភ្ជាប់គ្នាជាសាច់ញាតិ ចំពោះគ្រួសាររបស់សហព័ទ្ធទាំងសងខាង។ ហើយញាតិពន្ធនឹងត្រូវ

---

[79] ក្រមរដ្ឋប្បវេណី មាត្រា៩៥០ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[80] ក្រមរដ្ឋប្បវេណី មាត្រា៩៤១ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

បានបញ្ចប់ទៅវិញនៅពេលដែលសហព័ទ្ធសម្រេចរំលាយចំណងអាពាហ៍ពិពាហ៍ ពោលគឺសហព័ទ្ធបានសម្រេចលែងលះគ្នា អាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ ញាតិពន្ធក៏ត្រូវបានបញ្ចប់ដូចគ្នាផងដែរ។ ក្នុងករណីដែលភាគីមានកូន ទំនាក់ទំនងរវាងញាតិនឹងកូននៅតែមានដដែលទោះបីភាគីទាំងសងខាងត្រូវបានលែងលះគ្នាហើយក៏ដោយ។

**ខ.ចំពោះនាមត្រកូល**

នៅក្នុងអំឡុងពេលដែលបានរៀបអាពាហ៍ពិពាហ៍ មានសហព័ទ្ធមួយចំនួន ភាគច្រើនភាគីខាងស្រី បានប្តូរនាមត្រកូលរបស់ខ្លួន ដើម្បីប្រើប្រាស់នាមត្រកូលខាងស្វាមី។ នៅក្រោយពេលដែលសហព័ទ្ធបានលែងលះគ្នាហើយ ភាគីខាងប្តី ឬប្រពន្ធដែលបានប្តូរនាមត្រកូលថ្មី ពេលអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមានមុនរៀបអាពាហ៍ពិពាហ៍វិញបាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលដែលបានលែងលះគ្នាក៏បាន។[81] ចំពោះការប្រើប្រាស់នាមត្រកូលមិនជាបញ្ហាចោទនៅក្រោយពេលដែលបានលែងលះទេ ដូច្នេះនៅក្រោយពេលលែងលះ ប្តី ឬប្រពន្ធ អាចប្រើប្រាស់នាមត្រកូលទៅតាមឆន្ទៈរបស់ខ្លួន។

### ៣.១.៣. ចំពោះអត្តាធីនភាព

អត្តាធីនភាព គឺជាការផ្តល់ឱ្យអនីតិជនបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬអំណាចមេបាហើយមានសមត្ថភាពដូចទៅនឹងនីតិជនដែរ។ ទោះបីជានីតិជននេះ ពុំទាន់គ្រប់អាយុ ១៨ (ដប់ប្រាំបី) ឆ្នាំនៅឡើយក៏ពិតមែន តែនៅពេលដែលអនីតិជននេះមិនទាន់ដល់វ័យរៀបអាពាហ៍ពិពាហ៍បាន តែបែរជាអនីតិជននេះបានរៀបអាពាហ៍ពិពាហ៍ អនីតិជននេះនឹងត្រូវបានចាត់ទុកថាបានដល់វ័យនីតិភាពដោយសារការរៀបអាពាហ៍ពិពាហ៍។[82] នីតិភាពនេះ គឺជាសិទ្ធិដែលកំណត់ដោយច្បាប់សម្រាប់អនីតិជន ដែលបានរៀបអាពាហ៍ពិពាហ៍រួចដោយមិនចាំបាច់តម្រូវឱ្យតុលាការធ្វើការប្រកាសពីនីតិភាព ក៏ត្រូវបានបាត់បង់នូវចំណងអាពាហ៍ពិពាហ៍ទៅវិញឡើយ ទោះបីជាចំណងអាពាហ៍ពិពាហ៍បានឈានដល់ការលែងលះ នឹងចេញសាលក្រមនៃការលែងលះជាស្ថាពររួចហើយក៏ដោយ។

## ៣.២. អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ

ការលែងលះតាមការដាក់ពាក្យសុំ ទ្រព្យសម្បត្តិត្រូវបានបែងចែកទៅតាមការព្រមព្រៀងនៃគូភាគីដែលបានព្រមព្រៀងគ្នាដូចមានក្នុងពាក្យសុំលែងលះ។ ការព្រមព្រៀងនេះ គឺស្ថិតលើឆន្ទៈរបស់ភាគីទាំងសងខាងដោយមិនគិតថាភាគីម្ខាងបានតិច ឬភាគីម្ខាងទៀតបានច្រើនជាង ឱ្យតែជាការព្រមព្រៀងរបស់ភាគីទាំងសងខាងតុលាការនឹងធ្វើការសម្រេចទៅតាមការព្រមព្រៀងនោះជានិច្ច។ ចំពោះការលែងលះតាមការដាក់ពាក្យបណ្តឹង

[81] ក្រមរដ្ឋប្បវេណី មាត្រា៩៨១ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[82] ក្រមរដ្ឋប្បវេណី មាត្រា៩៦៨ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

ភាគីត្រូវយកបានតែទ្រព្យជារបស់ខ្លួនដែលជាទ្រព្យដោយឡែក ដែលមានមុនពេលរៀបការប៉ុណ្ណោះ។ ហេតុនេះ ទ្រព្យសម្បត្តិដែលរកបាននៅក្នុងចំណងអាពាហ៍ពិពាហ៍ត្រូវបែងចែងម្នាក់ពាក់កណ្ដាល ក្នុងករណីពិសេស និង តាមសំណើរបស់ភាគីណាម្នាក់ដែលតុលាការសម្រេចចែកទ្រព្យសម្បត្តិរួមផ្សេងដោយគិតទៅដល់ប្រយោជន៍ របស់កូន។

### ៣.២.១. ទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា

នៅក្នុងការលែងលះ ការបែងចែកទ្រព្យសម្បត្តិ គឺអាស្រ័យទៅលើឆន្ទៈរបស់ភាគី និងការពិភាក្សារវាងភាគី ដែលបានព្រមព្រៀងគ្នា។ ចំពោះទ្រព្យរបស់សហព័ទ្ធតាមកិច្ចសន្យានេះ ជាកិច្ចសន្យាដែលភាគីទាំងពីរបាន បង្ហាញនូវភាពច្បាស់លាស់ទៅលើទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍ ដែលកិច្ចសន្យានេះមានចែងនូវសិទ្ធិ កាតព្វកិច្ច និងករណីយកិច្ច ដែលតម្រូវតាមសហព័ទ្ធគោរពនូវកិច្ចសន្យានេះបន្ទាប់ពី បានចុះ ហើយកិច្ចសន្យានេះមិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្ដីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុង បានឡើយ។ កិច្ចសន្យានេះ ភាគីទាំងពីរត្រូវព្រមព្រៀងគ្នា និងធ្វើឡើងនៅចំពោះមុខមន្ត្រីក្រសួងយុត្តិធម៌ ហើយ គោរពតាមការកំណត់របស់ច្បាប់ ដើម្បីធានាឱ្យមានភាពត្រឹមត្រូវ។ ដូច្នេះនៅពេលដែលភាគីទាំងសងខាង សម្រេចចិត្តលែងលះនោះ ការបែងចែកទ្រព្យសម្បត្តិនឹងត្រូវអនុវត្តទៅតាមកិច្ចសន្យារបស់ភាគី។ បើប្ដីប្រពន្ធ មិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនោះ ត្រូវអនុលោមតាមបញ្ញត្តិ តាមការបែងចែកទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។[83]

### ៣.២.២. ទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់ដែលបានកំណត់

ក្នុងករណីដែលភាគីមិនពិភាក្សាគ្នាបានទៅលើការបែងទ្រព្យសម្បត្តិ និងមិនបានបង្កើតកិច្ចសន្យាទ្រព្យ សម្បត្តិប្ដីប្រពន្ធជាមួយគ្នាទេ តុលាការនឹងធ្វើការសម្រេចបែកចែកទ្រព្យសម្បត្តិនោះតាមបណ្ដឹងទាមទារដោយ ផ្អែកតាមច្បាប់ដែលបានកំណត់ ដែលបានចែកទ្រព្យសម្បត្តិសហព័ទ្ធជាពីរប្រភេទគឺៈ ទ្រព្យសម្បត្តិរួម និងទ្រព្យ សម្បត្តិដោយឡែក។

#### ៣.២.២.១. ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺសំដៅដល់ទ្រព្យសម្បត្តិទាំងឡាយរបស់សហព័ទ្ធទាំងពីរដែលបានរករួមគ្នា ដែលជា ទ្រព្យសម្បត្តិរបស់សហព័ទ្ធទទួលបាននៅអំឡុងពេលដែលមាននូវចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយគ្នា លើកលែងតែទ្រព្យសម្បត្តិដោយឡែក។ ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្ដីប្រពន្ធដើម្បីបែងចែកទ្រព្យ សម្បត្តិបានទេ តុលាការត្រូវបែងចែកទ្រព្យសម្បត្តិរួមនោះជាពីរចំណែកស្មើគ្នាទៅឱ្យ ប្ដី និងប្រពន្ធដែលបាន

[83] ក្រមរដ្ឋប្បវេណី មាត្រា៩៦៨ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

លែងលះគ្នា ទោះបីជានៅក្នុងសង្គមជាក់ស្តែងភាគីខាងបុរសជាអ្នកចេញពីក្រៅ ដើម្បីប្រកបមុខរបរ ធ្វើការយកប្រាក់មកផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារក៏ដោយ ហើយកិច្ចការគេហកិច្ចក៏ត្រូវបានធ្លាក់មកភាគីខាងស្ត្រីជាអ្នករ៉ាប់រង ដូច្នេះហើយទើបនៅក្នុងក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើនៅក្រៅផ្ទះដែរ។[84] បន្ថែមពីនេះតុលាការនឹងធ្វើការបែងចែកទ្រព្យសម្បត្តិដោយផ្អែកទៅលើការស្នើសុំរបស់ភាគី ស្របតាមរយៈភស្តុតាងដែលបានដាក់មកឱ្យតុលាការពិនិត្យ ដូចជាការបរិច្ចាគរបស់ភាគីនីមួយៗលើទ្រព្យសម្បត្តិរួម ឬសកម្មភាពថែរក្សា និងការខិតខំរកប្រាក់។

#### ៣.២.២.២. ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក គឺសំដៅដល់ទ្រព្យសម្បត្តិដោយឡែករបស់ភាគីដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលពេលរៀបអាពាហ៍ពិពាហ៍ ឬជាទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងលើទ្រព្យសម្បត្តិដោយឡែក។[85] ការបែងចែកទ្រព្យសម្បត្តិដោយឡែកនៅក្នុងរឿងលែងលះ គឺមានលក្ខណៈសាមញ្ញ និងមិនមានលក្ខណៈស្មុគស្មាញដូចការបែងចែកទ្រព្យសម្បត្តិរួមទេ ព្រោះថាការបែងចែកនៅទ្រព្យសម្បត្តិដោយឡែក គឺគូភាគីមានសិទ្ធិទទួលបាននូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនដែលមានមុនរៀបអាពាហ៍ពិពាហ៍ទាំងអស់ ត្រឡប់ទៅវិញ។ ចំពោះការអាស្រ័យនៅលើអចលនវត្ថុដែលជាសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ដែលប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារនឹងត្រូវបានបញ្ចប់នៅពេលដែលសាលក្រមនៃការលែងលះបានចូលជាស្ថាពរ។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ សហព័ទ្ធរបស់មតកជនជាសន្តតិជនជានិច្ច[86] តែនៅពេលដែលសាលក្រមនៃការលែងលះបានចូលជាស្ថាពរ បានសេចក្តីថាសហព័ទ្ធលែងត្រូវជាអ្វីនឹងគ្នាទៀតហើយ ដូច្នេះសិទ្ធិជាសន្តតិជនជានិច្ចក្នុងការទទួលបាននូវចំណែកមរតករបស់ម្ខាងទៀតនឹងត្រូវបានបាត់បង់ដែរ។

### ៣.៣. អានុភាពនៃការលែងលះចំពោះកូន

នៅក្រោយការលែងលះ តុលាការនឹងកំណត់យកភាគីណាម្ខាង ឪពុក ឬម្តាយ ជាអ្នកមានអំណាចមេបាតាមការពិភាក្សារបស់ឪពុកម្តាយ ដើម្បីផ្តល់នូវសិទ្ធិបីបាច់ថែរក្សា និងការអប់រំកូនជាដើម។ ការប្រគល់អំណាចមេបា ជាការប្រគល់សិទ្ធិគ្រប់យ៉ាង ចិញ្ចឹមបីបាច់ថែរក្សា អប់រំកូន ទៅភាគីណាមួយក្រោយពីគូភាគីបានលែងលះគ្នា។

---

[84] ក្រមរដ្ឋប្បវេណី មាត្រា៩៨០ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[85] ក្រមរដ្ឋប្បវេណី មាត្រា៩៧២ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[86] ក្រមរដ្ឋប្បវេណី មាត្រា១១៦១ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

### ៣.៣.១. ការកំណត់អំណាចមេបា

ក្រោយលែងលះ តុលាការនឹងធ្វើការសម្រេចអំពីភាគីណាម្ខាងដែលមានសិទ្ធិអំណាចមេបាទៅលើកូនៗ។ អ្នកដែលមានសិទ្ធិអំណាចមេបា គឺសំដៅលើអ្នកដែលមានសិទ្ធិ និងករណីយកិច្ច ត្រូវចិញ្ចឹមបីបាច់ថែរក្សាកូនដែលជាអនីតិជន និងជួយគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូន។ នៅក្នុងការលែងលះតាមការដាក់ពាក្យសុំ ឪពុកម្ដាយអាចពិភាក្សាគ្នាដើម្បីសម្រេចអំពីដែលមានសិទ្ធិអំណាចមេបាទៅលើកូន តុលាការនឹងធ្វើការសម្រេចអំពីសិទ្ធិអំណាចមេបាលើកូន តាមការស្នើសុំរបស់ភាគីដែលបានព្រមព្រៀងគ្នា។[87] ចំពោះការលែងលះតាមការដាក់ពាក្យបណ្ដឹង បើឪពុកម្ដាយគ្មានការព្រមព្រៀងអំពីសិទ្ធិអំណាចមេបាទេ តុលាការនឹងធ្វើការសម្រេចអំពីអ្នកដែលមានសិទ្ធិអំណាចមេបាលើកូន ដោយពិចារណាទៅលើផលប្រយោជន៍របស់កូន។ ប៉ុន្តែប្រសិនបើ កូនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹង និងមានការសម្រេចចិត្តដោយខ្លួនឯង តុលាការនឹងធ្វើការសម្រេចតាមការសម្រេចចិត្តរបស់កូន។ ក្នុងករណីដែល កូននោះមិនទាន់កើត នៅមុនពេលលែងលះគ្នា ម្ដាយជាអ្នកដែលមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។[88] ម្យ៉ាងទៀតបើអ្នកដែលមានអំណាចមេបាចំពោះកូន តាមការពិភាក្សា បានទទួលមរណភាព ប្រសិនបើកូននោះពុំមានអ្នកមានអំណាចមេបាទេ ឪពុកម្ដាយ ដែលពុំមែនជាអ្នកមានអំណាចមេបា ត្រូវក្លាយជាអ្នកមានអំណាចមេបា។[89]

### ៣.៣.២. អាហារកាតព្វកិច្ចចំពោះកូន

ការលែងលះបានធ្វើឱ្យចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ ឪពុក និងម្ដាយក៏ត្រូវបានបែកបាក់គ្នា តែទោះបីជាយ៉ាងនេះក៏ដោយ ឪពុក និងម្ដាយ នៅតែមានកាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូនរហូតដល់កូនមានវ័យនីតិភាព។ ភាគីដែលមិនបានថែរក្សាកូនមានកាតព្វកិច្ច ផ្ដល់អាហារកិច្ចដល់កូនតាមលទ្ធភាពដែលខ្លួនមាន។ អាហារកិច្ច អាចផ្ដល់ជាប្រាក់ ឬជារបស់របរអ្វីមួយ។ ឪពុក ឬម្ដាយ ដែលមានអំណាចមេបាលើកូន ត្រូវមានកាតព្វកិច្ច ត្រូវចិញ្ចឹមបីបាច់មើលថែរក្សាកូន និងជួយគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូន។[90] ចំពោះឪពុក ឬម្ដាយដែលពុំមានអំណាចមេបា ក្រោយពេលដែលបានលែងលះគ្នារួច មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនរបស់ខ្លួនផងដែរ។[91] ដូចនេះក្រោយការលែងលះ ឪពុក ឬម្ដាយដែលបាន លែងលះរួចហើយនោះ គឺនៅតែជាញាតិខ្សែផ្ទាល់របស់កូនជានិច្ច។[92]

---

[87] ក្រមរដ្ឋប្បវេណី មាត្រា១០៣៧ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[88] ក្រមរដ្ឋប្បវេណី មាត្រា១០៣៧ (២) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[89] ក្រមរដ្ឋប្បវេណី មាត្រា១០៥១ (៣) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[90] ក្រមរដ្ឋប្បវេណី មាត្រា១០៣៤ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[91] ក្រមរដ្ឋប្បវេណី មាត្រា១០៤១ (១) ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

[92] ក្រមរដ្ឋប្បវេណី មាត្រា១១៤០ ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជាចុងបញ្ចប់នៃប្រធានបទនេះ គឺការសរុបខ្លឹមសារដែលមាននៅក្នុងប្រធានបទសារណានេះទាំងមូល។ បន្ទាប់ពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទ៖ នីតិវិធីនៃការលែងលះ រួចមក បានបង្ហាញថាមូលហេតុដែលធ្វើឱ្យមានការលែងលះកើតឡើង គឺសហព័ទ្ធបានបាត់បង់នូវមនោសញ្ចេតនាក្នុងការរួមរស់ជាមួយនឹងគ្នា និងការរស់នៅមិនចុះសម្រុងគ្នា ដែលជាហេតុនាំឱ្យមានការលែងលះ។ ភាគីដែលមានបំណងចង់រំលាយនៅចំណងអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យសុំលែងលះ ឬដាក់ពាក្យបណ្តឹងលែងលះទៅតុលាការដែលក្នុងពាក្យសុំ ឬពាក្យបណ្តឹងនោះត្រូវរៀបរាប់នៅមូលហេតុដែលនាំឱ្យមានការទាមទារ ឬសុំលែងលះ តែមូលហេតុទាំងនោះត្រូវតែមានលក្ខណៈសមហេតុផលដូចមាននៅក្នុងក្រមរដ្ឋប្បវេណីដែលបានកំណត់នៅក្នុងមាត្រា ៩៨៧។ តាមរយៈការស្រាវជ្រាវក្នុងប្រធានបទនេះ ការលែងលះនៅក្នុងប្រទេសកម្ពុជា បានចែកចេញជាពីរប្រភេទគឺ ការលែងលះតាមការដាក់ពាក្យសុំ និងការលែងលះតាមការដាក់ពាក្យបណ្តឹង។ ការលែងលះតាមការដាក់ពាក្យសុំ គឺជាការលែងលះដែលសហព័ទ្ធមានឆន្ទៈក្នុងការព្រមព្រៀងគ្នាលែងលះ ហើយថែមទាំងបានព្រមព្រៀងគ្នារួចទាំងស្រុងក្នុងការកំណត់អំពីការបែងចែកទ្រព្យសម្បត្តិ សិទ្ធិ និងកាតព្វកិច្ចផ្សេងៗទៀតក្រោយការលែងលះ។ ការលែងលះតាមការដាក់ពាក្យបណ្តឹង គឺជាការប្តឹងទាមទារលែងលះ ដោយពុំមានការព្រមព្រៀង ឬខ្វែងគំនិតគ្នាទៅលើផ្នែកណាមួយ ឬទាំងស្រុងនៃការបែងចែកទ្រព្យសម្បត្តិ និងការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត ហើយទាមទារឱ្យតុលាការធ្វើការដោះស្រាយ។

ចំពោះនីតិវិធីនៃការដោះស្រាយរឿងក្តីលែងលះ គឺត្រូវបានអនុលោមតាមសៀវភៅនីតិវិធីរដ្ឋប្បវេណី គួបផ្សំនឹងច្បាប់ផ្សេងៗទៀងដែលពាក់ព័ន្ធជាមួយនឹងការលែងលះ។ បទដ្ឋានគតិយុត្តដែលត្រូវអនុលោមរួមជាមួយនឹងក្រមនីតិវិធីរដ្ឋប្បវេណី សម្រាប់ដោះស្រាយការលែងលះមានដូចជា៖ ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១០ សម្រាប់ធ្វើការដោះស្រាយការលែងលះតាមការដាក់ពាក្យសុំ និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០ សម្រាប់ការដោះស្រាយការលែងលះតាមការដាក់ពាក្យបណ្តឹង។ ជាចុងក្រោយ បន្ទាប់ពីតុលាការបានបញ្ចប់នីតិវិធីនៃការលែងលះ តុលាការនឹងចេញដីកាសម្រេច ឬសាលក្រម ដែលបង្កើតឱ្យមានអានុភាពនៃការលែងលះ។

សរុបសេចក្តីមក ការបកស្រាយទាំងអស់ខាងលើនេះ គឺជាការបង្ហាញអំពីលំហូរនីតិវិធីនៃការលែងលះចាប់តាំងពីពេលដែលទំនាក់ទំនងអាពាហ៍ពិពាហ៍នោះកើតមាននៅមូលហេតុដែលបណ្តាលឱ្យមានការលែងលះរហូតដល់ការអនុវត្តនីតិវិធីនៃការលែងលះ និងការចេញសេចក្តីសម្រេចរបស់តុលាការនៃការលែងលះ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានឆ្លងកាត់ការសិក្សាស្រាវជ្រាវពីប្រធានបទ៖ នីតិវិធីនៃការលែងលះ រួចមក នាងខ្ញុំទាំងពីរនាក់យល់ឃើញថាការលែងលះមានលក្ខណៈស្មុគស្មាញជាច្រើន ថែមទាំងបានផ្តល់នូវភាពអវិជ្ជមានដល់សាមីខ្លួនផ្ទាល់ដែលបានធ្វើការលែងលះ ដល់ភាគី និងបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធ ជាពិសេស គឺកូនៗរបស់សហព័ទ្ធដែលបានសម្រេចលែងលះគ្នា។ ហេតុនេះដើម្បីចូលរួមចំណែកពង្រឹងនៅប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជាឱ្យកាន់តែប្រសើរឡើង និងជួយសម្រួលក្នុងការកាត់បន្ថយនៅអត្រានៃលែងលះគ្នាក្នុងសង្គម នាងខ្ញុំទាំងពីរនាក់មានសំណូមពរចំនួន បួន ទាក់ទងនឹងការលែងលះ ដែលនាងខ្ញុំទាំងពីរនាក់គិតថាគួរតែកែលម្អបន្ថែមទៀត ដើម្បីជាប្រយោជន៍ដល់បុគ្គលគ្រប់ៗរូប មានដូចជា៖

សំណូមពរទី១៖ នាងខ្ញុំទាំងពីរនាក់សំណូមពរឱ្យ ប្រជាពលរដ្ឋខ្មែរទាំងអស់ដែលបានរៀបអាពាហ៍ពិពាហ៍ហើយ មានការយោគយល់ ចេះអត់ឱន អធ្យាស្រ័យឱ្យបានច្រើន និងកែតម្រូវគ្នាទៅវិញទៅមក ដើម្បីកសាងគ្រួសារមួយដែលមានសុភមង្គល ព្រោះថាការលែងលះ គឺបានផ្តល់នូវភាពអវិជ្ជមាន និងគុណវិបត្តិជាច្រើនបន្ទាប់ពីបានលែងលះ។

សំណូមពរទី២៖ នាងខ្ញុំទាំងពីរនាក់សំណូមពរឱ្យ សូមឱ្យរាជរដ្ឋាភិបាល ធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឱ្យបានយល់ដឹងគ្រប់ៗគ្នា ជាពិសេសពលរដ្ឋដែលរស់នៅឆ្ងាយពីទីក្រុង ឬដាច់ស្រយោល និងពលរដ្ឋដែលខ្វះខាតក្នុងយល់ដឹងពីការលែងលះ។

សំណូមពរទី៣៖ នាងខ្ញុំទាំងពីរនាក់សំណូមពរដល់មន្ត្រីថ្នាក់មូលដ្ឋាន ដែលពាក់ព័ន្ធនិងរឿងក្តីលែងលះជួយបន្ថែមនូវការផ្សះផ្សាដល់គូភាគីដែលមានបំណងលែងលះ ឱ្យអស់ពីសមត្ថភាពជាមុនសិន មុននិងសម្រេចចិត្តឱ្យគូភាគីធ្វើការលែងលះតាមប្រព័ន្ធតុលាការ។

សំណូមពរទី៤៖ សំណូមពរចុងក្រោយរបស់នាងខ្ញុំទាំងពីរនាក់ គឺសំណូមពរដល់ស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងរឿងក្តីលែងលះ សូមអ្នកដឹកនាំនីតិវិធី និងដោះស្រាយរឿងក្តីលែងលះ ឱ្យបានប្រព្រឹត្តទៅបានលឿន ព្រោះថាបើមានការយឺតយ៉ាវអាចបង្កឱ្យកើតមានគ្រោះថ្នាក់ដល់ភាគីម្ខាងទៀងកាន់តែធ្ងន់ធ្ងរ។

# ឯកសារយោង

# ឯកសារយោង

១. លិខិតបទដ្ឋានគតិយុត្ត

- ❖ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ❖ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ សន/រកម/១០០៥/០៣១ ចុះថ្ងៃទី២៤  ខែតុលា ឆ្នាំ២០០៥។
- ❖ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។
- ❖ ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦។
- ❖ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧។
- ❖ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០។
- ❖ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១០១០។

២. សៀវភៅ

- ❖ សាស្ត្រចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត សៀវភៅជំនួយស្មារតីនីតិគ្រួសារ ឆ្នាំ២០១៧។
- ❖ សាស្ត្រចារ្យ កេត សុជាតិ សៀវភៅជំនួយស្មារតីសង្ខេបលំហូរនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០១៧។
- ❖ សាស្ត្រាចារ្យ អម សុផាណារ៉ាត សៀវភៅជំនួយស្មារតីនីតិរដ្ឋប្បវេណី ឆ្នាំ២០២១-២០២២។

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

## ទម្រង់លិខិតរដ្ឋបាលពាក់ព័ន្ធជាមួយនឹងនីតិវិធីលែងលះ

-ការលែងលះតាមការដាក់ពាក្យសុំ

-បង្កាន់ដៃបង់ប្រាក់

-ពាក្យសុំដីកាសម្រេចលែងលះតាមការព្រមព្រៀង

-ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

-ដីកាកោះ

-កំណត់ហេតុស្ដីពីកាលបរិច្ឆេទនៃការសួរ

-ដីកាសម្រេចរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង

-បង្កាន់ដៃបង់ប្រាក់

-ពាក្យសុំបញ្ជាក់ដីកាសម្រេចចូលជាស្ថាពរ

-លិខិតបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេច

-ការលែងលះតាមការដាក់ពាក្យបណ្ដឹង

-បង្កាន់ដៃបង់ប្រាក់

-ពាក្យបណ្ដឹង

-ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

-ដីកាកោះ

-កំណត់ហេតុស្ដីពីកាលបរិច្ឆេទនៃសាកសួរ

-ដីកាកោះ

-កំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់

-សាលក្រមរដ្ឋប្បវេណី

-បង្កាន់ដៃបង់ប្រាក់

-ពាក្យសុំបញ្ជាក់សាលក្រមចូលជាស្ថាពរ

-ពាក្យសុំរូបមន្តអនុវត្ត

-លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម

# ទម្រង់លិខិតរដ្ឋបាលពាក់ព័ន្ធជាមួយ
# នឹងនីតិវិធីលែងលះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ចូល ថ្ងៃទី 22 ខែ 06 ឆ្នាំ 2022

## ពាក្យសុំដីកាសម្រេចលែងលះតាមការព្រមព្រៀង

**អ្នកដាក់ពាក្យសុំ:** ឈ្មោះ ភេទស្រី ថ្ងៃខែឆ្នាំកំណើត ០៥.ឧសភា.១៩៨១ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវជាតិលេខ២ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ **ជាប្រពន្ធ** ។

**ភាគីម្ខាងទៀត:** ឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០១.មករា.១៩៨០ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវជាតិលេខ២ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ **ជាប្តី** ។

សាលាដំបូងរាជធានីភ្នំពេញ
បទការិយាល័យ
លេខចុះបញ្ជី 00198701
ចុះថ្ងៃ 22 ខែ 06 ឆ្នាំ 2022

### សូមគោរពជូន
### ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

*សូមទានជ្រាប!*

**កម្មវត្ថុ:** សុំឲ្យតុលាការចេញដីកាសម្រេចលែងលះតាមការព្រមព្រៀង ដែលមានខ្លឹមសារដូចខាងក្រោម៖

១. ឱ្យឈ្មោះ និងឈ្មោះ លែងលះគ្នាចាប់ពីពេលនេះតទៅ។

២. ឱ្យឈ្មោះ ជាអ្នកមានអំណាចមេបាលើកូន ឈ្មោះ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ មានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៨ ។

៣. ឱ្យឈ្មោះ បង់អាហារកាតព្វកិច្ចចិញ្ចឹមកូន តាមលទ្ធភាព ។

៤. ទ្រព្យសម្បត្តិរួម និងបំណុលរួម មិនមាននោះទេ។

**យោង:** - សំបុត្រអាពាហ៍ពិពាហ៍លេខ ១១១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩
- កិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីឆ្នាំ២០០៩ យើងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាប្តីប្រពន្ធ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ១១១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩។ ក្នុងចំណងអាពាហ៍-

ពិពាហ៍ការរស់នៅរបស់យើងខ្ញុំមានកូនចំនួន ២(ពីរ) នាក់ ដែល កូនទី១ឈ្មោះ ភេទស្រី កើតថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០១ មានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៨ និងកូនទី ២ ឈ្មោះ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ មានសំបុត្រកំណើតលេខ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ ហើយចំពោះទ្រព្យសម្បត្តិរួម និងបំណុលរួម គឺយើងខ្ញុំមិនមាននោះទេ។

មួយរយៈកន្លងមកនេះការរស់របស់យើងខ្ញុំ ចេះតែមានបញ្ហារកាំរកូស ឈ្លោះប្រកែកគ្នា មានគំនិតមិនស្របគ្នាដែលនាំឱ្យការរស់នៅមិនមានភាពចុះសម្រុង។ កន្លងមកយើងខ្ញុំទាំងពីរនាក់បានព្យាយាមសម្រុះសម្រួលគ្នាដែរតែនៅតែមិនអាចរស់នៅជាមួយគ្នាបាន ជាហេតុធ្វើឱ្យយើងខ្ញុំអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត។ ដូចនេះយើងខ្ញុំទាំងពីរនាក់សម្រេចលែងលះគ្នាតាមការព្រមព្រៀង ដែលបានចុះ**កិច្ចព្រមព្រៀងលែងលះនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២** ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលពាក្យសុំរបស់យើងខ្ញុំដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២

**ស្នាមមេដៃស្តាំ**



<u>ឯកសារភ្ជាប់ជូន (ថតចម្លង)៖</u>

១. កិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០២២ ចំនួន ១ ច្បាប់ (ច្បាប់ដើម)
២. សំបុត្រអាពាហ៍ពិពាហ៍លេខ ១៨ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០០៨ ចំនួន ១ ច្បាប់
៣. អត្តសញ្ញាណប័ណ្ណរបស់ឈ្មោះ ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០១៦ ចំនួន ១ ច្បាប់
៤. អត្តសញ្ញាណប័ណ្ណរបស់ឈ្មោះ ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៣ ចំនួន ១ ច្បាប់
៥. សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតកូនឈ្មោះ លេខ ១២១ ចុះថ្ងៃទី៣១ កក្កដា ឆ្នាំ២០០៨ ចំនួន ១ ច្បាប់
៦. សេចក្តីចម្លងសំបុត្រកំណើតកូនឈ្មោះ លេខ ១១០ ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៨ ចំនួន ១ ច្បាប់

ម៉ូដែលលេខ ០៩ សហវ/ធនធ

260-1- 00517426

MEF20882604121

ក្រសួងយុត្តិធម៌

# បង្កាន់ដៃបង់ប្រាក់

(ប្រគល់ជូនអ្នកបង់ប្រាក់)

អង្គភាព [illegible] .................. អង្គភាព [illegible]

ទទួលពី [illegible]

ចំនួនទឹកប្រាក់ជាលេខ [illegible]

ជាអក្សរ [illegible]

អត្ថន័យចំណូល [illegible] .................. មាតិកាថវិកា [illegible]

MINISTRY OF ECONOMY AND FINANCE

[illegible] ថ្ងៃទី ០១ ខែ ០៣ ឆ្នាំ [illegible]

អ្នកប្រមូលចំណូល

ទៀង សុវណ្ណារ៉ា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ៖ ៩០ "ក" វ.វ

# ដីកាសម្រេច
## បង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

យើង **តាំង ស៊ុនឡាយ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**បានឃើញ** មាត្រា **៦២** កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង លេខ ១១១៦ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ដែលមាន៖

**-អ្នកដាក់ពាក្យសុំ៖** លោកស្រី កើតថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៨១ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវជាតិលេខ២ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**-និងភាគីម្ខាងទៀត៖** លោក កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨០ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវជាតិលេខ២ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**-កម្មវត្ថុ៖ សុំដីកាសម្រេចលែងលះតាមការព្រមព្រៀង។**

## សំអាងហេតុ

**អ្នកដាក់ពាក្យសុំ** មិនទាន់បានបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធសម្រាប់បញ្ជូនឯកសារ ដែលធ្វើឱ្យតុលាការមិនអាចចាត់ការតាមនីតិវិធីបាន។

## ហេតុដូច្នេះសម្រេច

-បង្គាប់ឱ្យអ្នកដាក់ពាក្យសុំលោកស្រី បង់ប្រាក់សម្រាប់បញ្ជូនឯកសារចំនួន **១០០,០០០៛ (ដប់ម៉ឺនរៀល)** នៅសាលាដំបូងរាជធានីភ្នំពេញឱ្យបានមុន **ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២** ជាកំណត់ ដើម្បីតុលាការចាត់ការរឿងក្ដីនេះតាមច្បាប់។

ថ្ងៃសុក្រ ៣កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២

**ចៅក្រម**

តាំង ស៊ុនឡាយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាកោះ

យើង ( ) ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

អញ្ជើញឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៦៥ ជាអ្នកដាក់ពាក្យសុំ។
អាសយដ្ឋាន៖ផ្លូវជាតិលេខ៦ ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
Tel:017 917 637

| | |
|---|---|
| សញ្ញាណនៃរឿងក្តី និងភាគី: | -សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹងលេខ:១៨៦៩ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣<br>-រឿងក្តី: សុំដីកាសម្រេចលែងលះតាមការព្រមព្រៀង<br>-អ្នកដាក់ពាក្យសុំឈ្មោះ , ភេទប្រុស<br>-ភាគីម្ខាងទៀតឈ្មោះ ភេទស្រី |
| កាលបរិច្ឆេទ និង ទីកន្លែងដែលត្រូវបង្ហាញខ្លួន: | ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ៣០នាទីព្រឹក<br>នៅសាលាដំបូងរាជធានីភ្នំពេញ បន្ទប់ "ថ" ជាន់ទី៣ |
| ប្រភេទដំណាក់កាលនៃនីតិវិធី " សំគាល់ដោយសញ្ញា ☐ " | ដើម្បីចូលរួមក្នុងនីតិវិធី:<br>☐-ត្រៀមសម្រាប់ការទាញហេតុផល ☐-ទាញហេតុផលដោយផ្ទាល់មាត់<br>☑-សាកសួរ ☐-ការប្រកាសសាលក្រម |
| ប្រភេទនៃឯកសារដែលភ្ជាប់មកជាមួយ(សូមសរសេរបញ្ជាក់ឈ្មោះឯកសារ បើចាំបាច់ឲ្យកាន់មក) | ..................................................<br>..................................................<br>.................................................. |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | ១-បើដើមចោទមិនបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទ ដោយសាលក្រមកំបាំងមុខ តាមមាត្រា ២០០ កថាខណ្ឌទី១ នៃក្រមនីតិវិធី រដ្ឋប្បវេណី។<br>២-បើចុងចម្លើយមិនបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលភ្លាម ហើយកំណត់កាលបរិច្ឆេទលើកទី១ នៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តាមបញ្ញត្តិមាត្រា ២០១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ |

សូមបង្ហាញខ្លួនដូចដែលបានកំណត់ខាងលើ។

ថ្ងៃអង្គារ ៧រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៣
ចៅក្រម

**បញ្ជាក់៖**
-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងៗទៀតដែលមិនអាចបង្ហាញខ្លួនបាន សូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុនោះជូនតុលាការ។
-ពេលបង្ហាញខ្លួន សូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
លេខ៖ ១១១៦ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២

## កំណត់ហេតុ
## ស្តីពីកាលបរិច្ឆេទនៃការសួរ

| | | |
|---|---|---|
| កាលបរិច្ឆេទ | ៖ | ឆ្នាំពីរពាន់ម្ភៃពីរ ខែកញ្ញា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោង ដប់បួន និង សូន្យនាទីរសៀល |
| ទីកន្លែង | ៖ | សាលាដំបូងរាជធានីភ្នំពេញ ជាន់ទី៤ បន្ទប់ "ក" |
| ចៅក្រម | ៖ | លោក **តាំង ស៊ុនឡាយ** |
| ក្រឡាបញ្ជី | ៖ | លោកស្រី **ថូ រតនា** |

**ភាគីក្នុងសំណុំរឿង៖**

**-អ្នកដាក់ពាក្យសុំ៖** លោកស្រី កើតថ្ងៃទី ខែឧសភា ឆ្នាំ១៩៨១ ជនជាតិខ្មែរ មុខរបរ លក់ដូរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែមករា ឆ្នាំ២០១៣ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវជាតិលេខ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**-មេធាវីតំណាងដោយអាណត្តិ៖** លោក អត្តលេខ ជាមេធាវីនៃការិយាល័យមេធាវី មានទីតាំងស្ថិតនៅអាគារលេខ ជាន់ទី៣ ផ្លូវលេខ១១៣ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

**-និងភាគីម្ខាងទៀត៖** លោក កើតថ្ងៃទី ខែមករា ឆ្នាំ១៩៨០ ជនជាតិខ្មែរ មុខរបរ នគរបាល កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវជាតិលេខ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**<u>កម្មវត្ថុនៃពាក្យសុំ៖</u>**

១-ស្នើសុំឱ្យមានការសម្រេចឱ្យភាគីអ្នកដាក់ពាក្យសុំលោកស្រី និងភាគីម្ខាងទៀតលោក លែងលះតាមការព្រមព្រៀង។

២-ស្នើសុំកំណត់យកលោកស្រី ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ ភេទប្រុស កើតថ្ងៃទី ខែកក្កដា ឆ្នាំ២០០៨។

### ខ្លឹមសារនៃការសាកសួរ

**-ភាគីអ្នកដាក់ពាក្យសុំ៖ លោកស្រី** ថ្លែងការណ៍ថា នាងខ្ញុំបានរៀបការជាមួយភាគីម្ខាងទៀតលោក កាលអំឡុងឆ្នាំ២០០៧ ដោយមានចុះសំបុត្រអាពាហ៍ពិពាហ៍ លេខ ១១១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។ ការរស់នៅជាមួយគ្នាបង្កើតបានកូនពីរនាក់

មានឈ្មោះ ភេទស្រី កើតថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០១ មានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៨ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងកូនឈ្មោះ

ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ មានសំបុត្រកំណើត លេខ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ ២០០៨ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ដោយមូលហេតុថា នៅរយៈពេលប្រហែលបួនទៅប្រាំឆ្នាំចុងក្រោយនេះ ការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធពុំទទួលបានសេចក្ដីសុខ មានការមិនយល់ចិត្តគ្នា ទាស់សំដីគ្នា រហូតធ្វើឱ្យពួកខ្ញុំអស់មនោសញ្ចេតនាជាប្ដីប្រពន្ធ ទើបពួកខ្ញុំពិភាក្សាគ្នាអំពីការលែងលះតាមការព្រមព្រៀង។ នៅក្នុងកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ ពួកខ្ញុំបានព្រមព្រៀងកំណត់យករូបនាងខ្ញុំជាអ្នកមានអំណាចមេបាលើកូនប្រុសឈ្មោះ ដែលទើបតែមានអាយុ១៤ឆ្នាំ ចំពោះកូនស្រីឈ្មោះ គាត់មានអាយុ២១ឆ្នាំហើយ គាត់មានសិទ្ធិទៅរស់នៅជាមួយឪពុកគាត់ក៏បាន រស់នៅជាមួយនាងខ្ញុំជាម្ដាយក៏បាន ដូចមានកំណត់ក្នុងប្រការ២ នៃកិច្ចព្រមព្រៀងលែងលះ។ តាមប្រការ៣ នៃកិច្ចព្រមព្រៀងលែងលះ បានកំណត់អំពីប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូន និងការកំណត់អំពីការចូលជួបប្រាស្រ័យទាក់ទងកូន ដោយភាគីម្ខាងទៀតផ្ដល់ប្រាក់ចិញ្ចឹមកូនតាមលទ្ធភាព និងមានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងកូនបានគ្រប់ពេល។ ក្នុងចំណងអាពាហ៍ពិពាហ៍ពុំមានទ្រព្យសម្បត្តិរួម និងបំណុលរួមនោះទេ ដូចមានការទទួលស្គាល់ក្នុងកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០២២។

**-ភាគីម្ខាងទៀត៖ លោក** **ថ្លែងការណ៍តបថា** ខ្ញុំបាទឯកភាពលែងលះតាមការស្នើសុំរបស់ភាគីអ្នកដាក់ពាក្យសុំលោកស្រី ។ ខ្ញុំបាទឯកភាពតាមការថ្លែងការណ៍ខាងលើរបស់ភាគីអ្នកដាក់ពាក្យសុំទាំងស្រុង។ ដោយសារតែការរួមរស់នៅជាមួយគ្នាពុំទទួលបានសេចក្ដីសុខ ទើបពួកខ្ញុំពិភាក្សាគ្នាអំពីការលែងលះតាមការព្រមព្រៀង។ ខ្ញុំបាទយល់ព្រមប្រគល់កូនប្រុសឈ្មោះ ឱ្យទៅភាគីអ្នកដាក់ពាក្យសុំធ្វើជាអ្នកមានអំណាចមេបា គ្រប់គ្រងកូន ដូចមានការព្រមព្រៀងក្នុងប្រការ២ នៃកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ ចំពោះកូនស្រីឈ្មោះ គាត់មានវ័យនីតិភាពហើយ គាត់មានសិទ្ធិក្នុងការសម្រេចចិត្តរស់នៅជាមួយម្ដាយគាត់ក៏បាន រស់នៅជាមួយខ្ញុំបាទជាឪពុកក៏បាន។ ក្នុងចំណងអាពាហ៍ពិពាហ៍គ្មានទ្រព្យសម្បត្តិរួម និងបំណុលបំណុលដែលត្រូវបែងចែកនោះទេ។

**-មេធាវីតំណាងដោយអាណត្តិឱ្យភាគីអ្នកដាក់ពាក្យសុំ៖ លោក** **ថ្លែងការណ៍ថា** ខ្ញុំបាទឯកភាពតាមការថ្លែងការណ៍របស់កូនក្ដីខ្ញុំបាទ ដោយហេតុថា គូភាគីមានឆន្ទៈលែងលះដោយស្ម័គ្រចិត្តប្រាកដមែន។ ស្នើសុំឱ្យតុលាការសម្រេចឱ្យគូភាគីបានលែងលះគ្នាតាមការព្រមព្រៀង និងកំណត់អំពីសិទ្ធិអំណាចមេបាលើកូនមកឱ្យកូនក្ដីខ្ញុំបាទតាមការស្នើសុំ។

**បញ្ចប់កំណត់ហេតុត្រឹមវេលាម៉ោង ដប់ប្រាំ និងសូន្យនាទីរសៀល នៅថ្ងៃខែឆ្នាំដដែល។**

| **អ្នកដាក់ពាក្យសុំ** | **ភាគីម្ខាងទៀត** | **មេធាវី** | **ក្រឡាបញ្ជី** | **ចៅក្រម** |
|---|---|---|---|---|
| | | | **ជួ រតនា** | **តាំង ស៊ីនឡាយ** |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី
ដែលមិនមែនជាបណ្ដឹង លេខ ១១១៦
ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២
ដីកាសម្រេចលេខ ១៣២៨ "ក" ដ.ម
ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២

## ដីកាសម្រេច

## រឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

យើង **តាំង ស៊ុនឡាយ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**បានឃើញ** មាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០។

**បានឃើញ** មាត្រា ៩៧៩ និងមាត្រាពាក់ព័ន្ធ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង លេខ ១១១៦ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ដែលមាន៖

**-អ្នកដាក់ពាក្យសុំ៖** លោកស្រី កើតថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៨១ ជនជាតិខ្មែរ មុខរបរ លក់ដូរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវជាតិលេខ២ ភូមិព្រៃកគាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**-មេធាវីតំណាងដោយអាណត្តិ៖** លោក អត្តលេខ ជាមេធាវីនៃការិយាល័យមេធាវី មានទីតាំងស្ថិតនៅអាគារលេខ ជាន់ទី៣ ផ្លូវលេខ១១៣ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

**-និងភាគីម្ខាងទៀត៖** លោក កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨០ ជនជាតិខ្មែរ មុខរបរ នគរបាល កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវជាតិលេខ២ ភូមិព្រៃកគាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

## អង្គហេតុ

**១-ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឱ្យតុលាការចេញ**

១.១- ស្នើសុំដីកាសម្រេចឱ្យភាគីអ្នកដាក់ពាក្យសុំលោកស្រី ។ និងភាគីម្ខាងទៀតលោក លែងលះតាមការព្រមព្រៀង។

១.២- ស្នើសុំកំណត់យកលោកស្រី ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨។

**២-ដំណើររឿងក្ដី**

-ភាគីអ្នកដាក់ពាក្យសុំលោកស្រី និងភាគីម្ខាងទៀតលោក បានរៀបអាពាហ៍ពិពាហ៍កាលពីឆ្នាំ២០០៧ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ លេខ ១១១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ចេញដោយមន្ត្រី

អគ្រានុកូលដ្ឋានសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។ ក្នុងរយៈពេលរួមរស់នៅជាមួយគ្នាពុំទទួលបានសេចក្ដីសុខ មានការឈ្លោះប្រកែកគ្នា ធ្វើឱ្យគូភាគីអស់មនោសញ្ចេតនាជាប្ដីប្រពន្ធ ហើយគូភាគីបានពិភាក្សាគ្នាអំពីការលែងលះដោយស្ម័គ្រចិត្ត ដូចមានក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២។

**<u>៣-អង្គហេតុដែលអះអាងដោយភាគីអ្នកដាក់ពាក្យសុំ</u>**

**-អ្នកដាក់ពាក្យសុំ៖ លោកស្រី បានអះអាងដូចទៅនឹងចំណុច២ ស្ដីពីការពន្យល់គ្រួសារអំពីរឿងក្ដី និងបានបន្ថែមទៀតថា** ខ្លួនបានរៀបការជាមួយភាគីម្ខាងទៀតលោក កាលអំឡុងឆ្នាំ២០០៧ ដោយមានចុះសំបុត្រអាពាហ៍ពិពាហ៍ លេខ ១១១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។ ការរស់នៅជាមួយគ្នាបង្កើតបានកូនពីរនាក់ មានឈ្មោះ ភេទស្រី កើតថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០១ មានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៨ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងកូនឈ្មោះ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ មានសំបុត្រកំណើត លេខ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៨ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ដោយមូលហេតុថា នៅរយៈពេលប្រហែលបួនទៅប្រាំឆ្នាំចុងក្រោយនេះ ការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធពុំទទួលបានសេចក្ដីសុខ មានការមិនយល់ចិត្តគ្នា ទាស់សំដីគ្នា រហូតធ្វើឱ្យពួកខ្លួនអស់មនោសញ្ចេតនាជាប្ដីប្រពន្ធ ទើបពួកខ្លួនពិភាក្សាគ្នាអំពីការលែងលះតាមការព្រមព្រៀង។ នៅក្នុងកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ ពួកខ្លួនបានព្រមព្រៀងកំណត់យករូបខ្លួនជាអ្នកមានអំណាចមេបាលើកូនប្រុសឈ្មោះ ដែលទើបតែមានអាយុ១៤ឆ្នាំ ចំពោះកូនស្រីឈ្មោះ គាត់មានអាយុ២១ឆ្នាំហើយ គាត់មានសិទ្ធិទៅរស់នៅជាមួយឪពុកគាត់ក៏បាន រស់នៅជាមួយខ្លួនជាម្ដាយក៏បាន ដូចមានកំណត់ក្នុងប្រការ២ នៃកិច្ចព្រមព្រៀងលែងលះ។ តាមប្រការ៣ នៃកិច្ចព្រមព្រៀងលែងលះ បានកំណត់អំពីប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូន និងការកំណត់អំពីការចូលជួបប្រាស្រ័យទាក់ទងកូន ដោយភាគីម្ខាងទៀតផ្ដល់ប្រាក់ចិញ្ចឹមកូនតាមលទ្ធភាព និងមានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងកូនបានគ្រប់ពេល។ ក្នុងចំណងអាពាហ៍ពិពាហ៍ពុំមានទ្រព្យសម្បត្តិរួម និងបំណុលរួមនោះទេ ដូចមានការទទួលស្គាល់ក្នុងកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២។

**<u>៤-អង្គហេតុដែលអះអាងដោយភាគីម្ខាងទៀត</u>**

**-ភាគីម្ខាងទៀត៖ លោក បានថ្លែងការណ៍តបថា** ខ្លួនឯកភាពលែងលះតាមការស្នើសុំរបស់ភាគីអ្នកដាក់ពាក្យសុំលោកស្រី ខ្លួនឯកភាពតាមការថ្លែងការណ៍ខាងលើរបស់ភាគីអ្នកដាក់ពាក្យសុំទាំងស្រុង។ ដោយសារតែការរួមរស់នៅជាមួយគ្នាពុំទទួលបានសេចក្ដីសុខ ទើបពួកខ្លួនពិភាក្សាគ្នាអំពីការលែងលះតាមការព្រមព្រៀង។ ខ្លួនយល់ព្រមប្រគល់កូនប្រុសឈ្មោះ ឱ្យទៅភាគីអ្នកដាក់ពាក្យសុំធ្វើជាអ្នកមានអំណាចមេបា គ្រប់គ្រងកូន ដូចមានការព្រមព្រៀងក្នុងប្រការ២ នៃកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ ចំពោះកូនស្រីឈ្មោះ គាត់មានវ័យនីតិភាពហើយ គាត់មានសិទ្ធិក្នុងការសម្រេចចិត្តរស់នៅជាមួយម្ដាយគាត់ក៏បាន រស់នៅជាមួយខ្លួនជាឪពុកក៏បាន។ ក្នុងចំណងអាពាហ៍ពិពាហ៍គ្មានទ្រព្យសម្បត្តិរួម និងបំណុលបំណុលដែលត្រូវបែងចែកនោះទេ។

**<u>៥-អង្គហេតុដែលអះអាងដោយមេធាវីតំណាងដោយអាណត្តិឱ្យភាគីអ្នកដាក់ពាក្យសុំ</u>**

**-មេធាវីតំណាងដោយអាណត្តិ៖ លោក បានថ្លែងការណ៍ថា** ខ្លួនឯកភាពតាមការថ្លែងការណ៍របស់កូនក្ដីខ្លួន ដោយហេតុថា គូភាគីមានឆន្ទៈលែងលះដោយស្ម័គ្រចិត្តប្រាកដមែន។ ស្នើសុំឱ្យតុលាការសម្រេចឱ្យគូភាគីបានលែងលះគ្នាតាមការព្រមព្រៀង និងកំណត់អំពីសិទ្ធិអំណាចមេបាលើកូនមកឱ្យកូនក្ដីខ្លួនតាមការស្នើសុំ។

## ការពិនិត្យភស្តុតាង

១-ភស្តុតាងជាឯកសាររបស់អ្នកដាក់ពាក្យសុំ

-កិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២។

-សំបុត្រអាពាហ៍ពិពាហ៍ លេខ ១១១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

-សំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៥ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ លើឈ្មោះ

-សំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៥ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ លើឈ្មោះ

-សំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ លើឈ្មោះ

-សំបុត្រកំណើត ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ លើឈ្មោះ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ លើឈ្មោះ

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ លើឈ្មោះ

## សំអាងហេតុ

១-តាមសេចក្តីថ្លែងការណ៍របស់អ្នកដាក់ពាក្យសុំលោកស្រី និងភាគីម្ខាងទៀតលោក នាពេលសាកសួរ ព្រមទាំងសំបុត្រអាពាហ៍ពិពាហ៍លេខ ១១១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល បានបង្ហាញឱ្យឃើញថា រវាងលោក និងលោកស្រី

ពិតជាប្តីប្រពន្ធស្របច្បាប់ ដែលបានរៀបអាពាហ៍ពិពាហ៍ និងទទួលស្គាល់ដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ប្រាកដមែន។

២-បន្ទាប់ពីបានស្តាប់នូវការអះអាងរបស់ភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត ព្រមទាំងមូលហេតុដែលឈានដល់ការព្រមព្រៀងលែងលះ តុលាការយល់ឃើញថា អាពាហ៍ពិពាហ៍រវាងលោកស្រី និងលោក ពិតជាបានបែកបាក់មិនអាចធ្វើបដិសន្ធានវិញបាន ហើយភាគីទាំងពីរមានឆន្ទៈពិតប្រាកដក្នុងការលែងលះតាមការព្រមព្រៀងមែន ទោះបីជាតុលាការបានខិតខំផ្សះផ្សាយ៉ាងណាក៏ដោយ ភាគីនៅតែទាមទារតុលាការឱ្យសម្រេចអំពីការលែងលះដដែល គប្បីតុលាការពិនិត្យ និងសម្រេចអំពីការលែងលះនេះតាមបញ្ញត្តិមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

៣-នាពេលសាកសួរ អ្នកដាក់ពាក្យសុំលោកស្រី និងភាគីម្ខាងទៀតលោក បានធ្វើសេចក្តីថ្លែងការណ៍ទៀតថា ក្នុងចំណងអាពាហ៍ពិពាហ៍ អ្នកទាំងពីរបានផ្តល់កំណើតកូនពីរនាក់ មានឈ្មោះ ភេទស្រី កើតថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០១ មានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៨ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងកូនឈ្មោះ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ មានសំបុត្រកំណើត លេខ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៨ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឃើញថា តាមសំបុត្រកំណើតកូន ពិតជាមានឪពុកឈ្មោះ និងម្តាយឈ្មោះ ប្រាកដមែន ហើយដែលកូនឈ្មោះ ភេទស្រី មានវ័យនីតិភាព

ហើយចំពោះកូនឈ្មោះ ង នៅពុំទាន់មានវ័យនីតិភាពនៅឡើយ។

៤-គូភាគីបានព្រមព្រៀងគ្នាក្នុងការកំណត់យកលោកស្រី ា ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ង ដូចមានកំណត់ក្នុងប្រការ២ នៃកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២។ ក្នុងនោះដែរ គូភាគីមិនបានកំណត់អំពីពេលវេលាក្នុងការចូលជួបប្រាស្រ័យទាក់ទងកូន និងមិនបានកំណត់អំពីសោហ៊ុយចាំបាច់ក្នុងការចិញ្ចឹមកូនទេ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៥-នាពេលសាកសួរ គូភាគីបានអះអាងប្រហាក់ប្រហែលគ្នាថា ក្នុងចំណងអាពាហ៍ពិពាហ៍ពួកខ្លួនពុំមានទ្រព្យសម្បត្តិរួម និងបំណុលរួម ដែលត្រូវបែងចែកនោះទេ។

៦-តាមបញ្ញត្តិមាត្រា ២២ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង បានកំណត់ថា ពន្ធដាក់ពាក្យសុំ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងប្រាក់ប្រដាប់ក្តីភាគី គឺជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ។ ហេតុដូចនេះ គប្បីតុលាការពិចារណា និងសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីទៅតាមការកំណត់របស់ច្បាប់។

## សេចក្តីសម្រេចបញ្ចប់

១-ឱ្យអ្នកដាក់ពាក្យសុំលោកស្រី ។ កើតថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៨១ និងភាគីម្ខាងទៀត លោក ។ កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨០ លែងលះតាមការព្រមព្រៀង។

២-កំណត់យកលោកស្រី ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨។

ភាគីដែលពុំមានសិទ្ធិអំណាចមេបា មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូន ហើយភាគីដែលមានសិទ្ធិអំណាចមេបា ត្រូវបង្កភាពងាយស្រួលដល់ភាគីម្ខាងទៀត តាមការពិភាក្សាជាក់ស្តែង។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ។

***ភាគីមានសិទ្ធិប្តឹងជំទាស់នឹងដីកាសម្រេចនេះក្នុងរយៈពេលកំណត់ដោយច្បាប់។***

**ចៅក្រម**
**ហត្ថលេខា និងត្រា៖ តាំង ស៊ុនឡាយ**

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃចន្ទ ៨កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២
**ក្រឡាបញ្ជី**
ថូ វតនា

**បានឃើញ**
**ចៅក្រម**
តាំង ស៊ុនឡាយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ចូល ថ្ងៃទី...២០...ខែ...១០...ឆ្នាំ២០២២

**ពាក្យសុំបញ្ជាក់ដីកាសម្រេចចូលជាស្ថាពរ**

នាងខ្ញុំឈ្មោះ: កើតឆ្នាំ ១៩៨១ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ផ្លូវជាតិលេខ ២ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាអ្នកដាក់ពាក្យសុំ ក្នុងសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ១១១៦ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

សាលាដំបូងរាជធានីភ្នំពេញ
បង់ពន្ធ
... ២០២២...
ថ្ងៃទី...២០...ខែ...១០...ឆ្នាំ២០២២

**សូមគោរពជូន**

**ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

*សូមមេត្តាជ្រាប!*

**កម្មវត្ថុ ៖** ស្នើសុំបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេចលេខ ១៣២៨ "ក"ដ.ម ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង៖**- សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ១១១៦ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

- ដីកាសម្រេចលេខ ១៣២៨ "ក" ដ.ម ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ១១១៦ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ តុលាការបានចេញដីកាសម្រេចលេខ ១៣២៨ "ក"ដ.ម ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ហើយដីកាសម្រេចខាងលើបានចូលជាស្ថាពរតាមផ្លូវច្បាប់ហើយ។ ដូច្នេះ នាងខ្ញុំស្នើសុំតុលាការមេត្តាបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេចខាងលើនេះ ដើម្បីអាចយកទៅប្រើប្រាស់តាមផ្លូវច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាសម្រេចតាមការស្នើសុំរបស់នាងខ្ញុំ ដើម្បីឱ្យនាងខ្ញុំបានយកទៅប្រើប្រាស់តាមផ្លូវច្បាប់ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ១០ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២០... ខែតុលា ឆ្នាំ២០២២

**ស្នាមមេដៃស្តាំ**

គំរូលេខ ០៩ សហវ/ខមព

260-1- 00202203

MEF20882604121

ក្រសួងយុត្តិធម៌

# បង្កាន់ដៃបង់ប្រាក់

(ប្រគល់ជូនអ្នកបង់ប្រាក់)

អង្គភាព..........

ទទួលពី .......... ..........អង្គភាព..........

ចំនួនទឹកប្រាក់ជាលេខ ..........

ជាអក្សរ ..........

អត្ថន័យចំណូល..........មាតិកាថវិកា..........

..........ថ្ងៃទី 20 ខែ 10 ឆ្នាំ 2022

អ្នកប្រមូលចំណូល

MINISTRY OF ECONOMY AND FINANCE

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ: ១៩២៨ "ក" ល.ស.ព

## លិខិតបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេច

យើង ថុ រតនា ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា ៣៧ នៃច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង លេខ ១១១៦ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង លេខ ១៣២៨ "ក" ដ.ម ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ របាយការណ៍អំពីការបញ្ជូនដីកាសម្រេចរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២ ឱ្យលោកស្រី  ជាភាគីអ្នកដាក់ពាក្យសុំ។

-បានឃើញ របាយការណ៍អំពីការបញ្ជូនដីកាសម្រេចរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ ឱ្យលោ  ន ជាភាគីម្ខាងទៀត។

-បានឃើញ ពាក្យសុំបញ្ជាក់ដីកាសម្រេចចូលជាស្ថាពរ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ របស់លោកស្រី  ជាភាគីអ្នកដាក់ពាក្យសុំ។

-បានឃើញ បង្កាន់ដៃបង់ប្រាក់ លេខ ២៦០-១-០០២០២២០៣ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

### សូមបញ្ជាក់ថា

១-ដីកាសម្រេចរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង លេខ ១៣២៨ "ក" ដ.ម ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ **បានចូលជាស្ថាពរ ចាប់ពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ រួចហើយ។**

២-លិខិតបញ្ជាក់នៃការចូលជាស្ថាពរនៃដីកាសម្រេចនេះ ចេញឱ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់។

ថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

ថុ រតនា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

ថ្ងៃទី 16 ខែ 11 ឆ្នាំ 2020

# ពាក្យបណ្តឹង

**<u>ដើមចោទ:</u>** ឈ្មោះ ភេទស្រី អាយុ ៣៩ ឆ្នាំ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ទីលំនៅបច្ចុប្បន្នផ្ទះលេខ --- ផ្លូវលេខ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ (ជាប្រពន្ធ)។

**<u>ចុងចម្លើយ:</u>** ឈ្មោះ ភេទប្រុស អាយុ ៥១ ឆ្នាំ ជនជាតិខ្មែ សញ្ជាតិអាមេរិក ទីលំនៅបច្ចុប្បន្នផ្ទះលេខ --- ផ្លូវលេខ --- ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ( ជាប្តី )។

... 000.35064

16 ខែ 11 ឆ្នាំ 2020

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

## I. ខ្លឹមសារនៃសាលក្រមដែលទាមទារឲ្យតុលាការចេញ៖

១. ឱ្យនាងខ្ញុំឈ្មោះ កែវ សំអាត ះជាមួយប្តីឈ្មោះ តាមផ្លូវច្បាប់

## II. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ៖

នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៤ នាងខ្ញុំ និងឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ដែលមានលេខៈ១៥៣ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤។ ចាប់តាំងពីយើងខ្ញុំទាំងពីរនាក់រស់នៅជាប្តីប្រពន្ធមកគឺយើងរស់នៅដោយមានសុភមង្គល ហើយការរស់នៅរបស់យើងខ្ញុំគឺមិនមានកូន ឬទ្រព្យសម្បត្តិ និងបំណុលរួមគ្នានោះទេ។ នៅក្នុងកំឡុងចុងឆ្នាំ២០១៤ ការរស់នៅរវាងយើងខ្ញុំទាំងពីរនាក់ចាប់ផ្តើមមានបញ្ហារកាំរកូស មិនចុះសម្រុងនឹងគ្នា ដោយមានការខ្វែងគំនិតគ្នាជារឿយៗ ក្រោយមកឈ្មោះ ក៏បានចុះចោលផ្ទះ បាត់ដំណឹង ដោយនាងខ្ញុំមិនដឹងថាគាត់ទៅរស់នៅកន្លែងណានៅរស់ ឬក៏ស្លាប់នោះទេ ព្រោះគាត់បានចុះចោលផ្ទះ និងចុះចោលនាងខ្ញុំអស់រយៈពេលជិត០៦ (ប្រាំមួយ) ឆ្នាំ មកហើយ ដែលជាហេតុនាំឲ្យនាងខ្ញុំ អស់មនោសញ្ចេតនាក្នុងការរងចាំ និងរួមរស់ជាមួយគាត់តទៅ

ទៀត។ ដូចនេះទើបនាងខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេចឱ្យនាងខ្ញុំ និងប្តីឈ្មោះ បានលែងលះនឹងគ្នាតាមផ្លូវច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវពាក្យបណ្តឹងរបស់នាងខ្ញុំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ថ្ងៃពុធ ១១រោច ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០២០
**ស្នាមមេដៃស្តាំ**



ឯកសារភ្ជាប់៖
- សំបុត្រអាពាហ៍ពិពាហ៍លេខ:១៥៣ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤
- ពាក្យបណ្តឹងរបស់ឈ្មោះ ឡ ប្តឹងពីឈ្មោះ រ ចុះ
 ចោលផ្ទះដោយគ្មានមូលហេតុ នៅសាលាសង្កាត់ភ្នំពេញថ្មី ចុះថ្ងៃទី

គំរូលេខ ០១ សហវ/បមក

260-1- 00035064

MEF18000115954

ក្រសួងយុត្តិធម៌

# បង្កាន់ដៃបង់ប្រាក់

(ប្រគល់ជូនអ្នកបង់ប្រាក់)

អង្គភាព [illegible]

ទទួលពី ........................ អង្គភាព [illegible]

ចំនួនទឹកប្រាក់ជាលេខ ៥៥,០០០៛

ជាអក្សរ [illegible]

អត្ថន័យចំណូល [illegible] មាតិកាថវិកា ៧០២៤

[illegible] ថ្ងៃទី ១៦ ខែ ១១ ឆ្នាំ ២០២០

អ្នកប្រមូលចំណូល

អេង សុវណ្ណារ៉ា

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បន្ទប់ "គ" ជាន់ទី៤

ផាង ណាងសេង

សាលាដំបូងរាជធានីភ្នំពេញ

លេខ ..១១៣..... "គ" រ.វ

## ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

យើង **គី ឫទ្ធិ** អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ មាត្រា៦២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ១៧៥៣ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមាន៖

**ដើមចោទ៖** ឈ្មោះ ភេទស្រី ជនជាតិខ្មែរ អាយុ៣៩ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ - ផ្លូវ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**ចុងចម្លើយ៖** ភេទ ប្រុស អាយុ៥១ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ផ្លូវ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**កម្មវត្ថុនៃបណ្តឹងសុំ៖** សុំលែងលះ

### សំអាងហេតុ

-ដើម្បីដំណើរការនីតិវិធីបណ្តឹងទៅតាមច្បាប់។

-ដើម្បីឱ្យតុលាការធ្វើការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងៗទៀតតាមនីតិវិធីបណ្តឹងរដ្ឋប្បវេណី។

### ហេតុដូច្នេះសម្រេច

បង្គាប់ឱ្យដើមចោទឈ្មោះ ភេទស្រី ជនជាតិខ្មែរ អាយុ៣៩ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។ បង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ចំនួន ១៥០,០០០ ៛ (ដប់ប្រាំម៉ឺន) រៀល នៅសាលាដំបូងរាជធានីភ្នំពេញ គិតចាប់ពីថ្ងៃទទួលបានដីកាសម្រេចនេះ រយៈពេល ១៥ ថ្ងៃជាកំណត់ ដើម្បីតុលាការចាត់ការរឿងក្តីនេះតាមច្បាប់។

ថ្ងៃព្រហស្បតិ៍ ១១ កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២៨.... ខែវិច្ឆិកា ឆ្នាំ២០២០

**អនុប្រធានសាលាដំបូង**

បានទទួល

ថ្ងៃទី..........ខែ.............ឆ្នាំ២០២០

ស្នាមមេដៃ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីលេខ: ១៧៥៣

ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០

## ដីកាកោះ

### យើង គី មុន្នី អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

អញ្ជើញដើមចោទ ឈ្មោះ ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ។

អាសយដ្ឋានផ្ទះលេខ ផ្លូវលេខ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ឱ្យចូលទៅកាន់សាលាដំបូងរាជធានីភ្នំពេញ បន្ទប់ (ត) (ជាន់ទី៤) នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ២:៣០ រសៀល។

ដើម្បី ៖ ចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

ពីដំណើររឿង ៖ ប្ដឹងសុំលែងលះ។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងរឿងក្ដីលើមកជាមួយផង ប្រសិនបើមាន ។

ថ្ងៃអង្គារ ៣កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១

អនុប្រធានសាលាដំបូង

គី មុន្នី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**<u>កំណត់ហេតុស្តីពីនីតិវិធីត្រៀមសំរាប់ការទាញហេតុផលលើកទី១</u>**

(មាត្រា១១០ និង មាត្រា១១៣)

សំណុំរឿងរដ្ឋប្បវេណីរឿងក្តីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៣

សញ្ញាណនៃរឿងក្តី **ប្តឹងសុំសាលក្រមលែងលះប្រពន្ធ**

កាលបរិច្ឆេទ ទី០៦ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ០៩ និង៣០ នាទីព្រឹក

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

លោក ក្រឡាបញ្ជី

*ភាគីដែលបានបង្ហាញខ្លួន*

-ដើមចោទ៖ ឈ្មោះ ភេទប្រុស កើតថ្ងៃទី ខែមិថុនា ឆ្នាំ១៩៩៦ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ មានអាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ផ្លូវលេខ ភូមិ៨ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-អ្នកតំណាងដោយអាណត្តិ៖ លោកស្រី អត្តលេខ

-ចុងចម្លើយ៖ ឈ្មោះ ភេទស្រី កើតថ្ងៃទី ខែកក្កដា ឆ្នាំ១៩៩៥ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ មានអាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ផ្លូវ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

**ការផ្សះផ្សា**

តុលាការបានទុកលទ្ធភាពគូភាគីទាំងពីរធ្វើការ ផ្សះផ្សាគ្នា ដោយការដកពាក្យសុំប្តឹង និងយកគ្នាជាប្តីប្រពន្ធឡើងវិញ។

ដើមចោទ បានធ្វើសេចក្តីថ្លែងថា៖ ខ្លួនមិនអាចយកគ្នាជាប្តីប្រពន្ធឡើងវិញបានទេ។

ចុងចម្លើយ បានធ្វើសេចក្តីថ្លែងថា៖ ខ្លួនក៏មិនអាចយកគ្នាជាប្តីប្រពន្ធឡើងវិញបានទេ។

**ដើមចោទបានថ្លែងករណីអំពីពាក្យបណ្តឹង**

ដើមចោទ បានធ្វើសេចក្តីថ្លែងថា៖ ទី១ ខ្លួនសុំលែងលះពីចុងចម្លើយឈ្មោះ ទី២ សុំអោយចុងចម្លើយមានសិទ្ធិអំណាចមេបាលើកូនប្រុសម្នាក់ឈ្មោះ កើតថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ទី៣ ខ្លួនសុំបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនទៅតាមលទ្ធភាព និងទី៤ សុំឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

ចុងចម្លើយ បានធ្វើសេចក្តីថ្លែងថា៖ ខ្លួនឯកភាពទៅតាមសេចក្តីទាមទារខាងលើរបស់ដើមចោទទាំងទាំងបួនចំណុច។

ដោយយោងលើការអះអាងលើភាគីទាំងពីរ នូវការទាមទាររបស់ដើមចោទ និងការទទួលស្គាល់របស់ចុងចម្លើយ តុលាការពិចារណាឃើញថា គប្បីទុកសិទ្ធិអោយភាគីដាក់ពាក្យសុំលែងលះតាមការព្រមព្រៀង ស្របតាមស្មារតីច្បាប់ស្តីពីនីតិវិធីបណ្តឹងរដ្ឋប្បវេណីមិនមែនជាបណ្តឹង វិញ។

ភាគីទាំងពីរបានឯកភាពយល់ព្រម ក្នុងការដកពាក្យបណ្តឹង ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ និងដាក់ពាក្យសុំដីកាសម្រេចលែងលះតាមការព្រមព្រៀង។

តុលាការបានបញ្ឈប់កំណត់វេលាម៉ោង ១១ និង ០០នាទី នៅខែឆ្នាំដដែល។

ដើមចោទ ចុងចម្លើយ អ្នកតំណាងដោយអាណត្តិ ក្រឡាបញ្ជី ចៅក្រម




**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។

| | |
|---|---|
| -អញ្ជើញឈ្មោះ ភេទប្រុស កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ១៩៨៣ **ជាដើមចោទ**។<br>អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅ ភូមិស្រែព្រីង សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំ ខេត្តកំពង់ឆ្នាំង។ (ទូរស័ព្ទលេខ ០ | |
| -សញ្ញាណនៃរឿងក្តី៖<br>**ប្តឹងសុំសាលក្រមលែងលះប្រពន្ធ** | -សំណុំរឿងក្តីលេខ ៦១២ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣<br>-ដើមចោទឈ្មោះ ភេទប្រុស កើតថ្ងៃទី ខែកញ្ញា ឆ្នាំ១៩៨៣។<br>-ចុងចម្លើយឈ្មោះ ភេទស្រី កើតថ្ងៃទី ខែវិច្ឆិកា ឆ្នាំ១៩៨៨។ |
| -កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន៖ | -ថ្ងៃទី ខែ ឆ្នាំ២០២៤ វេលាម៉ោង.......ព្រឹក.........។<br>-បន្ទប់ "ធ" ជាន់ទី ...សាលាដំបូងរាជធានីភ្នំពេញ (សាលាយុត្តិធម្ម)។ |
| -ដំណាក់កាលនៃនីតិវិធី | ១.☒ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ៣.☐ ប្រកាសសាលក្រម<br>២.☑ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ៤.☐ សាកសួរ ៥.☐ ការផ្សះផ្សា |
| -ប្រភេទនៃឯកសារដែលភ្ជាប់មកជាមួយ៖ | ១. លិខិតផ្សេងៗទៀតដែលពាក់ព័ន្ធ។ |
| -ទណ្ឌកម្មជាអាទិ៍ ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ៖ | <u>១. ចំពោះសាមីភាគី</u>៖ បើពុំចូលខ្លួនទេ តុលាការទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀត ជាការពិតបាន។ **តាមមាត្រា ១៤០ កថាខណ្ឌទី ២.២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី**។<br><u>២. ចំពោះសាក្សី</u>៖ បើមិនព្រមចូលខ្លួនមកតុលាការដោយ គ្មានមូលហេតុត្រឹមត្រូវ *តុលាការអាចពិន័យជាសាច់ប្រាក់ មិនលើសពី ១,០០០,០០០ (មួយលាន)* រៀល តាមមាត្រា **១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី**។ |
| -សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចបានកំណត់ខាងលើនេះ។<br>ថ្ងៃ............ ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស២៥៦៨<br>រាជធានីភ្នំពេញ ថ្ងៃទី.......... ខែមិថុនា ឆ្នាំ២០២៤<br>**ចៅក្រម** | |

**<u>សម្គាល់</u>៖**
-ករណីដែលមានជំងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចមកបង្ហាញខ្លួន សូមភ្ជាប់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់ពីមូលហេតុនោះជូនតុលាការ។
-ពេលបង្ហាញខ្លួន សូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក
-ទម្រង់នេះ ប្រើសម្រាប់៖ ភាគី, សាក្សី, អ្នកចូលរួមអន្តរាគមន៍ក្នុងបណ្តឹង។

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីលេខ ១៧៥៣
ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់

(មាត្រា ១១៨ និងមាត្រា ១១៩)

**សញ្ញាណរឿងក្តី**

-ប្តឹងសុំលែងលះ

**ដោយមានសមាសភាព**

លោក **គី ឫទ្ធី** អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

លោក **ផាង លាងសេង** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទ ឈ្មោះ ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានផ្ទះលេខ ផ្លូវលេខ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

មាន មេធាវី អត្តលេខ ជាមេធាវីតំណាងអាណត្តិឱ្យដើមចោទ ។

-ចុងចម្លើយឈ្មោះ ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិអាមេរិក អាសយដ្ឋានផ្ទះលេខ ផ្លូវលេខ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

កម្មវត្ថុនៃការទាមទារ៖ **ប្តឹងសុំលែងលះ**

នៅសាលសវនាការទី២ វេលាម៉ោង ពីរ និងសាមសិបនាទី រសៀល ឆ្នាំពីរពាន់ម្ភៃមួយ ខែមីនា ថ្ងៃទីម្ភៃពីរ នៅសាលាដំបូងរាជធានីភ្នំពេញ បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ដូចខាងក្រោម៖

-ដើមចោទឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថាៈ នាងខ្ញុំនៅតែរក្សាប្តឹងការទាមទារដូចក្នុងពាក្យបណ្តឹងដដែល ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ និងសូមរក្សាសេចក្តីថ្លែងការណ៍ដូចក្នុងសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកមុនចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ទុកជាបានការដដែល ។

នាងខ្ញុំសូមជម្រាបលោកចៅក្រមមេត្តាជ្រាបថា នាងខ្ញុំពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយពិតប្រាកដមែន និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ មានសំបុត្រអាពាហ៍ពិពាហ៍លេខ ១៥៣ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ហើយតាំងពីរៀបការជាមួយគ្នាមក គឺរួមរស់មិនចុះសំរុងនឹងគ្នា ហើយសព្វថ្ងៃនេះចុងចម្លើយបានចេញពីលំនៅសង្វាសជាយូរមកហើយ ជាហេតុផ្ទុយពីអត្ថន័យអាពាហ៍ពិពាហ៍ ដែលជាហេតុធ្វើឱ្យនាងខ្ញុំអស់មនោសញ្ចេតនាមិនអាចរស់នៅបែបនេះតទៅទៀតបាន។ តាំងពីនាងខ្ញុំរួមរស់ជាមួយចុងចម្លើយគឺពុំមានបំណុលរួម ទ្រព្យសម្បត្តិរួម និងកូននោះទេ ហេតុនេះសូមលោកចៅក្រមមេត្តាចេញសាលក្រមឱ្យនាងខ្ញុំបានលែងលះពីចុងចម្លើយ ។

មេធាវី តំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ នាងខ្ញុំសូមរក្សាសេចក្តីនូវសេចក្តីថ្លែងការណ៍របស់កូនក្តីនាងខ្ញុំទុកជាបានការដដែល និងស្នើសុំលោកចៅក្រមមេត្តាចេញសាលក្រមឱ្យកូនក្តីនាងខ្ញុំបានលែងលះពីចុងចម្លើយ ។

ចុងចម្លើយអវត្តមាន ដោយតុលាការបានធ្វើការបញ្ជូនរួចកាល់ហើយ ដោយបញ្ជូនទៅអាសយដ្ឋានចុងក្រោយរបស់ចុងចម្លើយត្រឹមត្រូវតាមច្បាប់ ហើយបានបញ្ជូនតាមមាត្រា២៥៥ និងមាត្រា ២៥៦ តាមក្រមនីតិវិធីរដ្ឋប្បវេណីរួចកាល់ហើយតែចុងចម្លើយនៅតែអវត្តមានដដែល ។

តុលាការសម្រេចប្រកាសបិទបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងកំណត់កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង បីរសៀល នៅសាលសវនាការទី២ សាលាដំបូងរាជធានីភ្នំពេញ ។

បញ្ឈប់កំណត់ហេតុ នៅវេលាម៉ោង បី រសៀល នាថ្ងៃខែឆ្នាំដដែល ។

**មេធាវី ដើមចោទ** **ចុងចម្លើយ** **ក្រឡាបញ្ជី** **ចៅក្រម**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ ៣១៦ "គ"

-ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១

-សំណុំរឿងរដ្ឋប្បវេណីលេខ ១៧៥៣

ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០

## គោរពនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី**២២ ខែមីនា ឆ្នាំ២០២១** វេលារសៀល នៅសាលសវនាការទី២ លើ**សំណុំរឿងរដ្ឋប្បវេណីលេខ ១៧៥៣** ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

-លោក **គី ឫទ្ធី** ជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-លោក **ផាង លាងសេង** ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទ ឈ្មោះ ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានផ្ទះលេខ ផ្លូវលេខ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ( )។

មាន មេធាវី អត្តលេខ ជាមេធាវីតំណាងអាណត្តិឱ្យដើមចោទ ។

-ចុងចម្លើយឈ្មោះ ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិអាមេរិក អាសយដ្ឋានផ្ទះលេខ ផ្លូវលេខ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

## I. អង្គហេតុ និងចំណុចវិវាទ

**១.ខ្លឹមសារនៃបណ្ដឹងសុំរបស់ដើមចោទ៖**

-សុំលែងលះជាមួយប្ដីឈ្មោះ តាមច្បាប់

**២.ការពន្យល់ត្រួសៗអំពីរឿងក្ដី**

-រឿងក្ដីនេះ គឺជារឿងក្ដីដែលដើមចោទ បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយចុងចម្លើយ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ មានលេខ: ១៥៣ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ក្នុងការរស់នៅជាមួយគ្នាអ្នកទាំងពីរ គឺពុំមានកូន និងទ្រព្យសម្បត្តិដោយឡែក ឬរួមនោះទេ ។ ក្នុងអំឡុងពេលរួមរស់ជាមួយគ្នាដើមចោទ និងជាចុងចម្លើយ រស់នៅមិនចុះសំរុងនឹងគ្នា មានគំនិតខ្វែងគ្នា ហើយចុងចម្លើយបានចុះពីលំនៅដ្ឋានតាំងពីឆ្នាំ២០១៤ ដែលផ្ទុយពីគោលបំណងនៃអាពាហ៍ពិពាហ៍ ទើបដើមចោទដាក់ពាក្យប្ដឹងលែងលះពីចុងចម្លើយ តែម្ដង។

**៣.អង្គហេតុដែលអះអាងដោយដើមចោទ**

**-ដើមចោទឈ្មោះ** បានធ្វើសេចក្ដីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ថា៖ នាងខ្ញុំនៅតែរក្សាការទាមទារដូចក្នុងពាក្យបណ្ដឹងដែលចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ គឺស្នើសុំលោកចៅក្រមមេត្តាចេញសាលក្រមឱ្យនាងខ្ញុំលែងលះជាមួយចុងចម្លើយតាមការស្នើសុំ។ នាងខ្ញុំសូមជម្រាបលោកចៅក្រមមេត្តាជ្រាបថា: នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ជាមួយចុងចម្លើយឈ្មោះ ដែលជាប្ដីតាំងពីឆ្នាំ២០១៤ កាលពីថ្ងៃទី៣១.០៨.២០១៤ មានសំបុត្រអាហ៍ពិពាហ៍លេខ ១៥៣ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤

ដោយនាងខ្ញុំ និងប្តីបានចុះសំបុត្រអាពាហ៍ពិពាហ៍មុនថ្ងៃរៀបការ ។

តាំងពីរៀបអាពាហ៍ពិពាហ៍មករហូតដល់សព្វថ្ងៃនេះ នាងខ្ញុំ និងចុងចម្លើយ គឺពុំមានកូននោះទេ ទ្រព្យសម្បត្តិរួម
បំណុលរួមក៏ពុំមានដែល ។ ចំពោះការលែងលះនេះដោយសារនាងខ្ញុំ និងចុងចម្លើយរស់នៅមិនចុះសំរុងនឹងគ្នា ដោយមាន
ការខ្វែងគំនិតគ្នា រស់នៅគ្មានសុភមង្គល ហើយចុងចម្លើយបានចុះចោលទីលំនៅឋានតាំងពីចុងឆ្នាំ ២០១៤ ម្លេះ ពោលគឺ
បាត់ដំណឹងរហូត មិនអាចទំនាក់ទំនងគ្នាបាន ។

ហេតុដូចនេះសូមលោកចៅក្រមមេត្តាចេញសាលក្រមសម្រេចឱ្យនាងខ្ញុំលែងលះពីចុងចម្លើយ ។

**-ដើមចោទឈ្មោះ** បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលនៅថ្ងៃទី២២ ខែមីនា ឆ្នាំ
២០២១ ថា៖ នាងខ្ញុំនៅតែរក្សាប្តឹងការទាមទារដូចក្នុងពាក្យបណ្តឹងដដែល ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ និងសូមរក្សា
សេចក្តីថ្លែងការណ៍ដូចក្នុងសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកមុនចុះថ្ងៃទី០១ ខែមីនា ឆ្នាំ
២០២១ ទុកជាបានការដដែល ។

នាងខ្ញុំសូមជម្រាបលោកចៅក្រមមេត្តាជ្រាបថា: នាងខ្ញុំពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយពិតប្រាក
ដមែន និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ មានសំបុត្រអាពាហ៍ពិពាហ៍លេខ ១៥៣ ចុះថ្ងៃទី២៩ ខែ
សីហា ឆ្នាំ២០១៤ ហើយតាំងពីរៀបការជាមួយគ្នាមក គឺរួមរស់មិនចុះសំរុងនឹងគ្នា ហើយសព្វថ្ងៃនេះចុងចម្លើយបានចេញ
ពីលំនៅសង្វាសជាយុរមកហើយ ជាហេតុផ្ទុយពីអត្ថន័យអាពាហ៍ពិពាហ៍ ដែលជាហេតុធ្វើឱ្យនាងខ្ញុំអស់មនោសញ្ចេតនា
មិនអាចរស់នៅបែបនេះតទៅទៀតបាន ។ តាំងពីនាងខ្ញុំរួមរស់ជាមួយចុងចម្លើយ គឺពុំមានបំណុលរួម ទ្រព្យសម្បត្តិរួម និង
កូននោះទេ ហេតុនេះសូមលោកចៅក្រមមេត្តាចេញសាលក្រមឱ្យនាងខ្ញុំបានលែងលះពីចុងចម្លើយ ។

មេធាវី តំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ នាងខ្ញុំសូមរក្សាសេចក្តីនូវសេចក្តីថ្លែង
ការណ៍របស់កូនក្តីនាងខ្ញុំទុកជាបានការដដែល និងស្នើសុំលោកចៅក្រមមេត្តាចេញសាលក្រមឱ្យកូនក្តីនាងខ្ញុំបានលែងលះ
ពីចុងចម្លើយ ។

**៤.អង្គហេតុដោយចុងចម្លើយ**

-ចុងចម្លើយឈ្មោះ ភេទប្រុស ពុំបានចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលពីថ្ងៃទី
០១ ខែមីនា ឆ្នាំ២០២១ នោះទេ ទោះបីតុលាការបានធ្វើការកោះហៅ តាមរយៈជូនដំណឹងស្តីពី ការបញ្ជូនតាមការផ្សាយ
ជាសាធារណៈលេខ:០២ "គ"រ.វ.ក្រ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ តែចុងចម្លើយនៅ
តែអវត្តមានដដែល ។

## II.ការពិនិត្យភស្តុតាង

**១ ភស្តុតាងជាឯកសាររបស់ដើមចោទ**

១.១.ឯកសារ $X_1$ ៖ សំបុត្រអាពាហ៍ពិពាហ៍លេខ ១៥៣ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤។

១.២.ឯកសារ $X_២$ ៖ ពាក្យបណ្តឹងស្តីពីការចុះពីលំនៅ របស់ឈ្មោះ ពិល លាន ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងការពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖

**១.ស្តីពីការទាមទារទី១៖ ការទាមទារលែងលះ**

១.១-តាមសំបុត្រអាពាហ៍ពិពាហ៍លេខ: ១៥៣ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ចេញដោយមន្ត្រី អត្រានុកូល
ដ្ឋានសង្កាត់ភ្នំពេញថ្មី (ឯកសារ $X_1$) ព្រមទាំងការអះអាងរបស់ដើមចោទថា ខ្លួនបានរៀបការជាមួយចុងចម្លើយតាម

ប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ ត្រឹមត្រូវតាមច្បាប់ពិតមែន ដូចមាននៅក្នុងសំបុត្រអាពាហ៍ពិពាហ៍លេខ ១៥៣ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ភ្នំពេញថ្មី។ ការដែលដើមចោទ និងចុងចម្លើយ រស់នៅជាមួយគ្នាដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នឹងគ្នាបែបនេះ មានន័យថាដើមចោទ និងចុងចម្លើយ មានជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា គឺរស់នៅជាមួយគ្នាមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

១.២-ដើមចោទបានអះអាងថា ខ្លួនសុំលែងលះជាមួយចុងចម្លើយ ដោយសារតែការរស់នៅជាមួយ គ្នាកន្លងមកមានភាពមិនចុះសម្រុងនឹងគ្នា ដោយមានការខ្វែងគំនិតគ្នា រស់នៅគ្មានសុភមង្គល រហូតធ្វើឱ្យខ្លួនរស់មនោសញ្ចេតនា ហើយចុងចម្លើយបានចុះចេញពីលំនៅឋានតាំងពីចុងឆ្នាំ២០១៤ រហូតមកទល់បច្ចុប្បន្ន មិនអាចទាក់ទងគ្នាបាន។ គឺធ្វើឱ្យតុលាការជឿថាចំណងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយពិត ឈានទៅរកភាពបែកបាក់ដោយភាគីទាំងពីរពុំមានចេតនាណាមួយផ្សះផ្សាគ្នាឡើយ ដោយគ្មានសង្ឃឹមថានឹងអាចធ្វើបរិវាសឡើងវិញបាននោះទេ។

១.៣-ការដែលចំណងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ ដោយគ្មានសង្ឃឹមថានឹងអាចធ្វើបរិវាសឡើងវិញបាននោះ គឺបង្ហាញឱ្យឃើញថា ការទាមទារលែងលះរបស់ ដើមចោទ គឺស្របតាមមាត្រា ៩៧៨-ខ.គ.ឃ និងចំណុច ង នៃក្រមរដ្ឋប្បវេណី ដែលគប្បីតុលាការសម្រេចឱ្យដើមចោទ និងចុងចម្លើយលែងលះគ្នាតាមការស្នើសុំរបស់ដើមចោទ។

១.៤-នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការបានជូនដំណឹងទៅចុងចម្លើយមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយមានភ្ជាប់នូវពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលដើមចោទបានដាក់ពាក្យបណ្តឹងមកតុលាការ ដោយតុលាការបានកោះហៅតាមរយៈការផ្សាយជាសាធារណៈនូវសេចក្តីជូនដំណឹងដីកាបញ្ជូនតាមរយៈការផ្សាយជាសាធារណៈលេខ ០២ គរក្រ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ នៅក្នុងកាសែត នគរធំ ឆ្នាំទី២៦ លេខ២៥៥០ ចេញផ្សាយថ្ងៃអង្គារ ទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ និងបានបិទផ្សាយនៅបញ្ជរព័ត៌មានរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលការណ៍នេះពុំមែនជាមូលហេតុដែលមានបញ្ញត្តក្នុងមាត្រា ២០២ ចំណុច ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ ដូចនេះតុលាការអាចចេញសាលក្រមកំបាំងមុខចុងចម្លើយបាន ស្របតាមមាត្រា២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-ប្រាក់ប្រដាប់ក្តី៖ ត្រូវអនុវត្តតាមមាត្រា ៦៤-១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-ឱ្យដើមចោទឈ្មោះ                    ភេទស្រី លែងលះគ្នាពីចុងចម្លើយឈ្មោះ                    ភេទប្រុស ។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ។

គូភាគីមានប្តឹងទាស់ និងឧទ្ធរណ៍គិតចាប់ពីថ្ងៃបានទទួលសាលក្រមនេះ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: **គី ឫទ្ធី**

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ [illegible] ខែចេត្រ ឆ្នាំឆ្លូវ ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

ផាន លាងសេង

បានឃើញ

**ចៅក្រម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ចុះលេខ ថ្ងៃទី 13 ខែ 10 ឆ្នាំ 2021

# ពាក្យសុំបញ្ជាក់សាលក្រមចូលជាស្ថាពរ

នាងខ្ញុំឈ្មោះ                    អាយុ ៤០ ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ                    មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ                    ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាដើមចោទ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ១៧៥៣ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

សាលាដំបូងរាជធានីភ្នំពេញ
0004893
13 ខែ 10 ឆ្នាំ 2021

## សូមគោរពជូន

## ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ៖** សុំបញ្ជាក់សាលក្រមរដ្ឋប្បវេណីលេខ ៣១៦ "គ" ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលចូលជាស្ថាពរ។

**យោង ៖**- សំណុំរឿងរដ្ឋប្បវេណីលេខ ១៧៥៣ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។
- សាលក្រមរដ្ឋប្បវេណីលេខ ៣១៦ "គ" ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ១៧៥៣ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ តុលាការបានចេញសាលក្រមរដ្ឋប្បវេណីលេខ ៣១៦ "គ" ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ នឹងបានចូលជាស្ថាពរតាមផ្លូវច្បាប់ហើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាបញ្ជាក់លើសាលក្រម ដែលចូលជាស្ថាពរតាមការស្នើសុំរបស់នាងខ្ញុំ ដើម្បីឲ្យនាងខ្ញុំបានយកទៅប្រើប្រាស់តាមផ្លូវច្បាប់ ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ថ្ងៃ.....កើត.ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៣....ខែតុលា ឆ្នាំ២០២១
**ស្នាមមេដៃស្ដាំ**



គំរូលេខ 09 សហវ/ធអព

260-1-00041893

MEF18000152814

ក្រសួងយុត្តិធម៌

# បង្កាន់ដៃបង់ប្រាក់

(ប្រគល់ជូនអ្នកបង់ប្រាក់)

អង្គភាព

ទទួលពី ........................ ..........អង្គភាព ........................

ចំនួនទឹកប្រាក់ជាលេខ ........................ 5,000 ........................

ជាអក្សរ ................................................

អត្ថន័យចំណូល ........................ មាតិកាថវិកា ........................

ថ្ងៃទី 13 ខែ 10 ឆ្នាំ ........

អ្នកប្រមូលចំណូល

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ ១៣៥២..“ធ” ល.ស.ព

## <u>លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម</u>

យើង **ខាម ផនមិច្ឆិកា** ក្រឡាបញ្ជីនៃសាលាដំបូងសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០២១/០៧០៦ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ១៧៥៣ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៣១៦ “គ” ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍ស្តីពីការបញ្ជូន ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ២០២១ របស់ឈ្មោះ . ។

-បានឃើញ សារពត៌មាន កាសែតនគរធំ ឆ្នាំទី២៦ លេខ ២៦៣២ ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០២១ ។

-បានឃើញ ពាក្យសុំបញ្ជាក់សាលក្រមស្ថាពរ ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២១ របស់ដើមចោទឈ្មោះ .. ដែលមានខ្លឹមសារស្នើសុំលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមលេខ ៣១៦ “គ” ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

<u>បញ្ជាក់ថា</u>

១.សាលក្រមរដ្ឋប្បវេណីលេខ ៣១៦ “គ” ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ បានចូលជាស្ថាពរចំពោះគូភាគី **ចាប់ពីថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០២១ តទៅ** ។

២.លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមនេះ ចេញឲ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់ ។

ថ្ងៃ..ពុធ ៥កើត.... ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ០៨.. ខែធ្នូ ឆ្នាំ ២០២១

**ក្រឡាបញ្ជី**

ខាម ផនមិច្ឆិកា